FTB

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

**Foreign Trade Bank of Cambodia**

## ស្នាក់ការកណ្តាល


អគារលេខ៣ វិថីក្រមួនស សង្កាត់ផ្សារថ្មី១

ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855-23) 724 466 / 722 466 / 725 266

ទូរសារ: (855-23) 426 108 / 426 410

អ៊ីមែល: info@ftbbank.com

វិបសាយ: www.ftbbank.com

FTB

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

Foreign Trade Bank of Cambodia

# វិនិយោគដើម្បីអនាគត

# របាយការណ៍ប្រចាំឆ្នាំ 2010




FTB

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

Foreign Trade Bank of Cambodia

# មាតិកា

## ទស្សនៈទូទៅនៃអាជីវកម្ម

1


ព័ត៌មានទូទៅរបស់ធនាគារ 4
បេសកកម្ម និងចក្ខុវិស័យ 4
ព័ត៌មានរបស់ធនាគារ 5
អង្គការលេខរបស់ធនាគារ 6
របាយការណ៍ហិរញ្ញវត្ថុសង្ខេបរយៈពេល៤ឆ្នាំ 7
លទ្ធផលអនុវត្តអាជីវកម្ម 8
សាររបស់លោកឧកញ៉ាប្រធានក្រុមប្រឹក្សាភិបាល 9
សាររបស់អគ្គនាយក 11


2

## អភិបាលកិច្ច


ក្រុមប្រឹក្សាភិបាល 13
គណៈគ្រប់គ្រង 13
សមាជិកក្រុមប្រឹក្សាភិបាល 15
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល 16


## របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

3


របាយការណ៍ក្រុមប្រឹក្សាភិបាល 19
របាយការណ៍សវនករឯករាជ្យ 23
តារាងតុល្យការ 24
របាយការណ៍លទ្ធផល 25
របាយការណ៍បំរែបំរួលមូលធន 26
របាយការណ៍លំហូរសាច់ប្រាក់ 27
កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ 28

# ព័ត៌មានទូទៅរបស់ធនាគារ

| | |
|---|---|
| ទម្រង់ទ្រាយគតិយុត្ត: | ធនាគាររដ្ឋចម្រុះឯកជន |
| ទីស្នាក់ការកណ្តាលៈ | ស្ថិតនៅអាគារលេខ៣ វុក្ខវិថីក្រមួនស សង្កាត់ផ្សារថ្មី ១ ខណ្ឌដូនពេញ<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។<br>ទូរស័ព្ទ : +៨៥៥ (0)២៣ ៧២៤ ៤៦៦ , ៧២២ ៤៦៦ , ៧២៥ ២៦៦<br>ទូរសារ : +៨៥៥ (0)២៣ ៤២៦ ១0៨ , ៤២៦ ៤១0<br>អ៊ីមែល : info@ftbbank.com<br>www.ftbbank.com |
| ដើមទុនចុះបញ្ជី: | ១៣,000,000.00 ដុល្លារអាមេរិក ដើមទុនបានកើនដល់<br>៣៧.៥00.000 ដុល្លារអាមេរិក នៅថ្ងៃទី ៣១ ខែ មករាឆ្នាំ ២0១១ |
| អាជ្ញាប័ណ្ណអាជីវកម្មលើកដំបូង : | លេខ១៦ ចុះថ្ងៃទី0៤ ខែមករា ឆ្នាំ២00១ |
| វិសោធនកម្មលក្ខន្តិកៈ | វិសោធនកម្មលក្ខន្តិកៈនៅធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២00៦ |
| ចុះបញ្ជីពាណិជ្ជកម្ម: | Co ៥២៨0/00 ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២000 ចុះបញ្ជីសាជាថ្មីលេខ<br>Co ៨៨៣៥/0៦ M ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២00៦ និងនៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២00៧ |

# បេសកកម្ម

ដើម្បីប្រែក្លាយជាធនាគារដ៏ល្អមួយនៅកម្ពុជា នៅក្នុងជំនឿរបស់អតិថិជន ក៏រឹតសេវាកម្ម និងក៏រឹតផលិតផល។ យើងនឹងធ្វើអោយសំរេចនូវបេសកកម្មខាងលើនេះ ដោយផ្តល់នូវសេវាកម្មថ្នាក់លេខមួយ និងផលិតផលហិរញ្ញវត្ថុយ៉ាងសមរម្យ និងប្រកបដោយការច្នៃប្រឌិត ដោយមិនត្រឹមតែបង្កើតអោយមានឡើងនោះទេ គឺធ្វើអោយមានតំលៃជាអតិបរមាសំរាប់អតិថិជននិងភាគទុនិករបស់យើង។

ក្នុងនាមជាអង្គភាពមួយ យើងប្រឹងប្រែងអោយអស់លទ្ធភាព ដើម្បីជោគជ័យ ភាពល្អបំផុត និងប្រកបដោយស្តង់ដារខ្ពស់បំផុត សម្រាប់អ្វីដែលយើងធ្វើដោយជ្រើសរើសបុគ្គលិកដែលមានគុណភាពកំពូល បង្កើតកន្លែងធ្វើការដែលប្រកបដោយទិន្នផលខ្ពស់ ផ្តល់បរិដ្ឋានរៀនសូត្រប្រកបដោយសុខភាព និងទទួលស្គាល់ ព្រមទាំងផ្តល់រង្វាន់ដល់បុគ្គលិកយើង និងកសាងក្រុមការងារមួយមានសមត្ថភាព និងត្រៀមខ្លួនដឹកនាំធនាគារឆ្ពោះទៅកាន់សម័យកាលថ្មី ប្រកបដោយជោគជ័យ ។

# ចក្ខុវិស័យ

ដើម្បីប្រែក្លាយជាធនាគារដ៏ល្អមួយនៅកម្ពុជា និងទទួលស្គាល់ពីអតិថិជនដោយ :

- ផ្តល់ជូនភាគទុនិក នូវផលចំណេញលើការវិនិយោគយ៉ាងសមរម្យ និងយូរអង្វែង
- ជានិយោជកដ៏ល្អបំផុត ដោយឈរលើមូលដ្ឋានប្រាក់បៀវត្ស លក្ខខណ្ឌការងារ និងឱកាសនៃការអភិវឌ្ឍន៍ការងារ
- ផ្តល់នូវតំលៃការងារល្អ ផលិតផលដ៏ល្អបំផុត សុវត្ថិភាព និងក៏រឹតសេវាកម្មខ្ពស់សំរាប់អតិថិជនរបស់យើង
- ចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈការអនុវត្តន៍យុទ្ធសាស្ត្រ វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

# ព័ត៌មានរបស់ធនាគារ

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា បានបង្កើតឡើងនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ដោយអនុក្រិត្យ លេខ១២១៣ ក្នុងអតីតរបបរដ្ឋកម្ពុជា ក្នុងគោលដៅ :

- ធ្វើប្រតិបត្តិការ និងផ្តល់សេវាកម្មធនាគារ
- គ្រប់គ្រងប្រតិបត្តិការទិញដូររូបិយប័ណ្ណ
- ប្រតិបត្តិការទូទាត់អន្តរជាតិ
- ផ្តល់ឥណទានគ្រប់ប្រភេទ
- រួមចំណែកការពាររូបិយវត្ថុជាតិ និងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងសេដ្ឋកិច្ច និងទំនាក់ទំនងវប្បធម៌ខាងក្នុង និងខាងក្រៅប្រទេស
- ធ្វើប្រតិបត្តិការក្នុងរូបភាពជានីតិបុគ្គលដោយឡែកពីរដ្ឋាភិបាល

ចាប់ពីថ្ងៃប្រវត្តិសាស្ត្រ៧មករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃរំដោះ ដល់ឆ្នាំ១៩៩៩ ធនាគារបានប្រឹងប្រែងដើម្បីធ្វើឱ្យសំរេចគោលដៅខាងលើនេះ ដោយធ្វើប្រតិបត្តិការរបស់ខ្លួនក្នុងនាមជានាយកដ្ឋានមួយរបស់ធនាគារជាតិនៃកម្ពុជា។ ដោយមានរៀបចំប្រព័ន្ធអាជីវកម្ម និងនីតិវិធីសមស្រប ធនាគារបានដើរតួនាទីមួយយ៉ាងសកម្ម ក្នុងទីផ្សារក្នុងស្រុក និងក្រៅប្រទេស ដែលទទួលបានជាលទ្ធផលមកវិញ គឺការបានចូលរួមចំណែកក្នុងការស្តារសេដ្ឋកិច្ច នៃប្រទេសកម្ពុជា។ មិនយូរប៉ុន្មានធនាគារក៏បានទទួលទំនុកចិត្តអំពីអតិថិជន និងបានកសាងសមត្ថភាពបច្ចេកទេសចាំបាច់ សំរាប់ធ្វើអាជីវកម្មបានចំណេញ។ នៅឆ្នាំ ១៩៩៩ ដើម្បីផ្តល់ឱកាសអោយធនាគាជាតិ នៃកម្ពុជា ធ្វើការផ្តោតអារម្មណ៍លើតួនាទីរបស់ខ្លួនក្នុងនាមជាធនាគារកណ្តាល និងជាអាជ្ញាធររូបិយវត្ថុជាតិ និងអនុញ្ញាតអោយធនាគារ FTB ធ្វើធុរៈកិច្ចជាស្វយ័តស្មើមុខជាមួយធនាគារពាណិជ្ជផ្សេងទៀត ព្រមទាំងដើម្បីអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលផង ការធ្វើឯកជនភាវូបនីយកម្មធនាគារ FTB ត្រូវបានកំណត់ជាគន្លឹះសំខាន់។

នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០០ ធនាគារ FTB បានផ្លាស់ប្តូររូបភាពគតិយុត្តរបស់ខ្លួនដោយបានក្លាយជាធនាគារពាណិជ្ជរបស់រដ្ឋមានចរិតជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច។

នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០២ ភាគហ៊ុនចំនួន៨០%នៃធនាគារបានត្រូវផ្ទេរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅសល់ ២០%ទៀតជាកម្មសិទ្ធិរបស់ធនាគារជាតិ នៃកម្ពុជា។

នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ធនាគារបានប្តូររូបភាពគតិយុត្ត ពីធនាគាររដ្ឋមកជាធនាគាររដ្ឋចម្រុះឯកជន។ ម្ចាស់កម្មសិទ្ធិថ្មី គឺធនាគារកាណាឌីយ៉ាភីអិលស៊ីមាន ៤៦% ក្រុមហ៊ុនអាយអិនជីហូលឌីងខូអិលធីឌី ៤៤% និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១០% នៃដើមទុនសរុប។

ក្នុងខែ មេសា ឆ្នាំ ២០០៩ លោកជំទាវ អ៊ុក ម៉ាលី បានលាឈប់ពីតំណែងជាអគ្គនាយក បន្ទាប់ពីបំពេញការងារដោយជោគជ័យ នៅក្នុងធនាគារ អស់រយៈពេលជិត ៣០ឆ្នាំ។

ដើម្បីសម្របតាមអនុសាសន៍របស់ធនាគារជាតិ នៃកម្ពុជា ធនាគារកាណាឌីយ៉ាបានកាត់បន្ថយភាគហ៊ុនរបស់ខ្លួន អោយនៅសល់តែ១៥,២២% នាខែ កក្កដា ឆ្នាំ ២០០៩។ នៅក្នុងបរិមាណភាគហ៊ុនដែលធនាគារកាណាឌីយ៉ាបានធ្វើអនុប្បទាន លោកស្រី គិម ទៀកបានទទួលយក១៥,៣៩% និង១៥,៣៩%ទៀតគឺ លោកស្រី ឆាយគីមបួយ។ ធនាគារជាតិ នៃកម្ពុជា បានទទួលស្គាល់ ភាគទុនិកថ្មីតាមរយៈលិខិតលេខធ៧.០៩.១៥៤.ឆ.ត ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩។ សមាជិកក្រុមប្រឹក្សាភិបាលឯករាជថ្មីម្នាក់ទៀត បានទទួលការតែងតាំងជាបន្ថែមពីលើចំនួនពីរនាក់មុន។ សមាជិកឯករាជទាំងនោះ គឺលោកជំទាវ សុខ ចាន់សូណា នៅឆ្នាំ ២០០៧ លោកកង អ៊ី នៅឆ្នាំ ២០០៨ និងលោក នួន សំអ៊ាន នាខែ កក្កដាឆ្នាំ ២០០៩ ។

# អង្គការលេខរបស់ធនាគារ



# របាយការណ៍ហិរញ្ញវត្ថុសង្ខេបរយៈពេល៤ឆ្នាំ

## តារាងតុល្យការសង្ខេប (ដុល្លារអាមេរិក)

| | 2010 | 2009 | 2008 | 2007 |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | 329,274,921 | 271,759,672 | 262,691,555 | 219,994,181 |
| ឥណទាន និងបុរេប្រទានសុទ្ធ | 136,201,031 | 95,765,360 | 93,967,174 | 65,475,143 |
| ទ្រព្យសកម្មផ្សេងៗ | 193,073,890 | 175,994,312 | 168,724,381 | 154,519,038 |
| ទ្រព្យអកម្មសរុប | 281,614,029 | 230,491,256 | 226,706,365 | 191,330,644 |
| ប្រាក់បញ្ញើអតិថិជន | 276,930,868 | 226,229,038 | 222,906,600 | 188,087,859 |
| ទ្រព្យអកម្មផ្សេងៗ | 4,683,161 | 4,262,218 | 3,799,765 | 3,242,785 |
| ដើមទុនចុះបញ្ជី | 35,750,000 | 13,000,000 | 13,000,000 | 13,000,000 |
| ទុនបំរុង និងប្រាក់ចំណេញរក្សាទុក | 11,910,892 | 28,268,416 | 22,985,190 | 15,663,537 |

## របាយការណ៍លទ្ធផលសង្ខេប (ដុល្លារអាមេរិក)

| | 2010 | 2009 | 2008 | 2007 |
|---|---|---|---|---|
| ចំណូលពីការប្រាក់សុទ្ធ | 8,020,895 | 8,112,037 | 8,612,015 | 8,932,451 |
| ចំណេញប្រតិបត្តិការមុនពេលពង្រីកឥណទាន | 8,080,506 | 10,852,969 | 8,486,931 | 9,215,739 |
| ចំណេញមុនបង់ពន្ធ | 8,108,840 | 6,409,880 | 9,146,333 | 9,608,363 |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | 6,392,476 | 5,322,826 | 7,321,651 | 7,682,690 |

## អនុបាតសំខាន់ៗ

| | 2010 | 2009 | 2008 | 2007 |
|---|---|---|---|---|
| ផលចំណេញពីមូលធន | 17.88% | 40.94% | 56.32% | 59.10% |
| ផលចំណេញពីទ្រព្យសកម្ម | 1.94% | 1.96% | 2.79% | 3.49% |
| ផលចំណេញពីមូលនិធិភាគទុនិក | 13.41% | 12.90% | 20.35% | 26.80% |
| អនុបាតសាធនភាព | 27.27% | 32.02% | 28.28% | 31.46% |
| អនុបាតសាច់ប្រាក់ងាយស្រួល | 104.05% | 111.46% | 111.81% | 147.45% |
| ចំណូលការប្រាក់ធៀបនឹងទ្រព្យសកម្មសរុប | 3.98% | 4.83% | 4.80% | 5.61% |
| ឥណទានដុលធៀបនឹងប្រាក់បញ្ញើអតិថិជន | 51.24% | 41.33% | 44.06% | 37.11% |
| អត្រាកំណើនចំណូលការប្រាក់ | 4.57% | 4.01% | 2.17% | 35.02% |
| អត្រាកំណើនប្រាក់បញ្ញើអតិថិជនសរុប | 22.41% | 1.49% | 18.51% | -4.11% |
| អត្រាកំណើនឥណទានដុលសរុប | 34.95% | 7.06% | 40.71% | 40.58% |
| អត្រាកំណើនមូលនិធិភាគទុនិក | 15.49% | 14.68% | 25.54% | 36.62% |
| អត្រាកំណើនទ្រព្យសកម្មសរុប | 21.16% | 3.45% | 19.41% | 0.52% |

# លទ្ធផលអនុវត្តអាជីវកម្ម

## ចំណូលបានពីការប្រាក់ (ដុល្លារអាមេរិក)




## សង្ខេបរបាយការណ៍ចំណេញខាត (ដុល្លារអាមេរិក)




## សង្ខេបរបាយការណ៍តារាងតុល្យការ (ដុល្លារអាមេរិក)





# សាររបស់លោកឧកញ៉ាប្រធាន ក្រុមប្រឹក្សាភិបាល

សម្តេច ទ្រង់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីរាប់អាន!

តាងនាមអោយក្រុមប្រឹក្សាភិបាលនៃធនាគារពាណិជកម្មក្រៅប្រទេស នៃកម្ពុជា យើងខ្ញុំមានកិត្តិយស បង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ សំរាប់ឆ្នាំសារពើពន្ធដែលបានបញ្ចប់ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១០ កន្លងទៅនេះ ។

បន្ទាប់ពីការធ្វើឯកជនភាវូបនីយកម្មក្នុងឆ្នាំ ២00៥ មក សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ មានភាពមមាញឹកយ៉ាងខ្លាំង ក្នុងការរិះរកយុទ្ធសាស្រ្តផ្សេងៗដើម្បីពង្រឹងវប្បធម៌ជាមូលដ្ឋានគ្រឹះ និងវត្តមានធនាគារយើង នៅចំពោះមុខបរិយាកាសធុរកិច្ច ដែលមានការប្រកួតប្រជែងកាន់តែខ្លាំងក្លានេះ ។ ការខិតខំប្រឹងប្រែងឥតសំចៃរបស់ថ្នាក់ដឹកនាំ ព្រមទាំងបុគ្គលិកទាំងអស់ បានធ្វើអោយធនាគារ ទទួលបានផលចំណេញជាទីគាប់ចិត្ត លើសពីការរំពឹងទុករបស់ភាគទុនិក ទោះបីជាវិបត្តិសេដ្ឋកិច្ចពិភពលោកបានបន្សល់ផលប៉ះពាល់បន្តិច បន្តួចមកលើសេដ្ឋកិច្ចប្រទេសយើងក៏ដោយ ។

ឆ្លៀតឱកាសនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយនឹងជំរាបជូនថា ធនាគារពាណិជកម្មក្រៅប្រទេស នៃកម្ពុជា ទទួលបាលលទ្ធផលជាវិជ្ជមានលើគ្រប់អនុបាតសំខាន់ៗទាំងអស់ ។ ការអនុវត្តនីគោលការណ៍គ្រប់គ្រងចំណាយនៅអំឡុងឆ្នាំ ២០១០ ព្រមទាំងការពង្រីកមូលដ្ឋានអតិថិជន និងការគ្រប់គ្រងដោយប្រសិទ្ធិភាព និងប្រុងប្រយ័ត្ននូវដើមទុនទាំងឡាយ បានធ្វើអោយធនាគារទទួលបាននូវកំនើនគួរអោយកត់សំគាល់ ដែលធ្វើអោយប្រាក់ចំនេញក្រោយបង់ពន្ធកើនរហូតដល់ទៅ ២0%  គិតជាទឹកប្រាក់មានចំនួនដល់ ៦.៣ លានដុល្លារសហរដ្ឋអាមេរិក ។

នៅក្នុងឆ្នាំ ២០១០ ធនាគារបានបង្កើនដើមទុនដើម្បីអោយស្របទៅនឹងប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ។ ដើមទុនទាំងនេះត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាព ដោយធ្វើអោយយើងមានលទ្ធភាព បើកសាខាពីរបន្ថែមទៀតនៅក្នុងទីតាំងយុទ្ធសាស្រ្ត គឺក្រុងព្រះសីហនុ និងតំបន់ផ្សារអូឡាំពិក ។

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា បាននឹងកំពុងនាំមុខគេ បើនិយាយពីការផ្តល់ជូននូវផលិតផល និងសេវាធនាគារ ដែលប្រកបដោយភាពច្នៃប្រឌិតខ្ពស់ ។ យើងបានពង្រីកសេវាទូទាត់ផ្សេងៗ តាមរយៈសេវាធនាគារតាមអ៊ីនធើណិត ។ ឥឡូវនេះ អតិថិជនរបស់យើងអាចធ្វើការបង់វិក្កយបត្ររដ្ឋាករទឹក និងអគ្គិសនីកម្ពុជាតាមប្រព័ន្ធអេឡិចត្រូនិច ។ មិនត្រឹមតែប៉ុណ្ណោះ យើងបានណែនាំផលិតផលគួរជាទីមោទនៈមួយទៀតគឺ ប្រភេទប័ណ្ណ FTB Visa CashCard ដំបូងបង្អស់នៅកម្ពុជា ហើយយើងសង្ឃឹមថាផលិផលថ្មីនេះនឹងពង្រីកតំរូវការទូទាត់ប្រាក់តាមរយៈប័ណ្ណនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខ ។

ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកធនាគារ នឹងខិតខំប្រឹងប្រែងជានិច្ច ដើម្បីកសាងទំនុកចិត្តជូនភ្ញៀវដ៏ថ្លៃថ្លាទាំងអស់ នៅក្នុងការសំរបខ្លួនដោយជោគជ័យទៅនឹង បរិយាកាសធុរកិច្ចនៅក្នុងប្រទេសកម្ពុជា ។ ការជ្រៀតចូលទៅក្នុងទីផ្សារអន្តរជាតិ រួមនឹងការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា បានធ្វើអោយវិស័យកសិកម្មទទួលបានការចាប់អារម្មណ៍ខ្ពស់ ហើយនេះគឺជាវិស័យអាទិភាពរបស់ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជាដែរ ។

ផែនការពង្រីកបន្ថែមនូវចំនួនសាខា នឹងធ្វើឡើងជាបន្តបន្ទាប់នៅតាមមជ្ឈមណ្ឌលពាណិជ្ជកម្មធំៗ ដូចជា សៀមរាប បាត់ដំបង និងកំពង់ផែរាជធានីភ្នំពេញ។ យើងនឹងបន្តបង្កើតផលិតផល និងសេវាផ្សេងដ៏ទៃទៀតដើម្បីរក្សាស្ថានភាពឈានមុខគេ និងការអភិវឌ្ឍន៍ជាប្រចាំរបស់ធនាគារ។

ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល យើងបានជំនះវិបត្តិសេដ្ឋកិច្ច ដោយសារស្ថានភាពរឹងមាំរបស់យើង សក្តិសមនឹង កិត្តិនាមថាជាដៃគូពាណិជ្ជកម្មដែលមានទាំងសុវត្ថិភាព មានទាំងទំនុកចិត្តពីអតិថិជន។ យើងមានសុទិដ្ឋិនិយមយ៉ាងខ្លាំង ចំពោះការអភិវឌ្ឍន៍នៅក្នុងឆ្នាំ ២០១១ និងនាពេលអនាគតរបស់ធនាគារពាណិជ្ជកម្ម ក្រៅប្រទេស នៃកម្ពុជា។

ឆ្លៀតឱកាសនេះ ខ្ញុំសូមសំដែងការកោតសរសើរចំពោះឯកឧត្តម ហ៊ី អានវ៉ានិថ ដែលបានដឹកនាំធនាគារប្រកបដោយភាពច្បាស់លាស់ និងការប្តេជ្ញាចិត្តខ្ពស់។ គួរបញ្ជាក់ផងដែរថា ឯកឧត្តម ហ៊ី អានវ៉ានិថ គឺជាជ័យលាភីរង្វាន់ CIO Award អន្តរជាតិ ពី International Data Group (IDG ASEAN)។ ហើយខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំ និងបុគ្គលិកធនាគារទាំងអស់ ដែលបានខិតខំប្រឹងប្រែងអស់លទ្ធភាព ព្រមទាំងអតិថជនដ៏ថ្លៃថ្លារបស់យើង ដែលបានបន្តការគាំទ្រ និងផ្តល់ទំនុកចិត្តចំពោះធនាគារ។ ខ្ញុំសូមថ្វាយព្រះពរ និងជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ជួបប្រទះតែនឹងជោគជ័យគ្រប់ប្រការ។



ឧកញ៉ា ពុង ឃាវសែ
ប្រធានក្រុមប្រឹក្សាភិបាល



# សាររបស់អគ្គនាយក

អស់រយៈពេលជាង ៣០ឆ្នាំកន្លងមកនេះ ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា មានមោទនភាពយ៉ាងខ្លាំងដែលបានបំរើអតិជនរបស់យើង ដោយជោគជ័យ ។ នៅឆ្នាំ ២០១០ នេះ យើងបានធ្វើការណែនាំផលិតផល និងសេវាថ្មីៗ ទៅកាន់ទីផ្សារ និងបើកសាខាពីរបន្ថែមទៀត ដើម្បីបង្កភាពងាយស្រួលដល់អតិថិជនរបស់យើង ។ កំនើនប្រាក់បញ្ញើ និងឥណទាន បានចូលរួមចំណែកពង្រឹងគុណភាពទ្រព្យសកម្ម អោយកាន់តែប្រសើរឡើង ។ ជាងនេះទៅទៀត ការអនុវត្តន៏គោលនយោបាយគ្រប់គ្រងចំណាយ បានធ្វើអោយប្រាក់ចំណេញក្រោយបង់ពន្ធកើនឡើងរហូតដល់ ៦.៣ លានដុល្លារ ។

ឆ្នាំ ២០១០ គឺជាឆ្នាំនៃភាពច្នៃប្រឌិត និងការបង្កើនចំនួនសាខាសំរាប់ធនាគាររបស់យើង ។ ទន្ទឹមនឹងការប្រកួតប្រជែងដ៏ស្វិតស្វាញ នៅតាមបណ្តាស្ថាប័នហិរញ្ញវត្ថុនានា យើងបានសំរេចគោលដៅដែលបានគ្រោងទុកដូចខាងក្រោម:

- ឥណទានដុល និងបុរេប្រទានអតិថិជនកើនចំនួន ៣៥% គិតជាទឹកប្រាក់ ១៤១.៩១ លានដុល្លារអាមេរិក
- ប្រាក់បញ្ញើកើនជាង ២២% គិតជាទឹកប្រាក់ ២៧៦.៩៣ លានដុល្លារអាមេរិក
- ទ្រព្យសកម្មសរុបកើនឡើងចំនួន ២១% គិតជាទឹកប្រាក់ជាង ៣២៩ លានដុល្លារអាមេរិក
- ប្រាក់ចំណេញក្រោយបង់ពន្ធចំនួនជាង ៦.៣ លានដុល្លារអាមេរិក
- គុណភាពតម្លៃទ្រព្យសកម្មកើនឡើង ដោយកាត់បន្ថយឥណទានសង្ស័យ និងអាក្រក់មកត្រឹម ២.៩៦%

ការខិតខំប្រឹងប្រែងក្នុងការស្វែងយល់ពីតម្រូវការអតិថិជន ការកសាងទំនាក់ទំនងរយៈពេលវែង និងការផ្តល់នូវសេវាដែលសមស្របនឹងតម្រូវការអតិថិជន គឺជាគន្លឹះនៃជោគជ័យរបស់យើង ។
ខាងក្រោមនេះ គឺជាលទ្ធផលគួរជាទីមោទនៈរបស់យើង:

- ការបើកសម្ពោធសាខានៅក្នុងតំបន់យុទ្ធសាស្ត្រពីរទៀតគឺ ក្រុងព្រះសីហនុ និងតំបន់ផ្សារអូឡាំពិក ។ សាខាក្រុងព្រះសីហនុ ត្រូវបានបើកសម្ពោធនៅក្នុងខែមិនា សាខានេះមានទីតាំងនៅក្នុងកំពង់ផែស្វយ័តក្រុងព្រះសីហនុដែលជាមជ្ឈមណ្ឌលប្រមូលផ្តុំសេវាផ្នែកគយនិងរដ្ឋាករ ព្រមទាំងចរាចរណ៍ទំនិញរបស់ក្រុមហ៊ុនដឹកជញ្ជូននានា ។ ទីតាំងនៅក្នុងបេះដូងសេដ្ឋកិច្ចដ៏សំខាន់របស់ប្រទេសនេះ នឹងសម្រួលដំណើរការលើកដាក់ និងទទួលទំនិញដោយឆាប់រហ័ស ។ ចំណែកសាខាផ្សារអូឡាំពិកវិញ ត្រូវបានបើកសម្ពោធនៅក្នុងខែធ្នូ ដើម្បីបំរើសេវាហិរញ្ញវត្ថុដល់អតិថិជនបោះដុំ នៅក្នុងតំបន់ពាណិជ្ជកម្មដ៏មមាញឹកនេះ ព្រមទាំងសម្រួលដល់សេចក្តីត្រូវការហិរញ្ញប្បទានរបស់សហគ្រាសធុនតូច និងមធ្យមដែលស្ថិតនៅជុំវិញផង ។
- ការដាក់អោយប្រើប្រាស់សេវាទូទាត់វិក្កយបត្ររដ្ឋាករទឹក និងអគ្គិសនីកម្ពុជាតាមរយៈអ៊ីនធើណិត
- ការណែនាំផលិតផលថ្មីគឺ FTB Visa CashCard ដំបូងបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ នេះគឺសមិទ្ធិផលនាំមុខគេមួយទៀតដែលធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ផ្តល់ជូនអតិថិជនយុវវ័យ ពាណិជ្ជករអន្តរជាតិ និងអ្នកដំណើរកំសាន្តក្រៅប្រទេស ដែលធ្លាប់តែជួបនូវការលំបាកក្នុងការទទួលបានសេវាពីបណ្ណវីសា ។

នៅក្នុងឆ្នាំ ២០១០ និងដើមឆ្នាំ ២០១១ យើងបាននឹងកំពុងផ្តោតលើគោលដៅដូចខាងក្រោម:

- បើកសាខាថ្មីជាបន្តបន្ទាប់នៅក្នុងតំបន់យុទ្ធសាស្ត្រផ្សេងទៀតដូចជា សៀមរាប បាត់ដំបង និងកំពង់ផែរាជធានីភ្នំពេញដើម្បីសម្រួលធុរកិច្ចរបស់អតិថិជនដ៏ថ្លៃថ្លារបស់យើង ។

- បង្កើតកម្មវិធីពិសេសៗផ្សេងៗ និងបង្កើនបណ្តាញបែងចែក ដើម្បីពង្រឹងវត្តមានរបស់ធនាគារលើទីផ្សារ
- ប្រើប្រាស់យុទ្ធសាស្ត្រផ្សេងៗ ក្នុងការកំណត់តម្លៃអោយសមស្របទៅនឹងទីផ្សារដែលមានការប្រកួតប្រជែងខ្ពស់
- រក្សា និងបង្កើនទំនាក់ទំនងរយៈពេលវែងជាមួយអតិថិជនរបស់ខ្លួន
- ប្រើប្រាស់មូលធនអោយបានល្អបំផុតដើម្បីធ្វើអោយលទ្ធភាពចំណេញមានជាអតិបរមា
- បន្តការបំពាក់បំប៉នដល់បុគ្គលិកធនាគារ ដើម្បីប្រាកដថាយើងមានធនធានមនុស្សដែលមានសមត្ថភាពខ្ពស់ ប្រកបដោយចិរភាព សមស្របនឹងការប្រឈមនិងកាលានុវត្តនាអនាគតកាល
- គាំទ្រដល់ការអភិវឌ្ឍន៍ប្រទេសជាតិរយៈពេលយូរអង្វែង ដោយអនុវត្តនយោបាយកំចីដែលមានទំនួលខុសត្រូវ
- អភិវឌ្ឍធុរកិច្ចក្នុងវិស័យកសិកម្ម ព្រោះថា វិស័យនេះនឹងផ្តល់នូវកំណើនប្រកបដោយចិរភាព ដើម្បីឈានចូលទីផ្សារអន្តរជាតិដោយជោគជ័យ ជាមួយនឹងការគាំទ្រដ៏ខ្លាំងក្លាពីសំណាក់រាជរដ្ឋាភិបាល ។

សេដ្ឋកិច្ចជាតិទាំងមូលនឹងបន្តការរីកចំរើនទៅមុខឥតឈប់ឈរ ហើយយើងសំឡឹងមើលទៅអនាគតប្រកបដោយជំនឿទុកចិត្តយ៉ាងមុតមាំ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ភាគទុនិក និងក្រុមប្រឹក្សាភិបាល ដែលបានផ្តល់ការគាំទ្រដល់យើងខ្ញុំ ។ ហើយខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់ ដែលបានខិតខំប្រឹងប្រែងរហូតមក ។ ការប្តេជ្ញាចិត្ត និងវិជ្ជាជីវៈរបស់អ្នកទាំងអស់គ្នា បានជំរុញអោយធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា នៅតែជាស្ថាប័នជាទីទុកចិត្ត និងប្រកបដោយជោគជ័យរហូតមកដល់ថ្ងៃនេះ ។ ខ្ញុំក៏សូមកោតសរសើរចំពោះអតិថិជន របស់យើងដែលតែងតែបន្តការគាំទ្រប្រកបដោយទំនុកចិត្ត ចំពោះធនាគារយើងខ្ញុំ ។ យើងសង្ឃឹមថា នឹងបានបំរើសម្តេច ទ្រង់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជារៀងរហូតតទៅ ។

សូមអរគុណ



ឯឧត្តម ហ្គី អានវ៉ានិថ
អគ្គនាយក

# ក្រុមប្រឹក្សាភិបាល

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ដឹកនាំដោយ ក្រុមប្រឹក្សាភិបាលដែលជា អង្គការចាត់តាំងកំពូល តំណាងមហាសន្និបាតភាគទុនិក បង្កើតជាតំណាងមហាសន្និបាតសាមញ្ញ និងវិសាមញ្ញ ។

ក្រុមប្រឹក្សាភិបាល ធនាគារមានសមាជិក ៨រូប ដូចមានរាយនាមខាងក្រោម:

| | | |
|---|---|---|
| ឧកញ៉ា ពុង ឃាវសែ | ប្រធានក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៥ |
| ឧកញ៉ា លឹម ប៊ុនសួរ | សមាជិកក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៥ |
| ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាង កសហ | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០២ |
| ឯកឧត្តម ហ៊្គី អានវ៉ានិថ | សមាជិកក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៥ |
| លោកជំទាវ អ៊ឹង ប៉ូលីណា | សមាជិកក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៥ |
| លោកស្រី សុខ ចាន់សូណា | សមាជិកក្រុមប្រឹក្សាភិបាល - ឯករាជ | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៧ |
| លោក កង អ៊ី | សមាជិកក្រុមប្រឹក្សាភិបាល - ឯករាជ | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៨ |
| លោក នួន សំអ៊ាន | សមាជិកក្រុមប្រឹក្សាភិបាល - ឯករាជ | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៩ |

## គណៈគ្រប់គ្រង

គណៈគ្រប់គ្រងធនាគារមានតួនាទីទទួលខុសត្រូវ គ្រប់គ្រងប្រតិបត្តិការអាជីវកម្មធនាគារទាំងមូល ។

គណៈគ្រប់គ្រងធនាគារមានចំនួន០៤រូប:

| | |
|---|---|
| ឯកឧត្តម ហ៊្គី អានវ៉ានិថ | អគ្គនាយក |
| លោកជំទាវ អ៊ឹង ប៉ូលីណា | អគ្គនាយករង |
| លោក ទឹម បូផល | អគ្គនាយករង |
| លោកស្រី នួន បូរ៉ានី | អគ្គនាយករង |

## គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម (ALCO)

គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម មានសមាជិកចំនួន០៨រូប

| | | |
|---|---|---|
| ឯកឧត្តម ហ៊្គី អានវ៉ានិថ | សមាជិកក្រុមប្រឹក្សាភិបាល | ប្រធាន |
| លោកជំទាវ អ៊ឹង ប៉ូលីណា | សមាជិកក្រុមប្រឹក្សាភិបាល | សមាជិក |
| លោក ទឹម បូផល | អគ្គនាយករង | សមាជិក |
| លោកស្រី នួន បូរ៉ានី | អគ្គនាយករង | សមាជិក |
| ប្រធាននាយកដ្ឋានអន្តរជាតិ | | សមាជិក |
| ប្រធាននាយកដ្ឋានសេវាអតិថិជន | | សមាជិក |
| ប្រធាននាយកដ្ឋានគណនេយ្យ | | សមាជិក |
| ប្រធាននាយកដ្ឋានឥណទាន | | សមាជិក |

## គណៈកម្មការសវនកម្ម

គណៈកម្មការនេះមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| លោក នួន សំអ៊ាន | សមាជិកក្រុមប្រឹក្សាភិបាលឯករាជ | ប្រធាន |
| លោកស្រី សុខ ចាន់សូណា | សមាជិកក្រុមប្រឹក្សាភិបាលឯករាជ | សមាជិក |
| លោក ទ្រី ចន្ទី | ប្រធានសវនកម្មផ្ទៃក្នុង | លេខាធិការ |

## គណៈកម្មការឥណទានធនាគារ

សមាសភាពគណៈកម្មការ ផ្នែកឥណទានមានដូចតទៅ:

| | | |
|---|---|---|
| ឧកញ៉ា លឹម ប៊ុនសួរ | សមាជិកក្រុមប្រឹក្សាភិបាល | ប្រធាន |
| ឯកឧត្តម ហ៊្គី អានវ៉ានិថ | អគ្គនាយក | សមាជិក |
| លោកជំទាវ អ៊ឹង ប៉ូលីណា | អគ្គនាយករង | សមាជិក |
| លោក ទឹម បូផល | អគ្គនាយករង | សមាជិក |

# សមាជិកក្រុមប្រឹក្សាភិបាល



ឧកញ៉ា ពុងឃាវសែ
ប្រធានក្រុមប្រឹក្សាភិបាល



ឧកញ៉ា លឹម ប៊ុនសួរ
សមាជិកក្រុមប្រឹក្សាភិបាល



ឯកឧត្តម ម៉ី វ៉ាន់
សមាជិកក្រុមប្រឹក្សាភិបាល



ឯកឧត្តម ហ្គី អានវ៉ានិថ
អគ្គនាយក



លោកជំទាវ អ៊ឹង ប៉ូលីណា
អគ្គនាយករង



លោកស្រី សុខចាន់សូណា
សមាជិកក្រុមប្រឹក្សាភិបាល



លោក កង អ៊ី
សមាជិកក្រុមប្រឹក្សាភិបាល



លោក ទួន សំអ៊ាន
សមាជិកក្រុមប្រឹក្សាភិបាល

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## សវនកម្មផ្ទៃក្នុង

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា បានរៀបចំនាយកដ្ឋានសវនកម្មផ្ទៃក្នុងដែលមានបេសកកម្មចំបងធ្វើជាជំនួយការរបស់ក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យបណ្តានាយកដ្ឋាននានារបស់ធនាគារ តាមរយៈការវាយតម្លៃ និងការត្រួតពិនិត្យជាទៀងទាត់ទៅតាមកម្មវិធីសវនកម្ម ដើម្បីធានាថាត្រឹមត្រូវទៅតាមគោលការណ៍តម្លាភាព អភិបាលកិច្ចល្អ និងភាពជាអាជីព ព្រមទាំងផ្តល់អនុសាសន៍កែលំអផង។

## ការគ្រប់គ្រងហានិភ័យ

គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម (អាល់កូ) របស់ធនាគារ ទទួលខុសត្រូវគ្រប់គ្រងហានិភ័យធនាគារ រាយការណ៍អំពីហានិភ័យធំៗ និងធានាថាធនាគារគោរពតាមបទបញ្ញត្តិផ្ទៃក្នុងធនាគារ ព្រមទាំងសេចក្តីតម្រូវរបស់ធនាគារជាតិ នៃកម្ពុជា ជាពិសេសអ្វីដែលទាក់ទងទៅនឹងសាធនភាព និងសាច់ប្រាក់ងាយស្រួល។ គណៈកម្មការនេះទទួលខុសត្រូវធានាថា ត្រួតពិនិត្យ និងវិភាគជាប្រចាំលើបរិស្ថានធុរកិច្ច ដើម្បីធ្វើការកែប្រែចាំបាច់ ទាន់ពេលនូវគោលនយោបាយ ឬនីតិវិធីគ្រប់គ្រងហានិភ័យរបស់ធនាគារ ប្រកបដោយសុក្រិតភាព។ បន្ទាប់ពីសម្រួលអោយបានរលូននូវនីតិវិធីគ្រប់គ្រងហានិភ័យ នៅឆ្នាំ ២០០៧ ថ្នាក់ដឹកនាំជាន់ខ្ពស់បានប្រមូលផ្តុំការយកចិត្តទុកដាក់លើការអនុវត្តន៍ និងការវាយតម្លៃលើនីតិវិធីសម្រួលថ្មីនេះ ដែលរួមមាន:

- ការពិនិត្យឡើងវិញរបាយការណ៍សាច់ប្រាក់ងាយស្រួលជាប្រចាំថ្ងៃ ដើម្បីធានាការត្រួតពិនិត្យឱ្យបានរឹងរិតតែម៉ឺងម៉ាត់ឡើង។
- ការរៀបចំផែនការរឹងមាំ សំរាប់ទប់ទល់ព្រឹត្តិការណ៍ ជាយថាហេតុនៃការខ្វះសាច់ប្រាក់ងាយស្រួល។
- ការរក្សាទុកជាប្រចាំនូវលំហូរសាច់ប្រាក់ងាយស្រួលឱ្យបានច្រើន និងការអនុវត្តន៍ តាមប្រកាសលេខ ធ.០៧.០០.៣៨ របស់ ធនាគារជាតិ នៃកម្ពុជា។
- ការកែលំអជាប្រចាំនូវគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យ អត្រាការប្រាក់តាមរយៈការវិភាគ Gap Analysis ។
- ការកំណត់ព្រំដែនសកម្មភាពប្តូរប្រាក់ និងការដាក់អនុវត្តនូវនីតិវិធីបង្ការភាពមិនស៊ីគ្នារវាងរូបិយប័ណ្ណនីមួយៗ ដែលទ្រព្យសកម្ម និងអកម្ម ត្រូវបានចុះបញ្ជី។
- ការរៀបចំរបៀបរាយការណ៍ប្រកបដោយតម្លាភាពទៅកាន់ និងចេញពីនាយកដ្ឋាន នីមួយៗរួមមានចេញពីផ្នែកសវនកម្មផ្ទៃក្នុងជូនទៅក្រុមប្រឹក្សាភិបាល។
- អនុវត្តគោលនយោបាយ និងនីតិវិធីសវនកម្មផ្ទៃក្នុងដែលស្របទៅនឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។
- ចែកចាយសៀវភៅណែនាំផ្ទៃក្នុងមួយសំរាប់បុគ្គលិកធនាគារប្រើប្រាស់ជាមគ្គុទេសន៍នៅក្នុងការអនុវត្តន៍កិច្ចការប្រចាំថ្ងៃ។
- អនុវត្តនូវកម្មវិធីបណ្តុះបណ្តាលទូលំទូលាយដើម្បីបុគ្គលិកអភិវឌ្ឍសមត្ថភាពគ្រប់គ្រងហានិភ័យរបស់ខ្លួន។

## ការប្រែប្រួលសំខាន់ៗនៅក្នុងឆ្នាំ

ឆ្នាំ២០១០ ជាឆ្នាំមមាញឹកជាងគេសំរាប់ធនាគារ។ យើងបានសម្រេចលទ្ធផលអនុវត្តការងារ ហួសពីការរំពឹងទុករបស់ភាគទុនិក នៅអំឡុងការិយបរិច្ឆេទនេះ។ ជោគជ័យទាំងនេះរួមមាន :

- ប្រាក់ចំណេញក្រោយបង់ពន្ធប្រមាណជាង ៦.៣ លានដុល្លារអាមេរិក
- ផលចំណេញពីមូលនិធិភាគទុនិកបានកើនឡើង ១៥.៥%   គិតជាទឹកប្រាក់ ៤៧.៧លានដុល្លារអាមេរិក

- ឥណទាន និងបុរេប្រទានដុលទៅអតិថិជនបានកើនឡើងជាង ៣៥%  គិតជាទឹកប្រាក់ ១៤១.៩១ លានដុល្លារអាមេរិក
- ទ្រព្យសកម្មសរុបកើនឡើង ២១.១៦% គិតជាទឹកប្រាក់ ២២៩.២៧លានដុល្លារអាមេរិក
- ប្រាក់បញ្ញើកើនឡើង ២២.៤១% គិតជាទឹកប្រាក់ ២៧៦.៩៣លានដុល្លារអាមេរិក
- គុណភាពទ្រព្យសកម្មមានការកើនឡើង គឺឥណទានមិនដំណើរការបានថយចុះមកនៅត្រឹម ២.៩៦%
- ដើមទុនបានកើនដល់ ៣៥.៧៥លានដុល្លារអាមេរិក ។

## ការប្តេជ្ញាចិត្ត របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការអភិវឌ្ឍន៍ផលិតផល និងសេវាថ្មីផ្សេងទៀតដើម្បីរក្សាជំហរ និងវត្តមានរបស់ធនាគារ និងបន្តពង្រឹងស្ថានភាពរឹងមាំរបស់ខ្លួនអោយរឹងរឹតតែប្រសើរឡើងទៀត នៅក្នុងវិស័យហិរញ្ញវត្ថុប្រទេសកម្ពុជា ។ យើងបានទទួលជោគជ័យធំៗដូចខាងក្រោម៖

- បើកសាខា ២បន្ថែមទៀត៖ មួយនៅក្រុងព្រះសីហនុ ដើម្បីឆ្លើយតបទៅនឹងតំរូវការអតិថិជន ប្រកបដោយភាពរហ័សរហួន និងងាយស្រួលជាងមុន និងសាខាមួយទៀតស្ថិតនៅតំបន់ផ្សារអូឡាំពិក ដើម្បីពង្រឹងវត្តមានធនាគារក្នុងចំណោមសហគ្រាសធុនតូច និងមធ្យមក្នុងតំបន់ផ្សារនោះ ។
- បង្កើតអោយមានការទូទាត់វិក្កយបត្ររដ្ឋាករទឹកតាមប្រព័ន្ធអ៊ីនធើណិត ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន និងពង្រីកសេវាធនាគារតាមអ៊ិនធើណិត ។
- កែលំអការិយាល័យកណ្តាល ដើម្បីអោយស្របតាមការកើនឡើងនៃតំរូវការអតិថិជន ។
- ណែនាំផលិតផលថ្មីគឺ FTB Visa CashCard ដំបូងបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រីកការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច ។
- កែលំអប្រព័ន្ធសវនកម្មផ្ទៃក្នុង ដើម្បីអោយស្របតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ។

## ពានរង្វាន់ ទទួលបាន៖

ក្នុងឆ្នាំ ២០១០ ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ទទួលបានពានរង្វាន់ធំចំនួន ២គឺ៖


HSBC Global Payments and Cash Management
2010 Golden Award

FOREIGN TRADE BANK OF CAMBODIA

HSBC

- ពានរង្វាន់ HSBC Global and Cash Management គឺជាការទទួលស្គាល់ និងកោតសរសើរពីធនាគារ HSBC ចំពោះការសហការប្រកបដោយទំនុកចិត្ត និងមានប្រសិទ្ធិភាព



- ពានរង្វាន់ CIO ASEAN ត្រូវបានប្រគល់ជូន អគ្គនាយករបស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា គឺ ឯកឧត្តម ហ៊ី អានវ៉ានិថ ដែលបានទទួលជោគជ័យក្នុងការដាក់ម៉ាស៊ីន ATM ប្រើក្រយៅដៃ និងមានការណែនាំដោយសម្លេងឱ្យដំណើរការ ។

## ក្រមសីលធម៌

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជាជាស្ថាប័នមួយដែលមានការទទួលស្គាល់ច្រើននៅក្នុងសហគមន៍ ។  ដើម្បីធានាថាយើងរក្សាកេរ្តិ៍ឈ្មោះដ៏ល្អនេះបាន ធនាគារនឹងបង្ហាញនូវកំរិតខ្ពស់បំផុត នៃសីលធម៌ សង្គមធម៌ ចរិយាធម៌ នៅគ្រប់ពេលទាំងអស់ ។

ដើម្បីជួយអោយបុគ្គលិកផ្សារភ្ជាប់ទៅនឹងគោលការណ៍ទាំងនេះនៅក្នុងការងារប្រចាំថ្ងៃរបស់ខ្លួន ធនាគារបានរៀបចំគោលនយោបាយ និងនីតិវិធីអនុវត្តការងារដ៏ល្អបំផុត ជាលាយលក្ខអក្សរ សំរាប់អោយបុគ្គលិកអនុវត្តតាម ។ នីតិវិធីទាំងនេះគូសបញ្ជាក់ពីការអនុវត្តន៍ការងារត្រឹមត្រូវ តាមបទបញ្ជានិងក្រមសីលធម៌របស់ធនាគារ ។ សៀវភៅទាំងនេះជាឯកសារបន្ថែមសំរាប់បណ្តុះបណ្តាលរបស់បុគ្គលិក ។

## អតិថិជន

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ខិតខំផ្តល់ការប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីផ្តល់សេវាជាទីទុកចិត្ត និងប្រកបដោយប្រសិទ្ធិភាពជូនទៅអតិថិជនរបស់យើងនៅគ្រប់ពេលវេលា ។ ទោះបីជាយ៉ាងនេះក្តី ក៏យើងតែងតែទទួលស្គាល់ថា នៅមានការខ្វះចន្លោះ ដូច្នេះហើយទើបយើងខ្ញុំតែងតែស្វាគមន៍ចំពោះការវាយតំលៃ និងមតិយោបល់កែលំអពីសំណាក់អតិថិជនរបស់យើងជានិច្ច ។ យើងប្តេជ្ញាធ្វើការវាយតម្លៃ និងធ្វើការលើមតិយោបល់ទាំងនេះអោយអស់ពីលទ្ធភាព ។

## ឯករាជ្យភាព និងតម្លាភាព

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ជាស្ថាប័នមានឯករាជ្យភាពពេញលេញ ។ ធនាគារបំពេញការងារ ជាធនាគារពាណិជ្ជមួយ ហើយក្នុងនាមជាធនាគារពាណិជ្ជ សកម្មភាពអាជីវកម្មរបស់ខ្លួន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យប្រចាំគ្រាដល់ទីកន្លែង និងលើឯកសារពីធនាគារជាតិ នៃកម្ពុជា ។ ដើម្បីធានាតម្លាភាពប្រតិបត្តិការ ធនាគារត្រូវបានត្រួតពិនិត្យពីសំណាក់សវនកម្មផ្ទៃក្នុងរបស់ខ្លួនផ្ទាល់ ។ ជាបន្ថែមទៀត ធនាគារទទួលការត្រួតពិនិត្យពីធនាគារជាតិនៃកម្ពុជា ដែលជាអាជ្ញាធររូបិយវត្ថុជាតិសំរាប់ធនាគារពាណិជ្ជទាំងអស់ ។ ទោះបីមានការត្រួតពិនិត្យជាប្រចាំយ៉ាងនេះទៅហើយក្តី ក៏ធនាគារជាកម្មវត្ថុនៃការស្រាវជ្រាវពិនិត្យប្រចាំឆ្នាំពីសំណាក់សវនករឯករាជ្យ ។ សវនករឯករាជ្យនេះ ត្រួតពិនិត្យរាល់ទិដ្ឋភាពហិរញ្ញវត្ថុនៃប្រតិបត្តិការទាំងអស់ ផ្តល់របាយការណ៍បញ្ជាក់អំពីការរកឃើញរបស់ពួកគេ និងធ្វើការបញ្ជាក់លើគណនីរបស់យើងថា បានគោរពទៅតាមតម្រូវការនៃច្បាប់ទាំងអស់ ។

## បុគ្គលិក

ដើម្បីក្លាយជាធនាគារជួរមុខគេនៅកម្ពុជា ក្រុមប្រឹក្សាភិបាល និងភាគទុនិកយល់ថា ការជ្រើសរើសនិងការរក្សាទុកបុគ្គលិកដែលមានគុណភាពថ្នាក់កំពូល យោលទៅលើចំណេះដឹង ជំនាញ ឯកទេសនិងការលើកទឹកចិត្ត ជាអាទិភាពចំបង ។ បៀវត្ស រង្វាន់ និងការអភិវឌ្ឍន៍បុគ្គលិក ដើរតួនាទីយ៉ាងសំខាន់នៅក្នុងសមត្ថភាពរបស់យើង ដើម្បីសម្រេចគោលដៅនេះ ។ បុគ្គលិកទាំងអស់តែងតែបានទទួលការបណ្តុះបណ្តាលនៅក្នុងធនាគារ ឬនៅក្រៅប្រទេស នៅអំឡុងការិយបរិច្ឆេទ ហើយយើងសង្ឃឹមថា នឹងបានធនធានមនុស្សមានជំនាញចំរុះ មានសមត្ថភាពឆ្លើយតបដោយប្រសិទ្ធិភាព ទៅនឹងការផ្លាស់ប្តូរដែលវិស័យឧស្សាហកម្មធនាគារ នៅកម្ពុជាកំពុងប្រឈម ។



## ការចូលរួមវិភាគទានដល់សង្គម និងសហគមន៍

ដូចពីមុនមកដែរ ធនាគារបន្តការចូលរួមចំណែកជួយសហគមន៍ និងបុព្វហេតុសង្គមនៅក្នុងឆ្នាំ ២០១០ ។ យើងយកចិត្តទុកដាក់ជាសំខាន់ទៅលើកាកបាទក្រហមកម្ពុជា តែយើងក៏បានចូលរួមសកម្មភាពអង្គការសប្បុរសធម៌ផ្សេងៗ តូចជាងនេះដែរ ព្រមទាំងបានផ្តល់មូលនិធិដល់ពិធីបុណ្យប្រពៃណីជាតិ និងឧបត្ថម្ភទូកប្រណាំងមួយក្រុម នៅក្នុងពិធីបុណ្យអុំទូកផង ។

## ការអនុវត្តន៍ស្របទៅនឹងបទបញ្ញត្តិ និងច្បាប់នានារបស់ធនាគារជាតិ នៃកម្ពុជា

ធនាគារពាណិជ្ជកកម្មក្រៅប្រទេស នៃកម្ពុជា តែងតែយកចិត្តទុកដាក់ និងអនុវត្តតាមច្បាប់ និងបទបញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជាដូចជា:

- ការអនុវត្តន៍ប្លង់គណនេយ្យថ្មី របស់ធនាគារ ជាតិនៃកម្ពុជា
- អនុបាតសាច់ប្រាក់ងាយស្រួល ប្រកាសលេខ ធ៧-០៤-២០៧
- កាតព្វកិច្ចដើមទុនអប្បបរមា ប្រកាសលេខ ធ៧-០០-៣៩
- មូលនិធិផ្ទាល់សុទ្ធ ប្រកាសលេខ ធ ៧-០០-៤៧
- អនុបាតសាធនភាព ប្រកាសលេខ ប ៧-០០-៤៦, ប ៧-០៤-២០៦ និង ប ៧-០៧-១៣៥
- ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនទ្រព្យសកម្ម ប្រកាសលេខ ប ៧-០២-១៤៥
- អចលនទ្រព្យ ប្រកាសលេខ ប ៧-០១-១៨៦
- ស្ថានភាពរូបិយប័ណ្ណចំហសុទ្ធ ប្រកាសលេខ ប ៧-០៧-១៣៤
- ហានិភ័យឥណទានធំៗ ប្រកាសលេខ ប៧-០៦-២២៦
- ឥណទានផ្តល់ទៅសម្ព័ន្ធញាតិ ប្រកាសលេខ ប7-០២-១៤៦

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (ហៅកាត់ថា "ធនាគារ") សូមដាក់ជូននូវរបាយការណ៍របស់ខ្លួននិង របាយការណ៍ ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារ សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០។

## អំពីធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ១២១៣អនក្រ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ក្នុងអតីតរបបរដ្ឋកម្ពុជា។ ក្នុងឆ្នាំ ២០០០ ធនាគារបានផ្តាច់ចេញពីការគ្រប់គ្រងផ្ទាល់របស់ធនាគារជាតិ នៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ដើម្បីក្លាយទៅជាធនាគារពាណិជ្ជរបស់រដ្ឋ ដែលមានចរិតជាសហគ្រាសសេដ្ឋកិច្ចសាធារណៈ និង មានគោលដៅធ្វើប្រតិបត្តិការអាជីវកម្មស្វយ័ត ។ ក្នុងខែមករា ឆ្នាំ២០០១ ធនាគារបានទទួលអាជ្ញាប័ណ្ណពីធនាគារកណ្តាល ដើម្បីធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជ នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលមានរយៈពេល៣ឆ្នាំ គិតចាប់ពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ តទៅ។ នេះគឺជាអាជ្ញាប័ណ្ណលើកដំបូង ដែលបានផ្តល់សិទ្ធិអោយធនាគារ ធ្វើប្រតិបត្តិការជានីតិបុគ្គល និងមានឯករាជ្យពីការគ្រប់គ្រងផ្ទាល់របស់ធនាគារកណ្តាល។ នៅថ្ងៃទី ០៨ ខែមករា ឆ្នាំ២០០៤ ធនាគារបានទទួល អាជ្ញាប័ណ្ណលើកទី២ពីធនាគារកណ្តាល សម្រាប់រយៈពេល៣ឆ្នាំបន្តទៀត។ បច្ចុប្បន្ននេះ ធនាគារបានទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ ជាធនាគារពាណិជ្ជ ដែលបានបន្តអាជ្ញាប័ណ្ណនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើសេចក្តីប្រកាសអំពីការធ្វើឯកជនភាវូបនីយកម្មទៅលើ ធនាគារ ដែល ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ ភាគទុនិករបស់ធនាគារ ដែលតំណាងដោយគណៈកម្មាធិការឯកជនភាវូបនីយកម្ម បានចុះកិច្ចព្រមព្រៀងជាមួយធនាគារកាណាឌីយ៉ា និង ក្រុមហ៊ុន ING Holding ដោយធនាគារកណ្តាលបានលក់ភាគហ៊ុន ២០% របស់ខ្លួន ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបន្ថយភាគហ៊ុនរបស់ខ្លួនពី ៨០% មកនៅត្រឹម ១០% វិញ។ លក្ខន្តិកៈរបស់ធនាគារ ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ដើម្បីឆ្លុះបញ្ចាំងពីបម្រែបម្រួលភាគទុនិក និង សមាជិកក្រុមប្រឹក្សាភិបាល។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ធនាគារ គឺការផ្តល់សេវាកម្មផ្នែកធនាគារ និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លទ្ធផលនៃប្រតិបត្តិការ និងភាគលាភ

លទ្ធផលនៃប្រតិបត្តិការសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ត្រូវបានបង្ហាញក្នុងរបាយការណ៍លទ្ធផលលើទំព័រទី២៥ ។ ក្នុងអំឡុងឆ្នាំនេះ មិនមានការប្រកាស ឬការបែងចែកភាគលាភជូនភាគទុនិកទេ (២០០៩ : គ្មាន)។

## ដើមទុនចុះបញ្ជី

ធនាគារបានបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួនពី ១៣.០០០.០០០ ដុល្លារអាមេរិក ដល់ ៣៥.៧៥០.០០០ ដុល្លារអាមេរិក តាមរយៈការផ្ទេរពីគណនីទុនបម្រុងធានាលើដើមទុន ចំនួន ២៤៧.៥២៩ ដុល្លារអាមេរិក ពីគណនីទុនបម្រុងសម្រាប់ហានិភ័យធនាគារ ចំនួន ១.០៤៣.៧០០ និងពីគណនីប្រាក់ចំណេញរក្សាទុកចំនួន ២១.៤៥៨.៧៧១ ដុល្លារអាមេរិក។

## ឥណទានអាក្រក់ និងសង្ស័យ

មុនការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យពាក់ព័ន្ធទៅនឹងការជំរះឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យចេញពីបញ្ជី ឬការធ្វើសំវិធានធនឥណទានអាក្រក់ និងសង្ស័យ និងបានយល់ស្របថារាល់ឥណទានអាក្រក់ដែលគេបានដឹង ត្រូវបានជំរះចេញពីបញ្ជី ហើយបានកត់ត្រាសំវិធានធនយ៉ាងពេញលេញ សម្រាប់ឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យ ។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងដ៏សុក្រឹតបំផុត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនឹងបណ្តាលអោយចំនួនឥណទាន និងបុរេប្រទានអាក្រក់ដែលបានជំរះចេញពីបញ្ជី ឬចំនួនសំវិធានធនឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយ លើកលែងតែ បំណុលដែលទំនងជាមិនអាចទទួលបានមកវិញ នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាទៅតាមតម្លៃ

នៅក្នុងបញ្ជីរបស់ធនាគារ ត្រូវបានកត់ត្រាបន្ថយអោយស្មើនឹងតម្លៃដែល រំពឹងថានឹងអាចលក់បាននៅលើទីផ្សារជាក់ស្តែង។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងដ៏សុក្រឹតបំផុត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលបណ្តាលអោយតម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានតម្លៃមិនត្រឹមត្រូវជាសារវន្តនោះទេ។

## វិធីសាស្ត្រប៉ាន់ស្មានតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងដ៏សុក្រឹតបំផុត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលបានកើតឡើង ដែលបណ្តាលអោយប៉ះពាល់ដល់ការអនុវត្តនីវិធីសាស្ត្រដែលមានស្រាប់ក្នុងការវាយតម្លៃទ្រព្យសកម្ម និង ទ្រព្យអកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានកំហុស ឬមិនសមស្របជាសារវន្តនោះទេ។

## ទ្រព្យអកម្មយថាភាព និងទ្រព្យអកម្មផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះមិនមាន :

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាមួយ និង

ខ. ទ្រព្យអកម្មយថាភាពណាមួយរបស់ធនាគារ ដែលបានកើតឡើងចាប់ពីដំណាច់ឆ្នាំក្រៅពីទ្រព្យអកម្មផ្សេងៗនៅក្នុងដំណើរការអាជីវកម្មធនាគារធម្មតាទេ ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល មិនមានទ្រព្យអកម្មយថាភាព ឬទ្រព្យអកម្មផ្សេងៗរបស់ធនាគារ ដែលត្រូវបានទាមទារអោយសង ឬអាចនឹងត្រូវទាមទារអោយសង ក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃផុតកំណត់សងនោះទេ។

## ការផ្លាស់ប្តូរហេតុការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្តាលអោយចំនួនទឹកប្រាក់ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានកំហុសឆ្គងជាសារវន្តនោះទេ ។

## ប្រតិបត្តិការមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលប្រតិបត្តិការនៃអាជីវកម្មរបស់ធនាគារក្នុងឆ្នាំនេះ ពុំមានរងនូវការប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ក្នុងចន្លោះពេលរវាងថ្ងៃបិទបញ្ជី មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានកើតឡើងនូវខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតា ដែលធ្វើអោយប៉ះពាល់ជាសារវន្ត លើលទ្ធផលប្រតិបត្តិការរបស់ធនាគារ ក្នុងឆ្នាំដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងប្រតិបត្តិ

សមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងប្រតិបត្តិ ដែលបានបម្រើការក្នុងអំឡុងឆ្នាំ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម :

### ក្រុមប្រឹក្សាភិបាល

| | | | |
|---|---|---|---|
| លោកឧកញ៉ា | ពុង ឃាវសែ | ប្រធានក្រុមប្រឹក្សាភិបាល | (ប្រតិបត្តិ) |
| លោកឧកញ៉ា | លឹម ប៊ុនសួរ | សមាជិកក្រុមប្រឹក្សាភិបាល | (ប្រតិបត្តិ) |
| ឯកឧត្តម | ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល | (ប្រតិបត្តិ) |
| ឯកឧត្តម | ហ៊ី អានវ៉ានិថ | សមាជិក ក្រុមប្រឹក្សាភិបាល | (ប្រតិបត្តិ) |
| លោកជំទាវ | អ៊ឹង ប៊ូលីណា | សមាជិក ក្រុមប្រឹក្សាភិបាល | (ប្រតិបត្តិ) |
| លោកស្រី | សុខ ចាន់សូណា | សមាជិក ក្រុមប្រឹក្សាភិបាល | (មិនប្រតិបត្តិ) |
| លោក | កង អ៊ី | សមាជិក ក្រុមប្រឹក្សាភិបាល | (មិនប្រតិបត្តិ) |
| លោក | នួន សំអ៊ាន | សមាជិក ក្រុមប្រឹក្សាភិបាល | (មិនប្រតិបត្តិ) |

## គណៈគ្រប់គ្រងប្រតិបត្តិ

| | | |
|---|---|---|
| ឯកឧត្តម | ហ្គី អានវ៉ានិថ | អគ្គនាយក |
| លោកជំទាវ | អ៊ឹង ប៊ូលីណា | អគ្គនាយករង |
| លោក | ទឹម បូផល | អគ្គនាយករង |
| លោកស្រី | នួន បូរ៉ានី | អគ្គនាយករង |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងឆ្នាំ និងគិតរហូតមកដល់ដំណាច់ឆ្នាំនេះ ធនាគារមិនបានចូលរួមជាភាគីក្នុងការចាត់ចែងណាមួយ ក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អោយទទួលបាននូវផលប្រយោជន៍ផ្សេងៗ តាមរយៈការទិញយកភាគហ៊ុន ឬលិខិតបំណុលពីសាមីធនាគារ ឬពីក្រុមហ៊ុនដទៃទៀតទេ ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់របស់ធនាគារ បានទទួល ឬមានសិទ្ធិនឹងបានទទួលនូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាងធនាគារ និងសមាជិកក្រុមប្រឹក្សាភិបាលនោះ ឬរវាងក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬរវាងក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍សំខាន់ផ្នែកហិរញ្ញវត្ថុ ក្រៅពីប្រតិបត្តិការផ្សេងៗដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ក៏ដូចជាលទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ តម្រូវអោយក្រុមប្រឹក្សាភិបាល :

១. ជ្រើសរើសគោលការណ៍គណនេយ្យដែលសមស្របមកប្រើ ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយអនុវត្តអោយមានភាពស៊ីសង្វាក់គ្នា ។

២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញអោយមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបង្ហាញពន្យល់និងកំណត់បរិមាណអោយបានត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

៣. ថែរក្សាកំណត់ត្រាគណនេយ្យអោយបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអោយមានប្រសិទ្ធិភាព ។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតយ៉ាងសមរម្យថា ធនាគារនឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

៥. ត្រួតពិនិត្យ និងដឹកនាំធនាគារអោយមានប្រសិទ្ធិភាព តាមរយៈការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងលទ្ធផលអាជីវកម្ម ហើយប្រាកដថាកិច្ចការទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមការតម្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំជាក្រុមប្រឹក្សាភិបាល បានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយ រួមនឹងកំណត់សម្គាល់ផ្សេងៗ ដែលបានបង្ហាញយ៉ាងត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ក៏ដូចជាលទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារ គណនេយ្យកម្ពុជា។

ចុះហត្ថលេខាដោយស្របទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

**ឯកឧត្តម ហ្គី អានវ៉ានិថ**

អគ្គនាយក

កាលបរិច្ឆេទ : ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១

**លោកស្រី នួន ប៉ូរ៉ានី**

អគ្គនាយករង

កាលបរិច្ឆេទ : ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១

## របាយការណ៍សវនករឯករាជ

ជូនភាគទុនិកធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ( ហៅកាត់ថា "ធនាគារ" ) រួមមានតារាងតុល្យការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ និងសេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះអោយបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ណែនាំផ្សេងៗ ចេញដោយធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនអោយមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្ម នៃកម្ពុជា ។ ស្តង់ដារទាំងនោះតម្រូវអោយយើងខ្ញុំប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការ និងធ្វើសវនកម្មដើម្បីទទួលបានការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ។

ការធ្វើសវនកម្មរួមមានការអនុវត្តន៍នីតិវិធីដើម្បីទទួលបាននូវភស្តុតាងសវនកម្មអំពីចំនួនទឹកប្រាក់ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនីតិវិធីទាំងនេះ គឺអាស្រ័យលើការវិនិច្ឆ័យរបស់សវនករដោយរួមបញ្ចូលទាំងការវាយតម្លៃលើហានិភ័យនៃភាពខុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើមានការក្លែងបន្លំ ឬកំហុសឆ្គងដែរឬទេ ។ ក្នុងការវាយតម្លៃហានិភ័យទាំងនោះ សវនករបានពិចារណាទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាព ដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីរៀបចំនីតិវិធីសវនកម្ម ដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈ ប៉ុន្តែការពិចារណានេះពុំមានគោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធិភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពនោះទេ ។ សវនកម្ម រួមបញ្ចូលទាំងការវាយតម្លៃនូវភាពសមស្រប នៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ក៏ដូចជាការវាយតម្លៃលើការបង្ហាញជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ ។

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងទទួលបាន គឺមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ ។

## មតិយោបល់

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ។

ជ. ក្រុមហ៊ុន PricewaterhouseCoopers (Cambodia) Ltd ។

**គុយ លឹម**
នាយក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ : ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១

## តារាងតុល្យការ
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០

| | កំណត់សម្គាល់ | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | 6,828,014 | 27,673,941 | 8,202,157 | 34,194,793 |
| សមតុល្យនៅធនាគារកណ្តាល | 4 | 161,236,833 | 653,492,884 | 145,442,216 | 606,348,599 |
| សមតុល្យនៅធនាគារផ្សេងៗ | 5 | 17,754,711 | 71,959,844 | 15,124,761 | 63,055,129 |
| ឥណទាន និងបុរេប្រទានអតិថិជន | 6 | 136,201,061 | 552,022,900 | 95,765,360 | 399,245,785 |
| ទ្រព្យសម្បត្តិរឹបអូស | 7 | 4,476,997 | 18,145,269 | 4,371,997 | 18,226,855 |
| ទ្រព្យសកម្មអរូបី | 8 | 379,684 | 1,538,859 | 439,394 | 1,831,834 |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | 9 | 1,965,716 | 7,967,047 | 1,728,042 | 7,204,207 |
| ពន្ធពន្យារទ្រព្យសកម្ម | 23 | 91,583 | 371,186 | 153,830 | 641,317 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 340,322 | 1,379,325 | 483,939 | 2,017,542 |
| **ទ្រព្យសកម្មសរុប** | | 329,274,921 | 1,334,551,255 | 271,711,696 | 1,132,766,061 |
| **ទ្រព្យអកម្ម និងមូលធន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 11 | 13,461,403 | 54,559,066 | 13,620,309 | 56,783,068 |
| ប្រាក់បញ្ញើរបស់អតិថិជន | 12 | 263,469,465 | 1,067,841,742 | 212,847,787 | 887,362,424 |
| បំណុលពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ | | 1,390,964 | 5,637,577 | 1,066,757 | 4,447,310 |
| ទ្រព្យអកម្មផ្សេងៗ | 13 | 2,451,226 | 9,934,821 | 2,176,633 | 9,074,383 |
| អត្ថប្រយោជន៍ក្រោយពេលបញ្ចប់កិច្ចសន្យាការងារ | 14 | 840,971 | 3,408,455 | 731,794 | 3,050,849 |
| **ទ្រព្យអកម្មសរុប** | | 281,614,029 | 1,141,381,661 | 230,443,280 | 960,718,034 |
| **មូលធន** | | | | | |
| ដើមទុន | 15 | 35,750,000 | 144,894,750 | 13,000,000 | 54,197,000 |
| ទុនបម្រុង | 16 | 2,945,589 | 11,938,471 | 4,236,822 | 17,663,312 |
| ចំណេញរក្សាទុក | | 8,965,303 | 36,336,373 | 24,031,594 | 100,187,715 |
| **មូលធនសរុប** | | 47,660,892 | 193,169,594 | 41,268,416 | 172,048,027 |
| **ទ្រព្យអកម្ម និងមូលធនសរុប** | | 329,274,921 | 1,334,551,255 | 271,711,696 | 1,132,766,061 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ២៨ ដល់ ទំព័រទី ៧៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍លទ្ធផល

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០

| | កំណត់សម្គាល់ | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | 17 | 13,719,979 | 55,607,075 | 13,120,651 | 54,699,994 |
| ចំណាយការប្រាក់ | 17 | (5,699,084) | (23,098,387) | (5,008,614) | (20,880,912) |
| **ចំណូលការប្រាក់សុទ្ធ** | | 8,020,895 | 32,508,688 | 8,112,037 | 33,819,082 |
| ចំណូលកម្រៃ និងជើងសារ | 18 | 2,463,789 | 9,985,737 | 1,848,423 | 7,706,075 |
| ចំណាយកម្រៃ និងជើងសារ | 18 | (198,618) | (804,999) | (145,019) | (604,584) |
| **ចំណូលកម្រៃ និងជើងសារសុទ្ធ** | | 2,265,171 | 9,180,738 | 1,703,404 | 7,101,491 |
| ចំណូលផ្សេងៗ | 19 | 315,132 | 1,277,230 | 525,994 | 2,192,869 |
| ចំណាយផ្នែកបុគ្គលិក | 20 | (1,908,819) | (7,736,443) | (1,915,902) | (7,987,395) |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | 8, 9 | (417,506) | (1,692,152) | (358,973) | (1,496,558) |
| ចំណាយរដ្ឋបាល និងចំណាយប្រតិបត្តិការ | 21 | (1,450,460) | (5,878,714) | (2,125,409) | (8,860,829) |
| **ចំណេញប្រតិបត្តិការមុនពេលពង្រីកឥណទាន** | | 6,824,413 | 27,659,347 | 5,941,151 | 24,768,660 |
| ការប្រមូលបានមកវិញនៃឥណទានបាត់បង់ និងការប្រាក់ - សុទ្ធ | 22 | 1,284,427 | 5,205,783 | 468,729 | 1,954,131 |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | 8,108,840 | 32,865,130 | 6,409,880 | 26,722,791 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 23 | (1,716,364) | (6,956,423) | (1,087,054) | (4,531,928) |
| **ចំណេញសុទ្ធក្នុងឆ្នាំ** | | 6,392,476 | 25,908,707 | 5,322,826 | 22,190,863 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ២៨ ដល់ ទំព័រទី ៧៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## **របាយការណ៍បម្រែបម្រួលមូលធន**
សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០

| | ដើមទុន ដុល្លារអាមេរិក | ទុនបម្រុងទូទៅ ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ | 13,000,000 | 4,276,420 | 18,708,768 | 35,985,188 |
| មូលនិធិសោធននិវត្តន៍ដែលបានទូទាត់ | - | (39,598) | - | (39,598) |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | 5,322,826 | 5,322,826 |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | 13,000,000 | 4,236,822 | 24,031,594 | 41,268,416 |
| **សមមូលនឹងពាន់រៀល ( មិនបានធ្វើសវនកម្ម)** | 54,197,000 | 17,663,311 | 100,187,715 | 172,048,026 |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ | 13,000,000 | 4,236,822 | 24,031,594 | 41,268,416 |
| ការផ្ទេរទុនបម្រុងទៅជាដើមទុន | 22,750,000 | (1,291,233) | (21,458,767) | - |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | 6,392,476 | 6,392,476 |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | 35,750,000 | 2,945,589 | 8,965,303 | 47,660,892 |
| **សមមូលនឹងពាន់រៀល ( មិនបានធ្វើសវនកម្ម)** | 144,894,750 | 11,938,471 | 36,336,373 | 193,169,595 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ២៨ ដល់ ទំព័រទី ៧៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| សាច់ប្រាក់ចេញពីប្រតិបត្តិការ (កំណត់សម្គាល់២៤) | 11,236,609 | 45,541,979 | 15,691,722 | 65,418,788 |
| ការប្រាក់បានទទួល | 13,340,112 | 54,067,474 | 13,029,514 | 54,320,044 |
| ការប្រាក់បានបង់ | (5,481,191) | (22,215,267) | (4,614,230) | (19,236,725) |
| មូលនិធិសោធននិវត្តន៍បានទូទាត់ | (14,726) | (59,684) | (42,389) | (176,720) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (1,329,914) | (5,390,141) | (1,872,660) | (7,807,120) |
| **សាច់ប្រាក់សុទ្ធចេញពីក្នុងសកម្មភាពប្រតិបត្តិការ** | 17,750,890 | 71,944,361 | 22,191,957 | 92,518,267 |
| | | | | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ប្រាក់តម្កល់បម្រុងនៅធនាគារកណ្តាល | (4,302,323) | (17,437,315) | 2,943,569 | 12,271,739 |
| ប្រាក់តម្កល់ធានាលើដើមទុននៅធនាគារកណ្តាល | (2,275,000) | (9,220,575) | - | - |
| ការទិញដីបន្ថែមជុំវិញទ្រព្យសម្បត្តិរឹបអូសបាន | (105,000) | (425,565) | - | - |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | (561,915) | (2,277,441) | (514,196) | (2,143,683) |
| ការទិញទ្រព្យសកម្មអរូបី | (33,555) | (135,998) | (146,833) | (612,147) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | - | - | 30,050 | 125,281 |
| **សាច់ប្រាក់សុទ្ធ(បានប្រើ)/ចេញពីសកម្មភាពវិនិយោគ** | (7,277,793) | (29,496,894) | 2,312,590 | 9,641,190 |
| | | | | |
| **កំណើនសុទ្ធ នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | 10,473,097 | 42,447,467 | 24,504,547 | 102,159,457 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ | 136,950,884 | 570,948,236 | 112,446,337 | 458,893,501 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (15,886,307) | - | 9,895,278 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** (កំណត់សម្គាល់២៥) | 147,423,981 | 597,509,396 | 136,950,884 | 570,948,236 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ២៨ ដល់ ទំព័រទី ៧៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០

## ១. ព័ត៌មានទូទៅ

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ១២១៣អនក្រ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ក្នុងអតីតរបបរដ្ឋកម្ពុជា។ ក្នុងឆ្នាំ ២០០០ ធនាគារបានផ្តាច់ចេញពីការគ្រប់គ្រងផ្ទាល់របស់ធនាគារជាតិ នៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ដើម្បីក្លាយទៅជាធនាគារពាណិជ្ជរបស់រដ្ឋ ដែលមានចរិតជាសហគ្រាសសេដ្ឋកិច្ចសាធារណៈ និងមានគោលដៅធ្វើប្រតិបត្តិការអាជីវកម្មស្វយ័ត ។

ក្នុងខែមករា ឆ្នាំ២០០១ ធនាគារបានទទួលអាជ្ញាប័ណ្ណពីធនាគារកណ្តាល ដើម្បីធ្វើប្រតិបត្តិការ ជាធនាគារពាណិជ្ជនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានរយៈពេល៣ឆ្នាំ គិតចាប់ពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ តទៅ។ នេះគឺជាអាជ្ញាប័ណ្ណលើកដំបូងដែលបានផ្តល់សិទ្ធិអោយធនាគារ ធ្វើប្រតិបត្តិការជានីតិបុគ្គល និងមានឯករាជ្យពីការគ្រប់គ្រងផ្ទាល់របស់ធនាគារកណ្តាល។ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ ធនាគារបានទទួលអាជ្ញាប័ណ្ណលើកទី២ ពីធនាគារកណ្តាល សម្រាប់រយៈពេល៣ឆ្នាំបន្តទៀត។ បច្ចុប្បន្ននេះ ធនាគារបានទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ ជាធនាគារពាណិជ្ជ ដែលបានបន្តនៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០០៦។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើសេចក្តីប្រកាសអំពីការធ្វើឯកជនភាវូបនីយកម្មទៅលើធនាគារ ដែលជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ ភាគទុនិករបស់ធនាគារ ដែលតំណាងដោយគណៈកម្មាធិការឯកជនភាវូបនីយកម្ម បានចុះកិច្ចព្រមព្រៀងជាមួយធនាគារកាណាឌីយ៉ា និងក្រុមហ៊ុន ING Holding ដោយធនាគារកណ្តាលបានលក់ភាគហ៊ុន ២០% របស់ខ្លួន ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបន្ថយភាគហ៊ុនរបស់ខ្លួនពី ៨០% មកនៅត្រឹម ១០% វិញ។ លក្ខន្តិករបស់ធនាគារ ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ដើម្បីឆ្លុះបញ្ចាំងពីបម្រែបម្រួលភាគទុនិក និងសមាជិកក្រុមប្រឹក្សាភិបាល។

ការិយាល័យចុះបញ្ជីរបស់ធនាគារ មានទីតាំងស្ថិតនៅអគារលេខ ៣ វុក្ខវិថី ក្រមួនស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ធនាគារមានបុគ្គលិកចំនួន ១២១ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ : ១១៦ នាក់)។ ក្រុមប្រឹក្សាភិបាល បានអនុម័តអោយចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១។ ក្រុមប្រឹក្សាភិបាល មានសិទ្ធិកែប្រែ និងចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះឡើងវិញ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញដូចខាងក្រោម ។

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល និងស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS")។ ក្នុងការអនុវត្ត CAS ធនាគារក៏បានអនុវត្តតាមការលាតត្រដាងព័ត៌មានរបស់ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ នៃកម្ពុជា CFRS 4 ស្តីពី "កិច្ចសន្យាធានារ៉ាប់រង" និង CFRS 7 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ" ផងដែរ។ គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យ ដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ ហេតុនេះរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាម យុត្តាធិការណាផ្សេង ក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រសន្មតថ្លៃដើម ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និង CAS តម្រូវអោយប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងទ្រព្យអកម្ម និងការលាតត្រដាងទ្រព្យសកម្ម និងទ្រព្យអកម្មយថាភាព គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃចំណូល និងចំណាយដែលបានរាយការណ៍ នៅក្នុងអំឡុងឆ្នាំដែលបានរាយការណ៍នេះ ។ ទោះបីជាការប៉ាន់ស្មានទាំងនេះ ផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតបំផុតរបស់គណៈគ្រប់គ្រង ទៅលើព្រឹត្តិការណ៍ និងសកម្មភាពបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់ស្តែងចុងក្រោយ អាចនឹងខុសពីការប៉ាន់ស្មានទាំងនេះ ។ ផ្នែកដែលទាក់ទងនឹងកម្រិតខ្ពស់បំផុតនៃការវិនិច្ឆ័យ ឬភាពស្មុគស្មាញ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានដែលមានលក្ខណៈជាសារវន្ត ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ ។

អនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៤ប្រ.ក. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ របស់ធនាគារកណ្តាល តារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាប្តូរប្រាក់មធ្យមភាគផ្លូវការដែលកំណត់ដោយធនាគារកណ្តាល នាកាលបរិច្ឆេទរាយការណ៍ ដែល ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៥៣ រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩: ១ ដុល្លារអាមេរិក ស្មើនឹង ៤.១៦៩ រៀល) ។ តួលេខដែលបានប្តូរនេះ មិនត្រូវបានធ្វើសវនកម្មទេ ដូចនេះមិនគួរបកស្រាយថា តួលេខនេះ ជាតួលេខសម្រាប់បង្ហាញ ដូចតួលេខជាប្រាក់ដុល្លារអាមេរិកនោះទេ ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ ។

## ២.២ ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយ

(ក) ស្តង់ដារថ្មីៗ វិសោធនកម្មលើស្តង់ដារដែលមានស្រាប់ និងបំណកស្រាយ ដែលចូលជាធរមានក្នុងឆ្នាំ ២០១០

ស្តង់ដារគណនេយ្យ វិសោធនកម្មលើស្តង់ដារដែលមានស្រាប់ និងបំណកស្រាយផ្សេងៗ ដែលបានចូលជាធរមាន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១០ ពុំទាក់ទងនឹងប្រតិបត្តិការរបស់ធនាគារទេ ។

(ខ) ស្តង់ដារ និងវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ ដែលបានចេញផ្សាយ ប៉ុន្តែពុំទាន់ចូលជាធរមាន

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យ បានប្រកាសដាក់អោយប្រើប្រាស់នូវស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងតាមស្តង់ដារដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មផ្សេងៗផងដែរ ។ ស្ថាប័នដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយអនុលោមតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ ។

ស្តង់ដារគណនេយ្យអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា "CIAS") ឬ CIFRS និងវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ ដូចខាងក្រោមនេះ បានចេញផ្សាយរួចហើយ ហើយមានការពាក់ព័ន្ធ និងមានភាពចាំបាច់សម្រាប់ការិយបរិច្ឆេទគណនេយ្យពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ ប៉ុន្តែធនាគារមិនបានអនុវត្តមុនកាលកំណត់ទេ ។

• CIAS 1 (កែសំរួល) ស្តីពី "ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ"

រាល់ប្រតិបត្តិការដែលមិនប៉ះពាល់ដល់ការប្រែប្រួលមូលធនម្ចាស់ទ្រព្យ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល ។ អង្គភាពទាំងឡាយ អាចជ្រើសរើសបានថា ត្រូវបង្ហាញក្នុងរបាយការណ៍លទ្ធផលតែមួយ (របាយការណ៍លទ្ធផលលម្អិត) ឬបង្ហាញក្នុង

របាយការណ៍លទ្ធផលពីរ (របាយការណ៍លទ្ធផល និងរបាយការណ៍លទ្ធផលលម្អិត) ។ អង្គភាពទាំងឡាយណាដែលរាយការណ៍ ឬធ្វើចំណាត់ថ្នាក់ឡើងវិញនូវព័ត៌មានប្រៀបធៀប ត្រូវបានតម្រូវអោយបង្ហាញតារាងតុល្យការដែលរាយការណ៍ឡើងវិញ គិតត្រឹមការចាប់ផ្តើមនៃការិយបរិច្ឆេទប្រៀបធៀបនោះ ។ ស្តង់ដារដែលបានធ្វើវិសោធនកម្មនេះ ក៏បញ្ជាក់ផងដែរថាការទូទាត់ទ្រព្យអកម្មដែលមានសក្តានុពលភាព ដោយការចេញផ្សាយដើមទុន មិនពាក់ព័ន្ធទៅនឹងការធ្វើចំណាត់ថ្នាក់ទ្រព្យអកម្មនោះ ជាទ្រព្យអកម្មរយៈពេលវែង ឬខ្លីនោះទេ ។ ធនាគារ នឹងអនុវត្ត CIAS 1 (កែសំរួល)ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ទៅ ។ ធនាគារទំនងជាបង្ហាញរបាយការណ៍លទ្ធផលទាំងពីរ គឺរបាយការណ៍លទ្ធផល និងរបាយការណ៍លទ្ធផលលម្អិត នៅក្នុងរបាយការណ៍លទ្ធផលតែមួយ ។

វិសោធនកម្មបន្ទាប់ទៅលើស្តង់ដារនេះ តម្រូវអោយអង្គភាពមួយបង្ហាញការវិភាគលើលទ្ធផលលម្អិតផ្សេងៗ សម្រាប់សមាសធាតុនីមួយៗនៃមូលធន ក្នុងរបាយការណ៍បម្រែបម្រួលមូលធន ឬបង្ហាញក្នុងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុក៏បាន ។

• CIAS 16 (វិសោធនកម្ម) ស្តីពី "ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ" (និងវិសោធនកម្មបន្ទាប់លើ CIAS 7 ស្តីពី "របាយការណ៍លំហូរសាច់ប្រាក់") ស្តង់ដារដែលបានធ្វើវិសោធនកម្មនេះ តម្រូវអោយអង្គភាពទាំងឡាយណា ដែលមានសកម្មភាពអាជីវកម្មប្រចាំថ្ងៃទាក់ទងទៅនឹងការជួល និងលក់ទ្រព្យសកម្មផ្សេងៗនៅពេលបន្ទាប់មក ត្រូវបង្ហាញសាច់ប្រាក់ដែលបានមកពីការលក់ទ្រព្យសកម្មទាំងនោះជាប្រាក់ចំណូល ហើយត្រូវផ្ទេរតម្លៃនៅសល់របស់ទ្រព្យសកម្មនោះ ទៅជាសន្និធិវិញ នៅពេលដែលទ្រព្យសកម្មនោះ ត្រូវគេរៀបចំសម្រាប់លក់ ។ វិសោធនកម្មនៅពេលបន្ទាប់មកទៀតទៅលើ CIAS 7 តម្រូវអោយចាត់ថ្នាក់លំហូរសាច់ប្រាក់ ដែលកើតពីការទិញ ការជួល និងការលក់ទ្រព្យសកម្មទាំងនោះ ជាលំហូរសាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ ។ គេមិនរំពឹងថាស្តង់ដារនេះ នឹងមានផលប៉ះពាល់ជាសារវន្ត លើរបាយកាណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ ។

• CIAS 19 ស្តីពី "អត្ថប្រយោជន៍និយោជិត"

កម្មវត្ថុនៃស្តង់ដារនេះ គឺការផ្តល់អនុសាសន៍លើគណនេយ្យកម្ម និងការលាតត្រដាងអំពីអត្ថប្រយោជន៍និយោជិត ។ ស្តង់ដារនេះ តម្រូវអោយអង្គភាពមួយកត់ត្រាអត្ថប្រយោជន៍និយោជិតដូចតទៅ : (ក) កត់ត្រាជាទ្រព្យអកម្ម នៅពេលដែលនិយោជិតបានផ្តល់សេវាកម្មដើម្បីទទួលបានអត្ថប្រយោជន៍តបស្នងមកវិញនាពេលអនាគត និង (ខ) កត់ត្រាជាចំណាយ នៅពេលដែលអង្គភាពប្រើប្រាស់អត្ថប្រយោជន៍សេដ្ឋកិច្ច ដែលបានមកពីការផ្តល់សេវាកម្មរបស់និយោជិត ជាថ្នូរនឹងអត្ថប្រយោជន៍និយោជិត ។ គេមិនរំពឹងថា ស្តង់ដារនេះនឹងមានផលប៉ះពាល់ជាសារវន្ត លើរបាយកាណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ ។

• CIAS 24 (កែសំរួល) ស្តីពី "ការលាតត្រដាងភាគីសម្ព័ន្ធញាតិ"

• CIAS 24 ត្រូវបានកែសំរួលដូចតទៅ : (ក)កែសំរួលនិយមន័យនៃពាក្យ "ភាគីសម្ព័ន្ធញាតិ" អោយមានលក្ខណៈកាន់តែសាមញ្ញដោយបញ្ជាក់អោយកាន់តែច្បាស់នូវអត្ថន័យរបស់វា និងលុបចោលនូវភាពមិនស៊ីសង្វាក់គ្នារបស់និយមន័យ និង (ខ) ផ្តល់នូវការលើកលែងខ្លះ ចំពោះអង្គភាពដែលពាក់ព័ន្ធនឹងរដ្ឋាភិបាល ចំពោះតម្រូវការក្នុងការលាតត្រដាងភាគីសម្ព័ន្ធញាតិនេះ ។CIAS 24 (កែសំរួល) នឹងមិនមានផលប៉ះពាល់ជាសារវន្ត លើរបាយកាណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ ។

• CIAS 32 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ : ការធ្វើចំណាត់ថ្នាក់"

កម្មវត្ថុរបស់ស្តង់ដារនេះ គឺដើម្បីបង្កើតគោលការណ៍ផ្សេងៗ សម្រាប់ការធ្វើចំណាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុមួយចំនួនជា ទ្រព្យអកម្ម ឬមូលធន និងសម្រាប់ទូទាត់ទ្រព្យសកម្មហិរញ្ញវត្ថុ ជាមួយនឹងទ្រព្យអកម្មហិរញ្ញវត្ថុ ។ ស្តង់ដារនេះ ត្រូវអនុវត្តចំពោះការធ្វើចំណាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុ ទៅជាទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុ និងឧបករណ៍មូលធន ទៅតាមទស្សនវិស័យរបស់អ្នកចេញផ្សាយភាគហ៊ុន ក៏ដូចជាការធ្វើចំណាត់ថ្នាក់ទៅលើអត្ថប្រយោជន៍ពាក់ព័ន្ធ ភាគលាភ ចំណេញ និងខាត និងកាលៈទេសៈផ្សេងៗ ដែលទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអកម្មហិរញ្ញវត្ថុគួរតែត្រូវបានទូទាត់ ។

ជាងនេះទៅទៀត ស្តង់ដារនេះតម្រូវអោយអង្គភាពទាំងឡាយ ធ្វើចំណាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុ puttable និងឧបករណ៍ផ្សេងៗ ឬសមាសធាតុ នៃឧបករណ៍ផ្សេងៗ ដែលធ្វើអោយអង្គភាពនោះ ជាប់កាតព្វកិច្ចក្នុងការផ្តល់អោយភាគីមួយផ្សេងទៀត នូវចំណែកភាគហ៊ុន តាមសមាមាត្រថេរនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពនោះ ទៅតាមដើមទុននៅពេលបិទក្រុមហ៊ុន ហើយប្រសិនបើឧបករណ៍ហិរញ្ញវត្ថុមាន លក្ខណៈពិសេស និងបំពេញនូវលក្ខខណ្ឌពិសេស ។ CIAS 32 នឹងមិនមានផលប៉ះពាល់ជាសារវន្ត លើការធ្វើចំណាត់ថ្នាក់ និងការបង្ហាញ ឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ ដោយសារទ្រព្យសកម្មហិរញ្ញវត្ថុរបស់ធនាគារ ភាគច្រើនមានតែគណនីឥណទាន និងគណនីអតិថិជន ហើយទ្រព្យអកម្មហិរញ្ញវត្ថុមានតែគណនីប្រាក់បញ្ញើរបស់អតិថិជនតែប៉ុណ្ណោះ ។

• CIAS 36 (វិសោធនកម្ម) ស្តីពី "ការថយចុះតម្លៃទ្រព្យសកម្ម"

ស្តង់ដារដែលបានធ្វើវិសោធនកម្មនេះបញ្ជាក់ថា ប្រសិនបើតម្លៃទីផ្សារដកចំណាយក្នុងការលក់ ត្រូវបានគណនាតាមមូលដ្ឋាន លំហូរសាច់ប្រាក់អប្បហារ (discounted cash flows) នោះការបង្ហាញពីចំនួនដែលសមមូលនឹងតម្លៃទាំងនោះ សម្រាប់ការគណនា តម្លៃនៅប្រើប្រាស់ (value-in-use) គួរតែត្រូវបានធ្វើឡើង ។ វិសោធនកម្មនេះ នឹងមិនមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ ហិរញ្ញវត្ថុរបស់ធនាគារទេ ។

• CIAS 38 (វិសោធនកម្ម) ស្តីពី "ទ្រព្យសកម្មអរូបី"

ស្តង់ដារដែលបានកែសំរួលនេះ ផ្តល់នូវការបញ្ជាក់កាន់តែច្បាស់ ចំពោះការវាស់វែងតម្លៃទីផ្សារនៃទ្រព្យសកម្មអរូបីដែលបានទិញក្នុងសមា ហរណកម្មអាជីវកម្ម ហើយស្តង់ដារនេះក៏បានអនុញ្ញាតអោយដាក់ក្រុមទ្រព្យសកម្មអរូបីទាំងនោះ ជាទ្រព្យសកម្មតែមួយ ប្រសិនបើទ្រព្យ សកម្មនីមួយៗនោះ មានអាយុកាលប្រើប្រាស់ផ្នែកសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ។ វិសោធនកម្មនេះ នឹងមិនមានផលប៉ះពាល់ជាសារវន្ត លើរបាយកាណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ ។

• CIAS 39 ស្តីពី "ការទទួលស្គាល់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ"

ស្តង់ដារនេះបង្កើតនូវគោលការណ៍សម្រាប់ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ ទ្រព្យអកម្មហិរញ្ញវត្ថុ និងកិច្ចសន្យាមួយ-ចំនួនក្នុងការទិញ ឬលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ។ ការអនុវត្ត CIAS 39 នឹងបណ្តាលអោយមានការកែប្រែគោលការណ៍គណនេយ្យ លើឧបករណ៍ហិរញ្ញវត្ថុមួយចំនួន ដូចខាងក្រោម :

## ឥណទាន និងបុរេប្រទានអតិថិជន

គណនីឥណទាន និងបុរេប្រទានអតិថិជន ត្រូវបានរាយការណ៍នៅក្នុងតារាងតុល្យការ តាមសមតុល្យប្រាក់ដើម និងការប្រាក់ ដែលនៅសល់ ដកចំនួនដែលបានជំរះចេញពីបញ្ជី និងសំវិធានធនឥណទានបាត់បង់ ។ ដោយឡែកក្រោម CIAS 39 គណនីឥណទាន និងគណនីអតិថិជន ត្រូវបានទទួលស្គាល់ជាបឋមតាមតម្លៃទីផ្សារ ដែលជាការចំណាយសាច់ប្រាក់ដើម្បីបង្កើត ឬទិញឥណទាន រាប់ទាំងចំណាយប្រតិបត្តិការ ផ្សេងៗ ហើយបន្ទាប់មកវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ពិត ។

## ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

បច្ចុប្បន្ននេះ ធនាគារអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទាន ដែលតម្រូវដោយប្រកាសលេខ ធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ចេញដោយធនាគារកណ្តាល ដូចបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ២.៦ នៃរបាយការណ៍ហិរញ្ញវត្ថុ ។ CIAS 39 តម្រូវអោយធនាគារវាយតម្លៃនៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍នីមួយៗ ទាំងតាមមូលដ្ឋាននៃការវាយតម្លៃទ្រព្យ សកម្មទោល និងតាមមូលដ្ឋាននៃការវាយតម្លៃទ្រព្យសកម្មជាក្រុម ដើម្បីរកមើលថាតើមានភស្តុតាងពិតបង្ហាញថា មានការថយចុះតម្លៃ នៃទ្រព្យសកម្មហិរញ្ញវត្ថុទោល និងទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុមដែរឬទេ ។ ការខាតបង់បណ្តាលមកពីការថយចុះ តម្លៃ ត្រូវបានវាស់វែង តាមចំនួនលម្អៀង រវាងតម្លៃនៅសល់នៃទ្រព្យសកម្មមួយ ធៀបនឹងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគត (ដោយ មិនគិតការខាតបង់ឥណទាននាពេលអនាគត ដែលមិនទាន់បានកើតឡើង) និងធ្វើអប្បហារផ្អែកលើអត្រាការប្រាក់ដើមពិតរបស់ទ្រព្យ សកម្មនោះ ។

ក្នុងការវាយតម្លៃរកការថយចុះតម្លៃជាក្រុម ទ្រព្យសកម្មទាំងឡាយត្រូវបានចាត់ជាក្រុម តាមមូលដ្ឋានទ្រព្យសកម្ម ដែលមានលក្ខណៈហានិភ័យឥណទានប្រហាក់ប្រហែលគ្នា។

## ប្រាក់បញ្ញើរបស់ធនាគារ និងប្រាក់បញ្ញើរបស់អតិថិជន

ធនាគារវាស់វែងប្រាក់បញ្ញើរបស់អតិថិជន តាមតម្លៃនៃប្រាក់បញ្ញើ។ CIAS 39 តម្រូវអោយវាស់វែងទ្រព្យអកម្មហិរញ្ញវត្ថុផ្សេងៗ (ដែលបានចាត់ថ្នាក់ពីប្រាក់បញ្ញើរបស់អតិថិជន) តាមតម្លៃថ្លៃដើមដករំលស់។

## ចំណូលការប្រាក់ និងចំណាយការប្រាក់

បច្ចុប្បន្ននេះ ធនាគារកត់ត្រាចំណូល និងចំណាយការប្រាក់តាមមូលដ្ឋានបង្គរ ទៅតាមអត្រាដែលបានព្រមព្រៀង និងកម្រៃដំណើរការឥណទានដែលមិនបានដករំលស់ លើរយៈពេលឥណទាន ហើយកម្រៃដំណើរការឥណទានដែលមិនបានដករំលស់ ត្រូវបានបង្ហាញ ដោយធៀបនឹងឥណទាន និងបុរេប្រទានអតិថិជន។ CIAS 39 តម្រូវអោយកត់ត្រាចំណូល និងចំណាយការប្រាក់ នៃរាល់ឧបករណ៍ហិរញ្ញវត្ថុដែលមានការប្រាក់ទាំងអស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ពិត។ ជាងនេះទៅទៀត ធនាគារមិនបានកត់ត្រាចំណូលការប្រាក់លើឥណទាន និងបុរេប្រទានអតិថិជនទេ ប្រសិនបើមានករណីសង្ស័យជាក់លាក់ចំពោះការប្រមូលប្រាក់មកវិញ។ អនុលោមតាម CIAS 39 នៅពេលទ្រព្យសកម្មហិរញ្ញវត្ថុណាមួយ ឬទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុម ដែលមានលក្ខណៈស្រដៀងគ្នា ត្រូវបានគេកត់ត្រាបន្ថយ ដោយសារការថយចុះតម្លៃ នោះចំណូលការប្រាក់ត្រូវបានកត់ត្រាតាមអត្រាការប្រាក់ ដែលបានប្រើក្នុងលំហូរសាច់ប្រាក់នាពេលអនាគតដែលបានធ្វើអប្បហារ ដើម្បីវាស់វែងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ។

- CIFRS 7 (វិសោធនកម្ម) ស្តីពី "ការលាតត្រដាងឧបករណ៍ហិរញ្ញវត្ថុ"

ស្តង់ដារដែលបានកែសំរួល តម្រូវអោយលាតត្រដាងការវាស់វែងតម្លៃទីផ្សារ និងហានិភ័យសាច់ប្រាក់ងាយស្រួល អោយបាន កាន់តែប្រសើរឡើង។ ជាពិសេស វិសោធនកម្មនេះ តម្រូវអោយលាតត្រដាងការវាស់វែងតម្លៃទីផ្សារ ទៅតាមឋានានុក្រមនៃការវាស់វែងតម្លៃទីផ្សារដូចខាងក្រោម :

- កម្រិតទី ១ - តម្លៃដែលបានដាក់លក់ (មិនបានកែតម្រូវ) លើទីផ្សារសកម្ម នៃទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលមានតម្លៃសមមូល
- កម្រិតទី ២ - ធាតុចូល ក្រៅពីតម្លៃដាក់លក់ ដែលបានបញ្ចូលទៅក្នុងកម្រិតទី១ ហើយអាចអង្កេតទ្រព្យសកម្ម ឬទ្រព្យអកម្មបានដោយផ្ទាល់ ឬដោយប្រយោល និង
- កម្រិតទី ៣ - ធាតុចូលសម្រាប់ទ្រព្យសកម្ម ឬទ្រព្យអកម្ម ដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន។

វិសោធនកម្មបន្ទាប់ លើស្តង់ដារនេះ តម្រូវអោយអង្គភាពមួយផ្តល់នូវការលាតត្រដាងព័ត៌មាន អំពីគុណភាពនៅក្នុងបរិបទ នៃការលាតត្រដាងព័ត៌មានអំពីគុណភាព ស្តីពីលក្ខណៈ និងទំហំហានិភ័យ ដែលកើតពីឧបករណ៍ហិរញ្ញវត្ថុ។

- CIFRS 9 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ"

ស្តង់ដារនេះ បង្កើតនូវគោលការណ៍សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលនឹងត្រូវបង្ហាញអំពី ព័ត៌មានដែលមានសារប្រយោជន៍ និងពាក់ព័ន្ធជាមួយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការវិភាគរបស់ពួកគេទៅលើតួលេខ ពេលវេលា និងភាពមិនពិតប្រាកដនៃលំហូរសាច់ប្រាក់នាពេលអនាគតរបស់អង្គភាព។ CIFRS 9 បញ្ជាក់អំពីមូលដ្ឋាននៃការធ្វើ ចំណាត់ថ្នាក់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុផងដែរ រួមទាំងកិច្ចសន្យាសំយោគ (hybrid contracts) មួយចំនួនផង។ ស្តង់ដារនេះ តម្រូវអោយទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ : (ក) ត្រូវបានធ្វើចំណាត់ថ្នាក់តាមមូលដ្ឋាននៃទម្រង់អាជីវកម្មរបស់អង្គភាពមួយ ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខណៈនៃលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា នៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ (ខ) ត្រូវបានវាស់វែង ជាបឋមតាមតម្លៃទីផ្សារ បូកនឹងចំណាយប្រតិបត្តិការផ្សេងៗ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុ មិនត្រូវបានវាស់វែងតាមតម្លៃទីផ្សារ ដែលនាំអោយមានចំណេញ ឬខាត និង (គ) ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ នៅពេលបន្ទាប់ ឬវាស់វែងតាមតម្លៃទីផ្សារ អាស្រ័យទៅតាមចំណាត់ថ្នាក់នៃទ្រព្យសកម្ម។

## ២.៣ ប្រតិបត្តិការរូបិយប័ណ្ណបរទេស

### ក. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល") ។ របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ ។

### ខ. ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ ។ ចំណេញ និងខាត ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរនាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

## ២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ គណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យមិនជាប់កម្រិត (non-restricted balance) នៅធនាគារកណ្តាល និងសមតុល្យនៅធនាគារផ្សេងៗ ដែលមានកាលកំណត់បីខែ ឬតិចជាងគិតពីថ្ងៃទទួលបាន ។

## ២.៥ ឥណទាន និងបុរេប្រទានអតិថិជន

ឥណទាន និងបុរេប្រទានអតិថិជនទាំងអស់ ត្រូវបានកត់ត្រាក្នុងតារាងតុល្យការ តាមចំនួនប្រាក់ដើមដែលនៅមិនទាន់ទូទាត់ ដកចំនួនដែលបានជំរះចេញពីបញ្ជី និងសំវិធានធនឥណទាន និងបុរេប្រទានបាត់បង់ ។ ឥណទាន ត្រូវបានជំរះចេញពីបញ្ជី នៅពេលដែលមិនមានភាពជាក់លាក់ថា នឹងអាចប្រមូលបានមកវិញ ។ ឥណទាន និងបុរេប្រទាន ដែលប្រមូលបានមកវិញ បន្ទាប់ពីបានជំរះចេញពីបញ្ជីរួចហើយ ឬបានកត់ត្រាសំវិធានធនរួចហើយ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

## ២.៦ សំវិធានធនឥណទាន និងបុរេប្រទានបាត់បង់

ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទាន ដែលតម្រូវដោយប្រកាសលេខ ធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ចេញដោយធនាគារកណ្តាល ។ ប្រកាសនេះ តម្រូវអោយធនាគារពាណិជ្ជទាំងឡាយ ធ្វើចំណាត់ថ្នាក់ ឥណទាន បុរេប្រទាន និងទ្រព្យសកម្មស្រដៀងៗគ្នារបស់ពួកគេ ជាប្រាំចំណាត់ថ្នាក់ ហើយកម្រិតចាំបាច់អប្បបរមានៃការធ្វើសំវិធានធនជាក់លាក់ នឹងត្រូវបានធ្វើឡើងអាស្រ័យតាមចំណាត់ថ្នាក់ដែលពាក់ព័ន្ធ ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជា វត្ថុបញ្ចាំ (លើកលែងសាច់ប្រាក់) ដូចមានបង្ហាញខាងក្រោម ៖

| | អត្រាសំវិធានធន |
|---|---|
| សំវិធានធនទូទៅ ៖ | |
| ឥណទានធម្មតា | ១% |
| សំវិធានធនជាក់លាក់ ៖ | |
| ឥណទានឃ្លាំមើល | ៣% |
| ឥណទានក្រោមស្តង់ដារ | ២០% |
| ឥណទានសង្ស័យ | ៥០% |
| ឥណទានបាត់បង់ | ១០០% |

## ២.៧ ទ្រព្យសកម្មអរូបី

### អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ

អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើង ក្នុងការទិញកម្មវិធីនោះ មកប្រើប្រាស់ ។ ថ្លៃដើមនេះ ត្រូវបានធ្វើរំលស់រយៈពេល៥ឆ្នាំ ដោយប្រើវិធីសាស្ត្ររំលស់ថេរ ។

## ២.៨ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់ លើកលែងតែដីធ្លី ដែលមិនត្រូវបានធ្វើរំលស់ ។ ថ្លៃដើម រួមមានចំណាយផ្ទាល់ផ្សេងៗ ក្នុងការទិញទ្រព្យសកម្មទាំងនោះ ។

ចំណាយនាពេលបន្ទាប់ ពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិ និងបរិក្ខារណាមួយ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃចុះបញ្ជីនៃ ទ្រព្យសកម្មនោះ ឬត្រូវបានកត់ត្រាជាទ្រព្យសកម្មដាច់ដោយឡែក តាមការជាក់ស្តែង តែនៅពេលដែលមានភាពប្រាកដថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះ នឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរអោយជឿជាក់បានតែប៉ុណ្ណោះ ។ រាល់ចំណាយលើការជួសជុល និងថែទាំ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង ។

ដីធ្លី និងទ្រព្យសម្បត្តិ និងបរិក្ខារមិនទាន់សម្រេច (Capital work-in-progress) មិនត្រូវបានដករំលស់ទេ ។ ការដករំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានរំលស់ថេរ លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាន នៃទ្រព្យសកម្មនីមួយៗ តាមអត្រាដូចខាងក្រោម ៖

| | |
|---|---|
| អគារ | ២០ ឆ្នាំ |
| គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ | ៣-៥ ឆ្នាំ |
| យានយន្ត | ៥ ឆ្នាំ |

តម្លៃសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យ និងកែសំរួលតាមការជាក់ស្តែង នៅរៀងរាល់ដំណាច់ការិយបរិច្ឆេទរបាយការណ៍នីមួយៗ ។ ប្រសិនបើតម្លៃនៅសល់នៃទ្រព្យសកម្មណាមួយ លើសពីតម្លៃប៉ាន់ស្មានដែលអាចប្រមូលមកវិញបាន វាត្រូវបានកត់ត្រាបន្ថយភ្លាម អោយនៅស្មើនឹងចំនួនដែលអាចប្រមូលមកវិញបាន ។ ចំណេញ និងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃនៅសល់ ហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

## ២.៩ ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានធ្វើរំលស់ទេ និងត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំ រកការថយចុះតម្លៃរបស់វា ។ បណ្តាទ្រព្យសកម្មដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យ ដើម្បីកំណត់រកការថយចុះតម្លៃរបស់វា នៅពេលដែលព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយ ចង្អុលបង្ហាញថាតម្លៃនៅសល់ ប្រហែលជាមិនអាចប្រមូលមកវិញបាន ។ ការខាត ដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមចំនួនលើស រវាងតម្លៃនៅសល់នៃទ្រព្យសកម្មនោះ ធៀបជាមួយតម្លៃដែលអាចប្រមូលបានមកវិញ ។ តម្លៃដែលអាចប្រមូលបានមកវិញ គឺជាតម្លៃមួយណាដែលខ្ពស់ជាងគេ រវាងតម្លៃទីផ្សារនៃទ្រព្យសកម្មនោះ ដកចំណាយក្នុងការលក់ និងតម្លៃកំពុងប្រើប្រាស់ ។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល ក្នុងឆ្នាំដែលវាបានកើតឡើង ។ ការកត់ត្រាបញ្ច្រាសមកវិញនៃការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រានៅក្នុងរបាយកាណ៍លទ្ធផល ទៅតាមទំហំតម្លៃនៅសល់នៃទ្រព្យសកម្មនោះ ដែលមិនលើសតម្លៃនៅសល់ដែលបានកំណត់ កាត់កងនឹងរំលស់ ប្រសិនបើគេមិនបានកត់ត្រាការខាត ដែលបណ្តាលមកពីការថយចុះតម្លៃ ។

## ២.១០ ភតិសន្យា

ភតិសន្យាដែលភាគីម្ចាស់ទ្រព្យ នៅមានចំណែកហានិភ័យ និងផលកម្មសិទ្ធិជាសារវន្តលើទ្រព្យសកម្ម ត្រូវបានចាត់ថ្នាក់ជា ភតិសន្យាប្រតិបត្តិ ។ ការទូទាត់ភតិសន្យាប្រតិបត្តិ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរ លើរយៈពេលនៃភតិសន្យានោះ ។

## ២.១១ សំវិធានធន

សំវិធានធន ត្រូវបានកត់ត្រានៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចដែលធនាគារបានបង្កើតឡើងនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល និងនៅពេលដែលមានភាពប្រាកដថា នឹងមានតម្រូវការអោយមានការចំណាយធនធាន ដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មានបានយ៉ាងគួរអោយជឿជាក់ ។

នៅពេលដែលមានកាតព្វកិច្ចប្រហាក់ប្រហែលគ្នា ជាច្រើនកម្រិត នៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចទាំងនោះ ត្រូវបានកំណត់ ដោយគិតទៅលើចំណាត់ថ្នាក់កាតព្វកិច្ចទាំងមូល ។ សំវិធានធន ត្រូវបានគេកត់ត្រា ទោះបីជាលំហូរចេញនៃធាតុណាមួយនៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះ មានចំនួនតិចតួចក៏ដោយ ។

សំវិធានធន ត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ន នៃចំណាយដែលរំពឹងថានឹងត្រូវការដើម្បីទូទាត់កាតព្វកិច្ច ដោយប្រើអត្រាអប្បហារមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ន នៃតម្លៃពេលវេលា ទឹកប្រាក់ និងហានិភ័យជាក់លាក់ផ្សេងៗ នៃកាតព្វកិច្ចនោះ ។ ការកើនឡើងនៃសំវិធានធន ដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់ ។

## ២.១២ អត្ថប្រយោជន៍និយោជិត

### ក. មូលនិធិសោធននិវត្តន៍

ធនាគារផ្តល់ជូនអត្ថប្រយោជន៍ផ្សេងៗ ជូននិយោជិតរបស់ខ្លួន តាមរយៈមូលនិធិសោធននិវត្តន៍ ( គំរោងមូលនិធិចូលរួមដែលបានកំណត់) ។ មូលនិធិនេះ មានប្រភពដូចខាងក្រោម :

i. ការចូលរួមប្រចាំខែ ដែលផ្អែកតាមប្រាក់បៀវត្សប្រចាំខែរបស់និយោជិតម្នាក់ៗ ៥% និងការចូលរួមចំណែករបស់ធនាគារ ៥% ។ ការចូលរួមរបស់ធនាគារ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល ។
ii. ធនាគារផ្តល់ការប្រាក់ចំនួន ៦% ក្នុងមួយឆ្នាំ លើសមតុល្យបង្គរនៃមូលនិធិសោធននិវត្តន៍នេះ ។

មូលនិធិសោធននិវត្តន៍នេះ នឹងត្រូវទូទាត់ជូននិយោជិត ដែលបានចូលរួមក្នុង មូលនិធិនេះ នៅពេលដែលពួកគេឈប់ធ្វើការងារនៅធនាគារ ។

### ខ. អត្ថប្រយោជន៍ផ្សេងៗក្រោយពេលបញ្ចប់កិច្ចសន្យាការងារ

នៅពេលបញ្ចប់ការងារពីធនាគារ និយោជិតម្នាក់ៗមានសិទ្ធិទទួលអត្ថប្រយោជន៍បន្ថែមទៀត ក្រៅពីមូលនិធិសោធននិវត្តន៍ ខាងលើនេះ តាមរយៈការទទួលបាននូវការទូទាត់សរុបមួយ នៃប្រាក់បៀវត្សប្រចាំខែរបស់និយោជិតចុងក្រោយដុល គុណនឹងចំនួនណាមួយដែលទាបជាងគេ រវាងចំនួនឆ្នាំនៃអតីតភាពការងារ ឬគុណនឹង១២ឆ្នាំ ។

## ២.១៣ ចំណូល និងចំណាយការប្រាក់

ចំណូលការប្រាក់បានពីឥណទាន និងបុរេប្រទានអតិថិជន សមតុល្យនៅធនាគារកណ្តាល និងនៅធនាគារផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ លើកលែងតែមានការសង្ស័យគួរអោយបារម្ភ ចំពោះការប្រមូលប្រាក់មកវិញ ដែលក្នុងករណីនេះ ការប្រាក់នឹងត្រូវបានព្យួរ រហូតដល់បានទទួលសាច់ប្រាក់ជាក់ស្តែង ។ គោលការណ៍ស្តីពីការព្យួរការប្រាក់ គឺអនុលោមស្របតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល ស្តីពីការព្យួរការប្រាក់លើឥណទានមិនដំណើរការ និងសំវិធានធនឥណទាន និងបុរេប្រទានបាត់បង់ ។

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់ ធនាគារ និងប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ ។

## ២.១៤ ចំណូលកម្រៃ និងជើងសារ

ចំណូលកម្រៃ និងជើងសារ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ នៅពេលដែលប្រតិបត្តិការនោះបានកើតឡើង ។ ចំណូលកម្រៃ និងជើងសារ រួមមានចំណូលបានពីសេវាផ្ទេរប្រាក់ចេញ-ចូលធនាគារ លិខិតឥណទានដែលទាក់ទងនឹងពាណិជ្ជកម្ម និងការប្រមូលផលបត្រ ។

កម្រៃ និង កិច្ចសន្យាផ្សេងៗលើការផ្តល់ឥណទាន ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល លើរយៈពេលឥណទាននោះ ។ កម្រៃឥណទាន ដែល មិនបានដករំលស់ ត្រូវបានបង្ហាញដោយបានកាត់បន្ថយទៅលើឥណទាន និងបុរេប្រទានអតិថិជន ។

## ២.១៥ ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ និងពន្ធពន្យារ

ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ ត្រូវបានគណនាតាមច្បាប់ពន្ធដារដែលបានអនុម័តរួចរាល់ ឬបានអនុម័តរួចមួយផ្នែកធំ ក្នុងព្រះរាជាណាចក្រកម្ពុជា គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ ជាទីកន្លែងដែលធនាគារធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញជាប់ពន្ធ ។ ពន្ធពន្យារលើប្រាក់ចំណេញ ត្រូវបានធ្វើសំវិធានធនពេញលេញ ដោយប្រើវិធីសាស្ត្រទ្រព្យអកម្ម លើលម្អៀងបណ្តោះអាសន្ន ដែលកើតមាន រវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងទ្រព្យអកម្ម និងតម្លៃនៅសល់របស់ទ្រព្យសកម្ម និងទ្រព្យអកម្មទាំងនោះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា ទៅតាមទំហំនៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលមានធៀប នឹងលម្អៀងបណ្តោះអាសន្នដែលអាចប្រើប្រាស់បាន ។

## ២.១៦ កិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗ

នៅក្នុងដំណើរការធម្មតានៃអាជីវកម្ម ធនាគារចុះកិច្ចសន្យាដែលពាក់ព័ន្ធនឹងឥណទានផ្សេងៗរួមមាន កិច្ចសន្យាឥណទាន លិខិតឥណទាន និងប័ណ្ណធានាផ្សេងៗ ។ គោលការណ៍គណនេយ្យ និងវិធីសាស្ត្រសំវិធានធនមានលក្ខណៈស្រដៀងគ្នាចំពោះឥណទានផ្សេងៗ ដូចបានកត់សម្គាល់ខាងលើ ។ សំវិធានធនជាក់លាក់ចំពោះកិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗទាំងនោះ នឹងត្រូវបានកត់ត្រា នៅពេលដែលវាទំនងជាមានការបាត់បង់ ។

## ២.១៧ តួលេខគត់

បណ្តាតួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ចំពោះតួលេខជាប្រាក់ដុល្លារអាមេរិក ត្រូវបានកាត់ខ្ទង់គត់ និងតួលេខជាប្រាក់រៀល ត្រូវបានកាត់ខ្ទង់គត់ពាន់រៀល ។

## ៣. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

ធនាគារធ្វើការប៉ាន់ប្រមាណ ការសន្មត និងការវិនិច្ឆ័យ ដែលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលបានរាយការណ៍ ។ ការប៉ាន់ប្រមាណ និងការវិនិច្ឆ័យ ត្រូវបានវាយតំលៃជាបន្តបន្ទាប់ ដោយផ្អែកលើបទពិសោធន៍នាពេលកន្លងមក និងកត្តាផ្សេងៗ ដូចជាការរំពឹងទុកអំពីហេតុការណ៍នាពេលអនាគត ដែលគេជឿថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ។

## ក. ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ នៃឥណទាន និងបុរេប្រទាន

ធនាគារ បានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទាន តាមប្រកាសលេខ ធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន សម្រាប់ស្ថាប័នធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ដែលចេញដោយធនាគារកណ្តាល ។ ធនាគារកណ្តាល តម្រូវអោយធនាគារពាណិជ្ជទាំងឡាយ ធ្វើចំណាត់ថ្នាក់សំពៀតឥណទាន បុរេប្រទាន និងទ្រព្យសកម្មប្រហាក់ប្រហែលរបស់ខ្លួន ជាប្រាំថ្នាក់ ហើយកម្រិតអប្បបរមានៃសំវិធានធនជាក់លាក់ត្រូវបានធ្វើឡើង អាស្រ័យតាមចំណាត់ថ្នាក់ពាក់ព័ន្ធ ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ ។ ក្នុងការធ្វើចំណាត់ថ្នាក់ឥណទាន ធនាគារពិចារណាទៅលើកត្តាពាក់ព័ន្ធទាំងអស់ ដែលអាចមានផលប៉ះពាល់ដល់លទ្ធភាពក្នុងការសងប្រាក់ នៃភាគីដៃគូរបស់ខ្លួន ។

## ខ. ពន្ធលើប្រាក់ចំណេញ

ពន្ធ ត្រូវបានគណនាតាមមូលដ្ឋានបំណាកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ប៉ុន្តែបទប្បញ្ញត្តិទាំងអស់នេះ មានការផ្លាស់ប្តូរ ពីមួយគ្រាទៅមួយគ្រា ហើយការសម្រេចជាចុងក្រោយលើចំនួនពន្ធ នឹងធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យចុងក្រោយ ដោយអគ្គនាយកដ្ឋានពន្ធដារ ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយ ខុសគ្នាពីចំនួនពន្ធដែលបានកត់ត្រាពីដំបូង ភាពលម្អៀងនេះនឹងធ្វើអោយប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធនពន្ធពន្យារ ក្នុងឆ្នាំដែលការកំណត់ពន្ធបានធ្វើឡើង ។

## ៤. សមតុល្យនៅធនាគារកណ្តាល

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| គណនីប្រាក់បញ្ញើមានកាលកំណត់ | 90,900,000 | 368,417,700 | 110,300,000 | 459,840,700 |
| គណនីទុនបម្រុង | 30,620,577 | 124,105,199 | 26,318,254 | 109,720,801 |
| គណនីចរន្ត | 36,141,256 | 146,480,510 | 7,523,962 | 31,367,398 |
| គណនីប្រាក់តម្កល់ធានាដើមទុន | 3,575,000 | 14,489,475 | 1,300,000 | 5,419,700 |
| | 161,236,833 | 653,492,884 | 145,442,216 | 606,348,599 |

### (ក) គណនីទុនបម្រុង

ទុនបម្រុងកាតព្វកិច្ច គឺជាទុនបម្រុងអប្បបរមា ដែលត្រូវបានគណនាតាមអត្រា ៨% នៃប្រាក់បញ្ញើអតិថិជនជាប្រាក់រៀល និង ១២% នៃប្រាក់បញ្ញើអតិថិជនជារូបិយប័ណ្ណផ្សេងៗ ។ ទុនបម្រុងកាតព្វកិច្ច ៤% នៃប្រាក់បញ្ញើអតិថិជនជារូបិយប័ណ្ណផ្សេងៗទៀត ក្រៅពីប្រាក់រៀល ទទួលបានអត្រាការប្រាក់ ៣/៤នៃអត្រា SIBOR ១ខែ ទន្ទឹមនឹងនោះ ទុនបម្រុងកាតព្វកិច្ច ៨% ទៀត និងទុនបម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើអតិថិជនជាប្រាក់រៀល ពុំមានការប្រាក់ទេ ។

### (ខ) ប្រាក់តម្កល់ធានាដើមទុន

យោងតាមប្រកាសលេខ ធ៧-០១-១៣៦ប្រ.ក. ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ចេញដោយធនាគារកណ្តាល ស្តីពីប្រាក់តម្កល់ធានាលើដើមទុន តម្រូវអោយធនាគារតម្កល់ប្រាក់ចំនួន ១០% នៃដើមទុនចុះបញ្ជីនៅធនាគារកណ្តាល ។ ប្រាក់តម្កល់នេះ មិនសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ ហើយនឹងត្រូវប្រគល់អោយធនាគារវិញ នៅពេលដែលធនាគារស្ម័គ្រចិត្ត បញ្ឈប់ប្រតិបត្តិការរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### (គ) អត្រាការប្រាក់

គណនីចរន្ត និងគណនីទុនបម្រុងជាប្រាក់រៀល គឺជាគណនីដែលមិនមានការប្រាក់ ។ អត្រាការប្រាក់ប្រចាំឆ្នាំនៃសមតុល្យនៅ ធនាគារកណ្តាល ត្រូវបានសង្ខេបដូចខាងក្រោម :

| | 2010 | 2009 |
|---|---|---|
| ប្រាក់បញ្ញើមានកាលកំណត់ | 0.11% - 0.26% | 0.12% - 1.64% |
| ប្រាក់តម្កល់ធានាដើមទុន | | |
| ជាប្រាក់រៀល | 0% | 0% |
| ជាប្រាក់ដុល្លារអាមេរិក | 0.11% - 0.12% | 0.28% - 0.68% |

## ៥.សមតុល្យនៅធនាគារផ្សេងៗ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| គណនីចរន្ត | 13,334,711 | 54,045,584 | 10,924,761 | 45,545,329 |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | 4,420,000 | 17,914,260 | 4,200,000 | 17,509,800 |
| | 17,754,711 | 71,959,844 | 15,124,761 | 63,055,129 |

អត្រាការប្រាក់ប្រចាំឆ្នាំនៃសមតុល្យនៅធនាគារផ្សេងៗ ត្រូវបានសង្ខេបដូចខាងក្រោម :

| | 2010 | 2009 |
|---|---|---|
| ប្រាក់បញ្ញើមានកាលកំណត់ | | |
| ជាប្រាក់រៀល | 0% | 0% |
| ជាប្រាក់ដុល្លារអាមេរិក | 1% - 4.5% | 4.5% - 6.5% |
| ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារផ្សេងៗ | 0.0357% - 0.10% | 0.05% - 0.773% |

## ៦. ឥណទាន និងបុរេប្រទានអតិថិជន

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ឥណទានពាណិជ្ជកម្ម : | | | | |
| ឥណទានរយៈពេលខ្លី | 8,630,000 | 34,977,390 | 3,806,127 | 15,867,743 |
| ឥណទានរយៈពេលវែង | 74,985,826 | 303,917,553 | 41,439,028 | 172,759,308 |
| ឥណទានវិបារូបន៍ | 47,025,135 | 190,592,872 | 47,882,579 | 199,622,472 |
| ឥណទានផ្តល់អោយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុ | 10,761,659 | 43,617,004 | 11,661,550 | 48,617,002 |
| | 141,402,620 | 573,104,819 | 104,789,284 | 436,866,525 |
| ឥណទានអ្នកប្រើប្រាស់ : | | | | |
| ឥណទានបុគ្គលិក | 503,883 | 2,042,238 | 364,712 | 1,520,484 |
| ឥណទាន និងបុរេប្រទានអតិថិជនសរុប-ដុល | 141,906,503 | 575,147,057 | 105,153,996 | 438,387,009 |
| ការប្រាក់ត្រូវទទួល | 1,379,794 | 5,592,305 | 999,927 | 4,168,696 |
| ការប្រាក់បានព្យួរ | (1,323,423) | (5,363,833) | (1,575,199) | (6,567,005) |
| | 56,371 | 228,472 | (575,272) | (2,398,309) |
| សំវិធានធនបំណុលសង្ស័យ | (4,348,744) | (17,625,459) | (8,060,501) | (33,604,229) |
| កម្រៃកិច្ចសន្យាឥណទានដែលមិនបានដករំលស់ | (1,413,069) | (5,727,170) | (752,863) | (3,138,686) |
| | (5,761,813) | (23,352,629) | (8,813,364) | (36,742,915) |
| | 136,201,061 | 552,022,900 | 95,765,360 | 399,245,785 |

រាល់ឥណទានទាំងអស់ ត្រូវបានផ្តល់អោយអ្នកខ្ចីប្រាក់ជាជនជាតិខ្មែរ និងអង្គភាពដែលចុះបញ្ជីពាណិជ្ជកម្មនៅក្នុង ព្រះរាជាណាចក្រកម្ពុជា។

## (ក) សំវិធានធនឥណទានបាត់បង់

បម្រែបម្រួលសំវិធានធនបំណុលអាក្រក់ និងសង្ស័យ មានដូចខាងក្រោម :

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| គិតត្រឹមដើមឆ្នាំ | 8,060,501 | 33,604,229 | 3,617,412 | 14,762,658 |
| សំវិធានធនក្នុងឆ្នាំ | 1,364,139 | 5,528,855 | 8,303,602 | 34,617,717 |
| ឥណទានអាក្រក់ដែលបានជំរះចេញពីបញ្ជី | (3,683,423) | (14,928,913) | - | - |
| ឥណទានអាក្រក់ដែលប្រមូលបានមកវិញ | (1,392,473) | (5,643,693) | (3,860,513) | (16,094,479) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (935,019) | - | 318,333 |
| គិតត្រឹមចុងឆ្នាំ | 4,348,744 | 17,625,459 | 8,060,501 | 33,604,229 |

## (ខ) វិភាគតាមចំណាត់ថ្នាក់ឥណទាន

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ឥណទានស្តង់ដារ | | | | |
| មានការធានា | 134,402,300 | 544,732,522 | 82,347,325 | 343,305,998 |
| មិនមានការធានា | - | - | 2,091,292 | 8,718,596 |
| ឥណទានឃ្លាំមើល | | | | |
| មានការធានា | 3,302,491 | 13,384,996 | 14,777,322 | 61,606,655 |
| មិនមានការធានា | - | - | - | - |
| ឥណទានក្រោមស្តង់ដារ | | | | |
| មានការធានា | - | - | 150,000 | 625,350 |
| មិនមានការធានា | - | - | - | - |
| ឥណទានសង្ស័យ | | | | |
| មានការធានា | 2,592,131 | 10,505,907 | - | - |
| មិនមានការធានា | - | - | - | - |
| ឥណទានបាត់បង់ | | | | |
| មានការធានា | 1,609,581 | 6,523,632 | 5,788,057 | 24,130,410 |
| មិនមានការធានា | - | - | - | - |
| | 141,906,503 | 575,147,057 | 105,153,996 | 438,387,009 |

(គ) វិភាគតាមប្រភេទអាជីវកម្ម

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ផ្នែកសេវាកម្មផ្សេងៗ | 82,133,283 | 332,886,196 | 50,394,163 | 210,093,266 |
| ផ្នែកសំណង់ | 12,415,101 | 50,318,404 | 17,527,097 | 73,070,467 |
| ផ្នែកលក់ដុំ និងលក់រាយ | 11,473,809 | 46,503,348 | 10,970,851 | 45,737,478 |
| ផ្នែកអាជីវកម្មធនាគារ និងហិរញ្ញវត្ថុ | 13,135,461 | 53,238,023 | 11,694,106 | 48,752,728 |
| ផ្នែកអាហារណេកម្ម និង នីហរណេកម្ម | 4,449,191 | 18,032,571 | 4,990,233 | 20,804,281 |
| ផ្នែកកសិកម្ម | 2,736,753 | 11,092,060 | 4,545,743 | 18,951,203 |
| ផ្នែកគីមីសាស្ត្រ និងបរិក្ខារផ្នែកវេជ្ជសាស្ត្រ | 2,459,675 | 9,969,063 | 1,675,019 | 6,983,154 |
| ផ្នែកអ្នកប្រើប្រាស់ | 9,097,292 | 36,871,324 | 882,633 | 3,679,697 |
| ផ្នែកផ្សេងៗ | 4,005,938 | 16,236,068 | 2,474,151 | 10,314,735 |
| | 141,906,503 | 575,147,057 | 105,153,996 | 438,387,009 |

(ឃ) វិភាគតាមកាលកំណត់

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ១ ខែ | 4,861,750 | 19,704,673 | 1,327,680 | 5,535,098 |
| ពី ១ ខែ ដល់ ៣ ខែ | 7,786,599 | 31,559,086 | 8,832,598 | 36,823,101 |
| ពី ៣ ខែ ដល់ ១២ ខែ | 54,334,276 | 220,216,821 | 52,094,546 | 217,182,162 |
| ពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ | 68,428,510 | 277,340,751 | 34,971,115 | 145,794,578 |
| ពី ៥ ឆ្នាំ ឡើងទៅ | 6,495,368 | 26,325,726 | 7,928,057 | 33,052,070 |
| | 141,906,503 | 575,147,057 | 105,153,996 | 438,387,009 |

(ង) វិភាគតាមប្រភេទរូបិយប័ណ្ណ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ប្រាក់ដុល្លារអាមេរិក | 127,564,722 | 517,019,819 | 91,860,678 | 382,967,166 |
| ប្រាក់រៀល | 14,341,781 | 58,127,238 | 13,293,318 | 55,419,843 |
| | 141,906,503 | 575,147,057 | 105,153,996 | 438,387,009 |

(ច) វិភាគតាមទំនាក់ទំនង

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ឥណទានបុគ្គលិក | 503,883 | 2,042,238 | 364,712 | 1,520,484 |
| ភាគីមិនមែនសម្ព័ន្ធញាតិ | 141,402,620 | 573,104,819 | 104,789,284 | 436,866,525 |
| | 141,906,503 | 575,147,057 | 105,153,996 | 438,387,009 |

(ឆ) វិភាគតាមហានិភ័យឥណទាន

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ហានិភ័យធំ | 23,664,197 | 95,910,990 | 37,621,961 | 156,845,955 |
| ហានិភ័យតូច | 118,242,306 | 479,236,067 | 67,532,035 | 281,541,054 |
| | 141,906,503 | 575,147,057 | 105,153,996 | 438,387,009 |

(ជ) វិភាគតាមអត្រាការប្រាក់

ឥណទាន និងបុរេប្រទានអតិថិជនទាំងអស់នេះ មានអត្រាការប្រាក់ប្រចាំឆ្នាំ ដូចខាងក្រោម :

| | 2010 | 2009 |
|---|---|---|
| ឥណទាន និងបុរេប្រទាន ជាប្រាក់រៀល | 9% - 14.40% | 10% - 14.40% |
| ឥណទាន និងបុរេប្រទាន ជាប្រាក់ដុល្លារអាមេរិក | 7% - 15% | 7% - 15% |

## ៧. ទ្រព្យសម្បត្តិរឹបអូស

ទ្រព្យសម្បត្តិរឹបអូស រួមមានអចលនទ្រព្យផ្សេងៗ ដែលធនាគារបានរឹបអូសពីវត្ថុបញ្ចាំ ដែលជាផ្នែកមួយនៃការទូទាត់បំណុល ដោយសារអតិថិជនខកខានមិនបានសងឥណទាន និងបុរេប្រទាន។

## ៨. ទ្រព្យសកម្មអរូបី

| | កម្មវិធីកុំព្យូទ័រ ដុល្លារអាមេរិក | កម្មវិធីកុំព្យូទ័រ កំពុងប្រើប្រាស់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩** | | | |
| ថ្លៃដើម | 317,273 | 174,454 | 491,727 |
| រំលស់បង្គរ | (106,665) | - | (106,665) |
| តម្លៃចុះបញ្ជីសុទ្ធ | 210,608 | 174,454 | 385,062 |

| | កម្មវិធីកុំព្យូទ័រ ដុល្លារអាមេរិក | កម្មវិធីកុំព្យូទ័រ កំពុងប្រើប្រាស់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | 210,608 | 174,454 | 385,062 |
| ការទិញបន្ថែម | 63,747 | 86,884 | 150,631 |
| ការផ្ទេរ | 259,193 | (259,193) | - |
| រំលស់ | (96,299) | - | (96,299) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | 437,249 | 2,145 | 439,394 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | | | |
| ថ្លៃដើម | 641,478 | 2,145 | 643,623 |
| រំលស់បង្គរ | (204,229) | - | (204,229) |
| តម្លៃចុះបញ្ជីសុទ្ធ | 437,249 | 2,145 | 439,394 |
| *សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម)* | 1,822,891 | 8,943 | 1,831,834 |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | 437,249 | 2,145 | 439,394 |
| ការទិញបន្ថែម | 32,340 | 1,215 | 33,555 |
| រំលស់ | (93,265) | - | (93,265) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | 376,324 | 3,360 | 379,684 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | |
| ថ្លៃដើម | 673,818 | 3,360 | 677,178 |
| រំលស់បង្គរ | (297,494) | - | (297,494) |
| តម្លៃចុះបញ្ជីសុទ្ធ | 376,324 | 3,360 | 379,684 |
| *សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម)* | 1,525,241 | 13,618 | 1,538,859 |

## ៩. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ដីធ្លី<br>ដុល្លារអាមេរិក | អគារ<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម<br>និងបរិក្ខារ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | ទ្រព្យសកម្ម<br>កំពុងសាងសង់<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩** | | | | | | |
| ថ្លៃដើម | 221,464 | 63,343 | 381,954 | 281,311 | 1,014,398 | 1,962,470 |
| រំលស់បង្គរ | - | - | (319,772) | (93,195) | - | (412,967) |
| តម្លៃចុះបញ្ជីសុទ្ធ | 221,464 | 63,343 | 62,182 | 188,116 | 1,014,398 | 1,549,503 |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | 221,464 | 63,343 | 62,182 | 188,116 | 1,014,398 | 1,549,503 |
| ការទិញបន្ថែម | - | 3,658 | 284,568 | 154,889 | 71,078 | 514,193 |
| ការផ្ទេរ | - | 316,301 | 713,842 | 33,454 | (1,063,597) | - |
| ការលក់ចេញ - សុទ្ធ | - | - | - | (69,182) | (3,798) | (72,980) |
| រំលស់ | - | (14,237) | (194,407) | (54,030) | - | (262,674) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | 221,464 | 369,065 | 866,185 | 253,247 | 18,081 | 1,728,042 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | | | | | | |
| ថ្លៃដើម | 221,464 | 383,302 | 1,380,364 | 337,546 | 18,081 | 2,340,757 |
| រំលស់បង្គរ | - | (14,237) | (514,179) | (84,299) | - | (612,715) |
| តម្លៃចុះបញ្ជីសុទ្ធ | 221,464 | 369,065 | 866,185 | 253,247 | 18,081 | 1,728,042 |
| សមមូលនឹងពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | 923,283 | 1,538,632 | 3,611,125 | 1,055,787 | 75,380 | 7,204,207 |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | 221,464 | 369,065 | 866,185 | 253,247 | 18,081 | 1,728,042 |
| ការទិញបន្ថែម | 1,530 | 32,476 | 278,220 | 44,000 | 205,689 | 561,915 |
| រំលស់ | - | (66,386) | (191,633) | (66,222) | - | (324,241) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | 222,994 | 335,155 | 952,772 | 231,025 | 223,770 | 1,965,716 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | | | |
| ថ្លៃដើម | 222,994 | 415,778 | 1,658,584 | 381,546 | 223,770 | 2,902,672 |
| រំលស់បង្គរ | - | (80,623) | (705,812) | (150,521) | - | (936,956) |
| តម្លៃចុះបញ្ជីសុទ្ធ | 222,994 | 335,155 | 952,772 | 231,025 | 223,770 | 1,965,716 |
| សមមូលនឹងពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | 903,795 | 1,358,383 | 3,861,585 | 936,344 | 906,940 | 7,967,047 |

## ១០. ទ្រព្យសកម្មផ្សេងៗ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| សមតុល្យមូលប្បទានបត្របរទេស មូលប្បទានបត្រអ្នកដំណើរ និងប័ណ្ណឥណទានសម្រាប់បេឡានិច្ច័យ : | | | | |
| - កំពុងផ្ញើរ | 23,560 | 95,489 | 18,843 | 78,557 |
| - នៅក្នុងដៃ | 18,300 | 74,170 | 60,132 | 250,690 |
| ចំណូលការប្រាក់បង្ករ | 78,904 | 319,798 | 189,066 | 788,216 |
| បុរេប្រទាន និងការបង់មុន | 219,558 | 889,868 | 215,898 | 900,079 |
| | 340,322 | 1,379,325 | 483,939 | 2,017,542 |

## ១១. ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ប្រាក់បញ្ញើរបស់ធនាគារក្នុងស្រុក : | | | | |
| គណនីចរន្ត | 713,086 | 2,890,138 | 460,178 | 1,918,482 |
| គណនីប្រាក់បញ្ញើសន្សំ | 210,593 | 853,533 | 93,193 | 388,522 |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | 12,537,724 | 50,815,395 | 13,066,938 | 54,476,064 |
| | 13,461,403 | 54,559,066 | 13,620,309 | 56,783,068 |

គណនីចរន្ត មិនមានការប្រាក់ទេ ។ គណនីប្រាក់បញ្ញើសន្សំ និងគណនីប្រាក់បញ្ញើមានកាលកំណត់ មានអត្រាការប្រាក់ដូចខាងក្រោម :

| | 2010 | 2009 |
|---|---|---|
| ប្រាក់បញ្ញើសន្សំ | 0.75% - 1.5% | 0.75% - 1.5% |
| ប្រាក់បញ្ញើមានកាលកំណត់ | 1% - 5.5% | 1% - 5.5% |

## ១២. ប្រាក់បញ្ញើរបស់អតិថិជន

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| គណនីចរន្ត | 53,675,294 | 217,545,967 | 55,763,767 | 232,479,145 |
| គណនីប្រាក់បញ្ញើសន្សំ | 100,632,669 | 407,864,207 | 75,345,057 | 314,113,543 |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | 107,316,369 | 434,953,244 | 79,687,593 | 332,217,575 |
| គណនីប្រាក់បញ្ញើមានកម្រិត | 1,445,251 | 5,857,602 | 1,475,036 | 6,149,425 |
| គណនីប្រាក់បញ្ញើផ្សេងៗ | 399,882 | 1,620,722 | 576,334 | 2,402,736 |
| | 263,469,465 | 1,067,841,742 | 212,847,787 | 887,362,424 |

គណនីប្រាក់បញ្ញើមានកម្រិត គឺជាសមតុល្យសរុបនៃប្រាក់បញ្ញើរបស់អតិថិជន ដែលមិនមានការប្រាក់ សម្រាប់ការធានាលើលិខិតឥណទាន និងលិខិតធានាផ្សេងៗ ដែលនៅមិនទាន់ទូទាត់គិតត្រឹមដំណាច់ឆ្នាំ (កំណត់សម្គាល់ ២៦)។ គណនីប្រាក់បញ្ញើផ្សេងៗ ភាគច្រើនគឺជាគណនីរបស់អតិថិជនដែលកំពុងផ្ទេរ និងមូលប្បទានបត្រធានាចំណាយ សម្រាប់ការទូទាត់នានា។

ប្រាក់បញ្ញើរបស់អតិថិជនមានការប្រាក់ ដូចខាងក្រោម :

| | 2010 | 2009 |
|---|---|---|
| គណនីចរន្ត | 0% | 0% |
| គណនីប្រាក់បញ្ញើសន្សំ : | | |
| ប្រាក់ដុល្លារអាមេរិក | 0.75% -1.5% | 0.75% -1.5% |
| ប្រាក់រៀល | 1.5% - 2% | 1.5% - 2% |
| គណនីប្រាក់បញ្ញើមានកាលកំណត់ ជាប្រាក់ដុល្លារអាមេរិក ដែលមានរយៈពេល : | | |
| ១ ខែ | 1% - 2% | 1% - 2% |
| ៣ ខែ | 3% | 3% |
| ៦ ខែ | 4% - 4.5% | 4% - 4.5% |
| ១២ ខែ | 5% - 5.5% | 5% - 5.5% |
| គណនីប្រាក់បញ្ញើមានកាលកំណត់ ជាប្រាក់រៀល ដែលមានរយៈពេល : | | |
| ៣ ខែ | 4.50% | 4.50% |
| ៦ ខែ | 5.50% | 5.50% |
| ១២ ខែ | 6.50% | 6.50% |
| ប្រាក់បញ្ញើមានកម្រិត | 0% | 0% |

## ១៣. ទ្រព្យអកម្មផ្សេងៗ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ការប្រាក់ត្រូវបង់បង្គរ | 1,662,290 | 6,737,261 | 1,444,397 | 6,021,691 |
| ពន្ធបង្គរ | 44,269 | 179,422 | 40,267 | 167,873 |
| ទ្រព្យអកម្មផ្សេងៗ | 744,667 | 3,018,138 | 691,969 | 2,884,819 |
| | 2,451,226 | 9,934,821 | 2,176,633 | 9,074,383 |

## ១៤. អត្ថប្រយោជន៍ក្រោយពេលបញ្ចប់កិច្ចសន្យាការងារ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| កាតព្វកិច្ចមូលនិធិសោធននិវត្តន៍ | 584,068 | 2,367,228 | 474,891 | 1,979,821 |
| ការផ្តល់អត្ថប្រយោជន៍ផ្សេងៗ ក្រោយពេលបញ្ចប់កិច្ចសន្យាការងារ | 256,903 | 1,041,227 | 256,903 | 1,071,028 |
| | 840,971 | 3,408,455 | 731,794 | 3,050,849 |

បម្រែបម្រួលនៃកាតព្វកិច្ចមូលនិធិសោធននិវត្តន៍ មានដូចខាងក្រោម ៖

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ដើមគ្រា | 474,891 | 1,979,821 | 410,744 | 1,676,246 |
| ការបន្ថែមក្នុងឆ្នាំ ៖ | | | | |
| ការចូលរួមរបស់បុគ្គលិក ៥% | 46,010 | 186,479 | 40,210 | 167,635 |
| ការចូលរួមរបស់ធនាគារ ៥% | 46,337 | 187,804 | 40,210 | 167,635 |
| ការប្រាក់ (កំណត់សម្គាល់ ១៧) | 31,556 | 127,896 | 26,115 | 108,874 |
| ការទូទាត់ | (14,726) | (59,684) | (42,388) | (176,716) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (55,088) | - | 36,147 |
| ចុងគ្រា | 584,068 | 2,367,228 | 474,891 | 1,979,821 |

បម្រែបម្រួលនៃការផ្តល់អត្ថប្រយោជន៍ផ្សេងៗ ក្រោយពេលបញ្ចប់កិច្ចសន្យាការងារ មានដូចខាងក្រោម ៖

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ដើមគ្រា | 256,903 | 1,071,028 | 339,978 | 1,387,450 |
| ការបន្ថែមក្នុងឆ្នាំ | - | - | - | - |
| ការទូទាត់ | - | - | (83,075) | (346,339) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (29,801) | - | 29,917 |
| ចុងគ្រា | 256,903 | 1,041,227 | 256,903 | 1,071,028 |

## ១៩. ដើមទុន

ដើមទុនចុះបញ្ជីសរុបទាំងអស់មានចំនួន ៥.០០០ ភាគហ៊ុន (២០០៩ ៖ ៥.០០០ ភាគហ៊ុន) ដែលមានតម្លៃ ៧.១៥០ ដុល្លារអាមេរិក ក្នុង ១ ភាគហ៊ុន (២០០៩ ៖ ១ ភាគហ៊ុន មានតម្លៃ ២.៦០០ ដុល្លារអាមេរិក) ។ ភាគហ៊ុនទាំងអស់ ត្រូវបានបង់រួចរាល់ទាំងស្រុង ។

ការវិភាគអំពីភាគទុនិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ មានដូចខាងក្រោម ៖

| | % | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|---|
| ក្រុមហ៊ុន ING Holding Company Ltd. | 44 | 15,730,000 | 63,753,690 | 5,720,000 | 23,846,680 |
| ធនាគារកាណាឌីយ៉ា | 15.22 | 5,441,150 | 22,052,981 | 1,978,600 | 8,248,784 |
| លោកស្រី Kim Tiek | 15.39 | 5,501,925 | 22,299,302 | 2,000,700 | 8,340,918 |
| លោកស្រី Chhay Kimbouy | 15.39 | 5,501,925 | 22,299,302 | 2,000,700 | 8,340,918 |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 10 | 3,575,000 | 14,489,475 | 1,300,000 | 5,419,700 |
| សរុប | 100 | 35,750,000 | 144,894,750 | 13,000,000 | 54,197,000 |

ក្នុងអំឡុងឆ្នាំ ធនាគារបានបង្កើនដើមទុនចុះបញ្ជី របស់ខ្លួនពី ១៣.០០០.០០០ ដុល្លារអាមេរិក ទៅ ៣៩.៧៥០.០០០ ដុល្លារអាមេរិក (សមមូលនឹង ១៥០.០០០.០០០.០០០ រៀល គិតត្រឹមពេលបង្កើនដើមទុន) ដោយការផ្ទេរពីគណនីប្រាក់ចំណេញរក្សាទុក ទុនបម្រុងធានាលើដើមទុន និងទុនបម្រុងហានិភ័យធនាគារ (កំណត់សម្គាល់ ១៦) ។ ការបង្កើនដើមទុនរបស់ធនាគារ គឺដើម្បីបំពេញតាមតម្រូវការដើមទុនអប្បបរមា ដែលបានកំណត់ដោយធនាគារកណ្តាល ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ដើមទុនចុះ បញ្ជីរបស់ក្រុមហ៊ុនទាបជាងតម្រូវការដើមទុនអប្បបរមាចំនួន ១.២៥៩.៦២៣ ដុល្លារអាមេរិក បណ្តាលមកពីបម្រែបម្រួលអត្រាប្តូរប្រាក់រៀល ។ ប៉ុន្តែ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ធនាគារបានបង្កើនដើមទុនបន្ថែមរហូតដល់ ៣៧.៥០០.០០០ ដុល្លារអាមេរិក ដើម្បីអោយស្របតាមតម្រូវការរបស់ធនាគារកណ្តាល ។

## ១៦. ទុនបម្រុង

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---:|---:|---:|---:|
| ទុនបម្រុងធានាលើដើមទុន | - | - | 247,529 | 1,031,948 |
| ទុនបម្រុងហានិភ័យធនាគារ | 146,306 | 592,978 | 1,190,006 | 4,961,135 |
| ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ | 2,664,192 | 10,797,969 | 2,664,195 | 11,107,030 |
| ទុនបម្រុងទូទៅ | 135,091 | 547,524 | 135,092 | 563,199 |
| | 2,945,589 | 11,938,471 | 4,236,822 | 17,663,312 |

### ទុនបម្រុងធានាលើដើមទុន

ទុនបម្រុងធានាលើដើមទុន គឺជាមូលនិធិដែលត្រូវបានបង្កើតឡើង សម្រាប់ការបង្កើនដើមទុននាពេលអនាគត ។ មូលនិធិនេះត្រូវបានបែងចែកពីប្រាក់ចំណេញសុទ្ធបន្ទាប់ពីបង់ពន្ធ ក្នុងចំនួនសមមូលនឹង ១០% នៃប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ ។ យោងតាមការធ្វើវិសោធនកម្មលើលក្ខន្តិករបស់ធនាគារ ការបែងចែកទៅទុនបម្រុងធានាលើដើមទុន មិនត្រូវបានតម្រូវអោយធ្វើទៀតទេ ។

### ទុនបម្រុងទុកសម្រាប់ហានិភ័យធនាគារ

ទុនបម្រុងសម្រាប់ហានិភ័យធនាគារ ត្រូវបានគេបង្កើតឡើងជាបឋម ដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៅថ្ងៃ ទី១៩ ខែមិថុនា ឆ្នាំ២០០០ ។ គណនីនេះ គឺជាទុនបម្រុងសម្រាប់គោលបំណងទូទៅ ដែលបង្កើតឡើងដើម្បីគ្រប់គ្រងហានិភ័យក្នុងកិច្ចប្រតិបត្តិការអាជីវកម្មរបស់ធនាគារនៅក្នុងប្រទេសកម្ពុជា ជាពិសេស ហានិភ័យទូទៅដែលបណ្តាលមកពីការខកខានក្នុងការសងឥណទាន ការខាតបង់ដែលមិនបានគ្របដណ្តប់ដោយសវិធានធនឥណទានអាក្រក់ និងសង្ស័យ និងហានិភ័យរូបិយប័ណ្ណ ។

### ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ

ទុនបម្រុងនេះ គឺជាប្រាក់ចំណេញ ឬខាតដែលមិនទទួលស្គាល់ សម្រាប់ការិយបរិច្ឆេទមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ ដែលកើតពីការប្តូរទ្រព្យសកម្ម និងទ្រព្យអកម្មជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់ នាកាលបរិច្ឆេទតារាងតុល្យការដែលត្រូវបានទទួលស្គាល់ជាបឋម និងកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល ហើយបន្ទាប់មកត្រូវបានបែងចែកទៅក្នុងគណនីទុនបម្រុងនេះ ជាប្រាក់ចំណេញរក្សាទុកក្នុងឆ្នាំ ។ ធនាគារបានបញ្ឈប់ការបែងចែកប្រាក់ចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណ ដែលមិនទាន់ទទួលស្គាល់ទៅក្នុងគណនីទុនបម្រុង ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ គឺក្នុងឆ្នាំនៃការធ្វើឯកជនភាវូបនីយកម្មលើធនាគារ ។

### ទុនបម្រុងទូទៅ

កាលពីមុន គណនីទុនបម្រុងទូទៅ ត្រូវបានបែងចែកមកពីប្រាក់ចំណេញក្រោយបង់ពន្ធ មានចំនួនស្មើនឹង ៦% នៃប្រាក់ ចំណេញសុទ្ធក្រោយបង់ពន្ធ បន្ទាប់ពីដកទុនបម្រុងធានាលើដើមទុនរួច ។ ការប្រើប្រាស់ទុនបម្រុងទូទៅនោះ គឺជាបុព្វសិទ្ធិរបស់ក្រុមប្រឹក្សាភិបាល ។ អនុលោមតាមលក្ខន្តិករបស់ធនាគារ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៦ និងវិសោធនកម្មថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ធនាគារលែងបន្តការបែងចែកប្រាក់ចំណេញក្រោយបង់ពន្ធ ទៅក្នុងទុនបម្រុងទូទៅទៀតហើយ ។

## ១៧. ចំណូលការប្រាក់សុទ្ធ

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| **ចំណូលការប្រាក់ពី :** | | | | |
| ឥណទាន និងបុរេប្រទានអតិថិជន | 13,441,846 | 54,479,802 | 12,568,692 | 52,398,877 |
| សមតុល្យនៅធនាគារកណ្តាល | 155,311 | 629,475 | 219,325 | 914,366 |
| សមតុល្យនៅធនាគារផ្សេងៗ | 122,822 | 497,798 | 332,634 | 1,386,751 |
| ចំណូលការប្រាក់សរុប | 13,719,979 | 55,607,075 | 13,120,651 | 54,699,994 |
| **ចំណាយការប្រាក់លើ :** | | | | |
| ប្រាក់បញ្ញើមានកាលកំណត់ | 4,897,761 | 19,850,625 | 4,298,286 | 17,919,554 |
| ប្រាក់បញ្ញើសន្សំ | 769,767 | 3,119,866 | 684,213 | 2,852,484 |
| មូលនិធិសោធននិវត្តន៍ | 31,556 | 127,896 | 26,115 | 108,874 |
| ចំណាយការប្រាក់សរុប | 5,699,084 | 23,098,387 | 5,008,614 | 20,880,912 |
| **ចំណូលការប្រាក់សុទ្ធ** | 8,020,895 | 32,508,688 | 8,112,037 | 33,819,082 |

## ១៨. ចំណូលកម្រៃ និងជើងសារសុទ្ធ

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| **ចំណូលកម្រៃ និងជើងសារ :** | | | | |
| កម្រៃបានពីដំណើរការឥណទាន | 1,177,848 | 4,773,818 | 712,203 | 2,969,174 |
| កម្រៃបានពីការផ្ទេរប្រាក់ | 559,886 | 2,269,218 | 608,966 | 2,538,779 |
| កម្រៃជើងសារបានពីការចេញលិខិតឥណទាន និងប័ណ្ណធានា | 439,592 | 1,781,666 | 244,597 | 1,019,725 |
| កម្រៃជើងសារបានពីទូរលេខ SWIFT | 98,695 | 400,011 | 108,930 | 454,129 |
| កម្រៃកិច្ចសន្យាឥណទាន | 86,113 | 349,016 | 57,009 | 237,671 |
| កម្រៃបានពីសេវាផ្សេងៗ | 101,655 | 412,008 | 116,718 | 486,597 |
| ចំណូលកម្រៃ និងជើងសារសរុប | 2,463,789 | 9,985,737 | 1,848,423 | 7,706,075 |
| ចំណាយកម្រៃ និងជើងសារ | (198,618) | (804,999) | (145,019) | (604,584) |
| | 2,265,171 | 9,180,738 | 1,703,404 | 7,101,491 |

## ១៩. ចំណូលផ្សេងៗ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ចំណេញពីការប្តូររូបិយប័ណ្ណ | 55,848 | 226,352 | 462,289 | 1,927,283 |
| ចំណូលផ្សេងៗ | 259,284 | 1,050,878 | 63,705 | 265,586 |
| | 315,132 | 1,277,230 | 525,994 | 2,192,869 |

## ២០. ចំណាយផ្នែកបុគ្គលិក

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ប្រាក់បៀវត្ស និងប្រាក់ឈ្នួល | 1,406,463 | 5,700,395 | 1,246,199 | 5,195,404 |
| ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភផ្សេងៗ | 240,593 | 975,123 | 369,313 | 1,539,666 |
| អត្ថប្រយោជន៍ផ្សេងៗក្រោយពេលបញ្ចប់កិច្ចសន្យាការងារ | 98,273 | 398,300 | 127,990 | 533,589 |
| កម្រៃសម្រាប់ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល | 117,228 | 475,125 | 131,290 | 547,348 |
| មូលនិធិសោធននិវត្តន៍ | 46,262 | 187,500 | 41,110 | 171,388 |
| | 1,908,819 | 7,736,443 | 1,915,902 | 7,987,395 |

## ២១. ចំណាយរដ្ឋបាល និងចំណាយប្រតិបត្តិការ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| កម្រៃលើសេវាផ្នែកច្បាប់ និងតុលាការ | 128,468 | 520,681 | 555,499 | 2,315,875 |
| ចំណាយលើការទំនាក់ទំនង | 107,637 | 436,253 | 95,504 | 398,156 |
| ចំណាយលើការជួល | 114,666 | 464,741 | 85,550 | 356,658 |
| ចំណាយលើទឹក-ភ្លើង និងការិយាល័យ | 163,478 | 662,576 | 150,984 | 629,452 |
| ចំណាយលើសេវាវិជ្ជាជីវៈ | 115,600 | 468,527 | 114,992 | 479,402 |
| ចំណាយលើផ្នែកទីផ្សារ | 177,776 | 720,526 | 368,717 | 1,537,181 |
| ចំណាយលើការធានារ៉ាប់រង និងសន្តិសុខ | 53,068 | 215,085 | 58,208 | 242,669 |
| ចំណាយលើការដឹកជញ្ជូន | 58,548 | 237,295 | 38,571 | 160,802 |
| ចំណាយលើការជួសជុល និងថែទាំ | 144,331 | 584,974 | 69,738 | 290,738 |
| ចំណាយផ្សេងៗ | 386,888 | 1,568,056 | 587,646 | 2,449,896 |
| | 1,450,460 | 5,878,714 | 2,125,409 | 8,860,829 |

## ២២. ការប្រមូលបានមកវិញនៃឥណទានបាត់បង់ និងការប្រាក់ - សុទ្ធ

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| សំវិធានធនក្នុងឆ្នាំ (កំណត់សម្គាល់ ៦.ក) | (1,364,139) | (5,528,855) | (8,303,602) | (34,617,717) |
| ការប្រមូលបានមកវិញនៃឥណទានអាក្រក់ (កំណត់សម្គាល់ ៦.ក) | 1,392,473 | 5,643,693 | 3,860,513 | 16,094,479 |
| ការប្រមូលប្រាក់ដើមបានមកវិញនៃឥណទានអាក្រក់ ដែលបានជំរះចេញពីបញ្ជីរួច | 1,256,093 | 5,090,945 | 4,911,818 | 20,477,369 |
| | 1,284,427 | 5,205,783 | 468,729 | 1,954,131 |

## ២៣. ចំណាយពន្ធលើប្រាក់ចំណេញ

### ក. ចំណាយពន្ធលើប្រាក់ចំណេញ

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ចំណាយពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ | 1,654,117 | 6,704,136 | 1,278,966 | 5,332,009 |
| ពន្ធពន្យារទ្រព្យសកម្ម | 62,247 | 252,287 | (191,912) | (800,081) |
| | 1,716,364 | 6,956,423 | 1,087,054 | 4,531,928 |

### ខ. ការផ្ទៀងផ្ទាត់ចំណាយពន្ធលើប្រាក់ចំណេញ និងចំណេញគណនេយ្យ

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ | 8,108,840 | 32,865,130 | 6,409,880 | 26,722,790 |
| ពន្ធគណនាតាមអត្រា ២០% | 1,621,768 | 6,573,026 | 1,281,976 | 5,344,558 |
| ចំណាយដែលមិនអាចកាត់កងពន្ធ | 1,683 | 6,821 | 107,782 | 449,343 |
| ផលប៉ះពាល់នៃពន្ធពន្យារទ្រព្យសកម្ម ដែលមិនទាន់ទទួលស្គាល់ក្នុងឆ្នាំមុន | - | - | (305,067) | (1,271,824) |
| ផ្សេងៗ | 92,913 | 376,576 | 2,363 | 9,851 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 1,716,364 | 6,956,423 | 1,087,054 | 4,531,928 |

យោងតាមច្បាប់ពន្ធដារកម្ពុជា ធនាគារមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ តាមចំនួនមួយណាដែលខ្ពស់ជាង រវាងពន្ធលើប្រាក់ចំណេញ តាមអត្រា ២០% នៃប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាតាមអត្រា ១% នៃផលរបរ ។

ពន្ធលើប្រាក់ចំណេញ ត្រូវបានគណនាតាមមូលដ្ឋានប្រាក់ចំណេញជាប់ពន្ធ បន្ទាប់ពីកែសំរួលទៅលើលទ្ធផលហិរញ្ញវត្ថុ លើខ្ទង់ចំណាយមួយចំនួន ដោយអនុលោមទៅតាមប្បញ្ញត្តិផ្សេងៗ នៅក្នុងប្រទេសកម្ពុជា ។ ពន្ធផ្សេងៗទៀត ក្រៅពីពន្ធលើប្រាក់ចំណេញ ត្រូវបានកត់ត្រាក្នុងចំណាយប្រតិបត្តិការ ។

### គ. បញ្ហាពន្ធផ្សេងៗ

លិខិតប្រកាសពន្ធរបស់ធនាគារ ត្រូវត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារតាមការិយបរិច្ឆេទ ។ ដោយសារអាចមានការបកស្រាយខុសៗគ្នា ទៅលើផ្នែកខ្លះនៃច្បាប់ និងបទប្បញ្ញត្តិពន្ធដារ ហេតុនេះចំនួនពន្ធដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចមានការផ្លាស់ប្តូរនៅពេលក្រោយ អាស្រ័យលើការកំណត់ចុងក្រោយ ដោយអគ្គនាយកដ្ឋានពន្ធដារ ។

### ឃ. ពន្ធពន្យារ

ធនាគារ បានកត់ត្រាពន្ធពន្យារទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ពន្ធពន្យារទ្រព្យសកម្ម និងទ្រព្យអកម្ម ត្រូវបានកាត់កងនៅពេលដែលខ្លួនមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកាត់កងចំណាយពន្ធក្នុងគ្រា ជាមួយនឹងបំណុលពន្ធក្នុងគ្រា និងនៅពេលដែលពន្ធពន្យារទ្រព្យសកម្មនោះ ពាក់ព័ន្ធនឹងអាជ្ញាធរសារពើពន្ធដូចគ្នា ។ ចំនួនដែលត្រូវកាត់កង មានដូចខាងក្រោម ៖

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| **ពន្ធពន្យារទ្រព្យសកម្ម ៖** | | | | |
| ពន្ធពន្យារទ្រព្យសកម្ម ដែលត្រូវយកមកវិញក្នុងរយៈពេល១២ខែ | 168,194 | 681,690 | 238,817 | 995,628 |
| **ពន្ធពន្យារទ្រព្យអកម្ម ៖** | | | | |
| ពន្ធពន្យារទ្រព្យអកម្ម ដែលត្រូវយកមកវិញបន្ទាប់ពីរយៈពេល១២ខែ | (76,611) | (310,504) | (84,987) | (354,311) |
| ពន្ធពន្យារទ្រព្យសកម្ម – សុទ្ធ | 91,583 | 371,186 | 153,830 | 641,317 |

បម្រែបម្រួលដុលនៃគណនីពន្ធពន្យារទ្រព្យសកម្ម មានដូចខាងក្រោម ៖

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា | 153,830 | 641,317 | (38,082) | (155,413) |
| ពន្ធពន្យារទ្រព្យសកម្មបានប្រើក្នុងឆ្នាំ | (62,247) | (252,287) | 191,912 | 285,722 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (17,844) | - | 511,008 |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | 91,583 | 371,186 | 153,830 | 641,317 |

បម្រែបម្រួលដុលនៃពន្ធពន្យារទ្រព្យសកម្ម និងពន្ធពន្យារទ្រព្យអកម្ម ក្នុងអំឡុងឆ្នាំ ដោយមិនគិតដល់ការកាត់កងសមតុល្យ ផ្សេងៗ ក្នុងយុត្តាធិការដូចគ្នា មានដូចខាងក្រោម :

## ពន្ធពន្យារទ្រព្យសកម្ម

| | សវិធានធន ដុល្លារអាមេរិក | ចំណេញពីការប្តូរប្រាក់ដែលមិនទាន់ទទួលស្គាល់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩** | - | - | - |
| កត់ត្រាខាងខ្ទង់ឥណទានក្នុងរបាយការណ៍លទ្ធផល | 146,359 | 92,458 | 238,817 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | 146,359 | 92,458 | 238,817 |
| *សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម)* | 610,171 | 385,457 | 995,628 |
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១០** | 146,359 | 92,458 | 238,817 |
| កត់ត្រាខាងខ្ទង់ឥណទាន/(បន្ទុក)ក្នុងរបាយការណ៍លទ្ធផល | 21,835 | (92,458) | (70,623) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | 168,194 | - | 168,194 |
| *សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម)* | 681,690 | - | 681,690 |

## ពន្ធពន្យារទ្រព្យអកម្ម

រំលស់ពន្លឿន

| | សរុប ដុល្លារអាមេរិក |
|---|---|
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩** | (38,082) |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល | (46,905) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | (84,987) |
| *សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម)* | (354,311) |
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១០** | (84,987) |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល | 8,376 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | (76,611) |
| *សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម)* | (310,504) |

## ២៤. សាច់ប្រាក់ចេញពីប្រតិបត្តិការ

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ | 8,108,840 | 32,865,130 | 6,409,880 | 26,722,791 |
| **និយ័តកម្ម :** | | | | |
| សំវិធានធនឥណទានបាត់បង់ | 1,364,139 | 5,528,855 | 8,303,602 | 34,617,717 |
| ការប្រមូលបានមកវិញនៃឥណទានអាក្រក់ | (1,392,473) | (5,643,693) | (3,860,513) | (16,094,479) |
| សំវិធានធនអត្ថប្រយោជន៍ក្រោយពេលបញ្ចប់កិច្ចសន្យាការងារ | 123,903 | 502,179 | 83,211 | 346,906 |
| រំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | 417,506 | 1,692,152 | 358,973 | 1,496,558 |
| ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | - | - | 39,132 | 163,141 |
| ចំណូលការប្រាក់សុទ្ធ | (8,020,895) | (32,508,687) | (8,112,037) | (33,819,082) |
| ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទ្រព្យសកម្ម និងទ្រព្យអកម្មប្រតិបត្តិការ | 601,020 | 2,435,936 | 3,222,248 | 13,433,552 |
| *បម្រែបម្រួលទ្រព្យសកម្ម និងទ្រព្យអកម្មប្រតិបត្តិការ* | | | | |
| ឥណទាន និងបុរេប្រទានអតិថិជន | (40,687,706) | (164,907,272) | (10,335,593) | (43,089,087) |
| លម្អៀងនៃកម្រៃកិច្ចសន្យាឥណទាន | 660,206 | 2,675,815 | (114,173) | (475,987) |
| សមតុល្យនៅធនាគារផ្សេងៗ | - | - | 19,013,326 | 79,266,556 |
| ទ្រព្យសកម្មផ្សេងៗ | 143,617 | 582,080 | (218,222) | (909,768) |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | (158,906) | (644,046) | 7,884,007 | 32,868,425 |
| ប្រាក់បញ្ញើរបស់អតិថិជន | 50,621,678 | 205,169,661 | - | - |
| ទ្រព្យអកម្មផ្សេងៗ | 56,700 | 229,805 | (3,759,871) | (15,674,903) |
| សាច់ប្រាក់ចេញពីប្រតិបត្តិការ | 11,236,609 | 45,541,979 | 15,691,722 | 65,418,788 |

## ២៥. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | 6,828,014 | 27,673,941 | 8,202,157 | 34,194,793 |
| សមតុល្យនៅធនាគារកណ្តាល : | | | | |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | 90,900,000 | 368,417,700 | 110,300,000 | 459,840,700 |
| គណនីចរន្ត | 36,141,256 | 146,480,511 | 7,523,966 | 31,367,414 |
| សមតុល្យនៅធនាគារផ្សេងៗ | 13,554,711 | 54,937,244 | 10,924,761 | 45,545,329 |
| | 147,423,981 | 597,509,396 | 136,950,884 | 570,948,236 |

## ២៦. កិច្ចសន្យា និងទ្រព្យអកម្មយថាភាពផ្សេងៗ

### ក. កិច្ចសន្យាពន្យារឥណទាន លិខិតធានា និងទ្រព្យអកម្មហិរញ្ញវត្ថុផ្សេងៗ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ធនាគារមានចំនួនទឹកប្រាក់ក្នុងកិច្ចសន្យា នៃឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការ ដែលត្រូវពន្យារឥណទានជូនអតិថិជន លិខិតធានា និងកញ្ចប់ឥណទានផ្សេងៗ ដូចខាងក្រោម :

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| កញ្ចប់ឥណទានដែលបានអនុម័ត ប៉ុន្តែមិនទាន់បានប្រើប្រាស់ | 24,185,851 | 98,025,254 | 15,216,113 | 63,435,975 |
| លិខិតឥណទាន | 4,519,073 | 18,315,803 | 6,177,838 | 25,755,407 |
| លិខិតធានា | 5,023,818 | 20,361,534 | 5,230,946 | 21,807,814 |
| មូលប្បទានបត្រធ្វើបេឡានិច្ច័យ | 20,686 | 83,840 | 109,306 | 455,697 |
| | 33,749,428 | 136,786,431 | 26,734,203 | 111,454,893 |

### ខ. កិច្ចសន្យាពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ និងបរិក្ខារ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ធនាគារមានកិច្ចសន្យាមួយចំនួនដែលពាក់ព័ន្ធនឹងការជួលការិយាល័យថ្មី កម្មវិធីកុំព្យូទ័រសំខាន់ៗរបស់ធនាគារ និងសេវាកម្មពាក់ព័ន្ធផ្សេងៗទៀត ។

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| កិច្ចសន្យាដែលបានអនុម័ត និងបានចុះហត្ថលេខា មិនលើសពី ១ ឆ្នាំ | 29,113 | 117,995 | 76,646 | 319,537 |

### គ. កិច្ចសន្យាភតិសន្យា

ធនាគារគឺជាភាគីអ្នកជួល ហើយចំណាយភតិសន្យាអប្បបរមាសរុបនាពេលអនាគត ក្រោមភតិសន្យាប្រតិបត្តិមិនអាចលុបចោលបាន មានដូចខាងក្រោម :

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| មិនលើសពី ១ ឆ្នាំ | 36,372 | 147,416 | 68,000 | 283,492 |
| ពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ | 23,930 | 96,988 | 7,200 | 30,017 |
| | 60,302 | 244,404 | 75,200 | 313,509 |

## ២៧. ប្រតិបត្តិការភាគីសម្ព័ន្ធញាតិ

ក្រុមហ៊ុន ING Holding Company Ltd. មានភាគហ៊ុននៅក្នុងធនាគារចំនួន ៤៤% ធនាគារកាណាឌីយ៉ា មានភាគហ៊ុនចំនួន ១៥,២២% លោកស្រី Kim Tiek និងលោកស្រី Chhay Kimbouy មានភាគហ៊ុនម្នាក់ៗ ១៥,៣៩% ហើយភាគហ៊ុន ១០% ទៀត ជាកម្មសិទ្ធិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្នុងអំឡុងដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ប្រតិបត្តិការភាគីសម្ព័ន្ធញាតិ មានដូចខាងក្រោម ៖

### ក. ប្រាក់បញ្ញើរបស់ភាគីសម្ព័ន្ធញាតិ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| នាដើមឆ្នាំ | 1,105,304 | 4,608,012 | 592,743 | 2,418,984 |
| ប្រាក់បញ្ញើបានទទួលក្នុងឆ្នាំ | 8,682,450 | 35,189,970 | 5,042,738 | 21,023,175 |
| ប្រាក់បញ្ញើបានសងក្នុងឆ្នាំ | (7,824,587) | (31,713,051) | (4,530,177) | (18,886,308) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (128,215) | - | 52,161 |
| នាចុងឆ្នាំ | 1,963,167 | 7,956,716 | 1,105,304 | 4,608,012 |
| ចំណាយការប្រាក់លើប្រាក់បញ្ញើ | 51,061 | 206,950 | 3,111 | 12,696 |

ប្រាក់បញ្ញើសន្សំរបស់ក្រុមប្រឹក្សាភិបាល មានអត្រាការប្រាក់ ០,៧៥% (២០០៩ ៖ ០,៧៥%)។ គណនីទូទាត់របស់ធនាគារកាណាឌីយ៉ា មិនមានការប្រាក់ទេ។

### ខ. ប្រាក់បញ្ញើនៅភាគីសម្ព័ន្ធញាតិ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| នាដើមឆ្នាំ | 4,200,000 | 17,509,800 | 4,200,000 | 17,140,200 |
| ប្រាក់បញ្ញើបានទទួលក្នុងឆ្នាំ | 47,188,777 | 191,256,113 | 4,200,000 | 17,509,800 |
| ប្រាក់បញ្ញើបានសងក្នុងឆ្នាំ | (44,835,799) | (181,719,493) | (4,200,000) | (17,509,800) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (487,200) | - | 369,600 |
| នាចុងឆ្នាំ | 6,552,978 | 26,559,220 | 4,200,000 | 17,509,800 |
| ចំណូលការប្រាក់បានពីប្រាក់បញ្ញើ | 114,551 | 464,275 | 306,816 | 1,252,116 |

### គ. ការទូទាត់ជូនក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងសំខាន់ៗ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| កម្រៃប្រជុំរបស់ក្រុមប្រឹក្សាភិបាល | 27,637 | 112,013 | 20,742 | 86,473 |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | 626,873 | 2,540,715 | 789,416 | 3,291,075 |
| | 654,510 | 2,652,728 | 810,158 | 3,377,548 |

## ២៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

សកម្មភាពរបស់ធនាគារ ប្រឈមនឹងហានិភ័យហិរញ្ញវត្ថុផ្សេងៗមួយចំនួនដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមានហានិភ័យរូបិយប័ណ្ណបរទេស ហានិភ័យអត្រាការប្រាក់ និងហានិភ័យតម្លៃ) និងហានិភ័យសាច់ប្រាក់ងាយស្រួល ។ សកម្មភាព អាជីវកម្មហិរញ្ញវត្ថុភាគច្រើនប្រឈមមុខនឹងហានិភ័យ ហើយហានិភ័យប្រតិបត្តិការ គឺជាផលវិបាកដែលពិបាកជៀសរួចណាស់ក្នុង ដំណើរការអាជីវកម្ម ។

ធនាគារ មិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instrument) ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ និងការផ្តោះប្តូរអត្រាការប្រាក់ ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ខ្លួននោះទេ ។

ធនាគារ កាន់កាប់ទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុ ដូចខាងក្រោម ៖

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| សាច់ប្រាក់ក្នុងដៃ | 6,828,014 | 27,673,941 | 8,202,157 | 34,194,793 |
| សមតុល្យនៅធនាគារកណ្តាល | 161,236,833 | 653,492,884 | 145,442,216 | 606,348,599 |
| សមតុល្យនៅធនាគារផ្សេងៗ | 17,754,711 | 71,959,844 | 15,124,761 | 71,959,844 |
| ឥណទាន និងបុរេប្រទានអតិថិជន | 136,201,061 | 552,022,900 | 95,765,360 | 552,022,900 |
| ទ្រព្យសកម្មផ្សេងៗ | 76,455 | 309,872 | 220,068 | 309,872 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | 322,097,074 | 1,305,459,441 | 264,754,562 | 1,264,836,008 |
| **ទ្រព្យអកម្មហិរញ្ញវត្ថុ** | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 13,461,403 | 54,559,066 | 13,620,309 | 56,783,068 |
| ប្រាក់បញ្ញើរបស់អតិថិជន | 263,469,465 | 1,067,841,742 | 212,847,787 | 887,362,424 |
| អត្ថប្រយោជន៍ក្រោយពេលបញ្ចប់កិច្ច សន្យាការងារ | 840,971 | 3,408,455 | 731,794 | 3,050,849 |
| ទ្រព្យអកម្មផ្សេងៗ | 1,705,341 | 6,911,747 | 1,484,664 | 6,911,747 |
| **ទ្រព្យអកម្មហិរញ្ញវត្ថុសរុប** | 279,477,180 | 1,132,721,010 | 228,684,554 | 954,108,088 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ** | 42,619,894 | 172,738,431 | 36,070,008 | 310,727,920 |

## ២៨.១ ហានិភ័យឥណទាន

ធនាគារប្រឈមមុខនឹងហានិភ័យឥណទាន ជាហានិភ័យដែលភាគីជាដៃគូ នឹងធ្វើអោយមានការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ធនាគារ ដោយការខកខានក្នុងការបំពេញកាតព្វកិច្ចសងប្រាក់ជូនធនាគារ ។ ហានិភ័យឥណទាន គឺជាហានិភ័យដែលសំខាន់ជាងគេបំផុតក្នុងអាជីវកម្មធនាគារ ។ ហានិភ័យឥណទាន ជាចម្បងកើតមកពីសកម្មភាពផ្តល់ឥណទាន និងបុរេប្រទានជូនអតិថិជន ។ ឧបករណ៍ហិរញ្ញវត្ថុក្រៅតារាង តុល្យការ ក៏មានហានិភ័យឥណទានដែរ ដូចជាកិច្ចសន្យាឥណទានជាដើម ។ ការគ្រប់គ្រងហានិភ័យឥណទាន ត្រូវបានអនុវត្តដោយគណៈកម្មការឥណទានរបស់ធនាគារ ។

ហានិភ័យឥណទាន ត្រូវបានគ្រប់គ្រងតាមរយៈការវិភាគជាប្រចាំអំពីលទ្ធភាពរបស់អ្នកខ្ចីប្រាក់ និងអ្នកខ្ចីប្រាក់ដែលមានសក្តានុពល ដើម្បីអោយពួកគេបំពេញកាតព្វកិច្ចសងការប្រាក់ និងប្រាក់ដើម ។ មួយផ្នែកទៀត ហានិភ័យឥណទាន ក៏ត្រូវបានគ្រប់គ្រងដោយការដាក់ធានាជាវត្ថុបញ្ចាំ ឬការធានាពីបុគ្គលផ្ទាល់ផងដែរ ។

### (ក) ការវាស់វែងហានិភ័យឥណទាន

ធនាគារវាយតម្លៃប្រូបាប៊ីលីតេនៃការខកខានមិនបានសងបំណុល របស់ភាគីដៃគូជាឯកត្តជន ដោយផ្តោតលើការព្យាករអំពីប្រាក់ចំណេញ និងលំហូរសាច់ប្រាក់របស់អ្នកខ្ចីប្រាក់ ។ គណៈកម្មការឥណទាន ទទួលខុសត្រូវក្នុងការអនុម័តឥណទាន និងបុរេប្រទានជូនអតិថិជន ។

ធនាគារក៏អះអាងផងដែរថា ខ្លួនមានការបែងចែកតួនាទីច្បាស់លាស់ រវាងកាតព្វកិច្ចអ្នកលើកសំណើឥណទាន (loan originators) អ្នកវាយតម្លៃឥណទាន (evaluators) និងអាជ្ញាធរអនុម័តឥណទាន (approving authorities) ។

### (ខ) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ

ធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទាន និងបុរេប្រទានជូនឯកត្តជន ឬសហគ្រាស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ធនាគារគ្រប់គ្រងកម្រិត និងត្រួតពិនិត្យការប្រមូលផ្តុំហានិភ័យឥណទាន នៅពេលដែលគេរកឃើញ ។ ហានិភ័យធំ ត្រូវបានកំណត់និយមន័យ ដោយធនាគារកណ្តាល ថាជាហានិភ័យឥណទានទូទៅធៀបនឹងអ្នកទទួលផលជាឯកត្តជន ដែលលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។ យោងតាមលក្ខខណ្ឌនៃប្រកាសលេខ ធ៧-០៦-២២៦ប្រ.ក. របស់ធនាគារកណ្តាល ធនាគារចាំបាច់ត្រូវរក្សាគ្រប់ពេលវេលា នូវអនុបាតអតិបរមា ចំនួន ២០% រវាងហានិភ័យឥណទានទូទៅរបស់ធនាគារ ធៀបនឹងអ្នកទទួលផលឯកត្តជនណាមួយ និងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។ ហានិភ័យឥណទានធំៗសរុប មិនត្រូវលើសពី ៣០០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារទេ ។

ធនាគារ ប្រើប្រាស់គោលការណ៍ និងការអនុវត្តជាច្រើនដើម្បីកាត់បន្ថយហានិភ័យឥណទាន ហើយគោលការណ៍ជាប្រពៃណីជាងគេបំផុតក្នុងចំណោមគោលការណ៍ទាំងនេះ គឺការដាក់ធានាជាវត្ថុបញ្ចាំលើឥណទាន និងបុរេប្រទានអតិថិជន ដែលជាការអនុវត្តន៍ទូទៅមួយ ។ ធនាគារ អនុវត្តគោលការណ៍ណែនាំ ស្តីពីការទទួលយកបាននូវចំណាត់ថ្នាក់ជាក់លាក់នៃវត្ថុបញ្ចាំ ឬការកាត់បន្ថយហានិភ័យឥណទាន ។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗ ដើម្បីធានាឥណទាន និងបុរេប្រទានអតិថិជន មានដូចជា :

- វត្ថុបញ្ចាំលើទ្រព្យសម្បត្តិសម្រាប់តាំងទីលំនៅ (មានដីធ្លី អគារ និងទ្រព្យសម្បត្តិផ្សេងៗ)
- បន្ទុកផ្សេងៗលើទ្រព្យសកម្មក្នុងអាជីវកម្ម ដូចជាដីធ្លី និងអគារ និង
- សាច់ប្រាក់ ក្នុងទម្រង់ជាប្រាក់បញ្ញើមានកម្រិត

### (គ) គោលការណ៍សវិធានធន និងការថយចុះតម្លៃ

ធនាគារ ត្រូវបានតម្រូវអោយអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាននិងសវិធានធន ស្របតាមប្រកាសលេខធ៧-០៩-០៧៤ ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ធនាគារកណ្តាល ។ ប្រកាសនេះ តម្រូវអោយធនាគារពាណិជ្ជទាំងឡាយ ធ្វើចំណាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជាប្រាំថ្នាក់ ហើយកម្រិតអប្បបរមានៃសវិធានធនជាក់លាក់ ត្រូវបានធ្វើឡើងអាស្រ័យទៅតាមចំណាត់ថ្នាក់ពាក់ព័ន្ធ ដោយមិនគិតពីទ្រព្យសកម្មផ្សេងៗ ដែលបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) ដូចខាងក្រោម :

| | 2010 | 2009 |
|---|---|---|
| ឥណទានទូទៅ | 1% | 1% |
| ឥណទានឃ្លាំមើល | 3% | 3% |
| ឥណទានក្រោមស្តង់ដារ | 20% | 20% |
| ឥណទានសង្ស័យ | 50% | 50% |
| ឥណទានបាត់បង់ | 100% | 100% |

### (ឃ) ហានិភ័យអតិបរមានៃឥណទាន មុនរាប់បញ្ចូលវត្ថុបញ្ចាំ ឬមុនការបង្កើនឥណទានផ្សេងៗ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ហានិភ័យឥណទានទាក់ទិននឹង ទ្រព្យសកម្មក្នុងតារាងតុល្យការ : | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | 17,754,711 | 71,959,844 | 15,124,761 | 63,055,129 |
| ឥណទាន និងបុរេប្រទានអតិថិជន | 136,201,061 | 552,022,900 | 95,765,360 | 399,245,785 |
| ទ្រព្យសកម្មផ្សេងៗ | 76,455 | 309,872 | 220,068 | 309,872 |
| ហានិភ័យឥណទានទាក់ទិននឹង ទ្រព្យសកម្មក្រៅតារាងតុល្យការ : | | | | |
| កញ្ចប់ឥណទានដែលបានអនុម័ត | | | | |
| ប៉ុន្តែមិនទាន់បានប្រើប្រាស់ | 24,185,851 | 98,025,254 | 15,216,113 | 63,435,975 |
| លិខិតធានា ស្វីការ និងកញ្ចប់ហិរញ្ញវត្ថុផ្សេងៗ | 9,563,577 | 38,761,178 | 11,518,090 | 48,018,917 |
| | 187,781,655 | 761,079,048 | 137,844,392 | 574,065,678 |

តារាងខាងលើនេះ បង្ហាញពីស្ថានភាពអាក្រក់បំផុត នៃហានិភ័យឥណទានរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ និង២០០៩ ដោយមិនគិតលើវត្ថុបញ្ចាំ ឬការបង្កើនឥណទានផ្សេងទៀតឡើយ ។ ចំពោះទ្រព្យសកម្មក្នុងតារាងតុល្យការ ហានិភ័យដែល បានបង្ហាញខាងលើ ផ្អែកទៅលើតម្លៃនៅសល់សុទ្ធ ។

ដូចបានបង្ហាញខាងលើ ៧៣% នៃហានិភ័យអតិបរមាសរុប គឺកើតចេញពីឥណទាន និងបុរេប្រទានអតិថិជន (២០០៩ : ៦៩%) ។ គណៈគ្រប់គ្រងមានជំនឿថា ខ្លួនមានលទ្ធភាពបន្តការគ្រប់គ្រង និងទ្រទ្រង់ហានិភ័យឥណទានរបស់ធនាគារ ដែលបណ្តាលមកពីឥណទាន និងបុរេប្រទាន អោយស្ថិតនៅក្នុងកម្រិតអប្បបរមា តាមវិធីដូចខាងក្រោម :

- ៩៧% នៃសំពៀតឥណទាន (២០០៩ : ៩៧%) ត្រូវបានធានាដោយវត្ថុបញ្ចាំ ហើយឥណទានដែលធនាគារបានផ្តល់ គឺមានតម្លៃពី៥០% ទៅ ៦៥% នៃតម្លៃវត្ថុបញ្ចាំ ប៉ុន្តែភាគច្រើនគឺមានតម្លៃក្រោម ៥០% ទៅតាមគោលការណ៍របស់ធនាគារ ។
- ៨៨% នៃសំពៀតឥណទាន មិនត្រូវបានចាត់ទុកថាហួសកាលកំណត់សង ឬថយចុះតម្លៃទេ (២០០៩ : ៨០%)
- សំវិធានធនឥណទានបាត់បង់ ត្រូវបានកត់ត្រាសម្រាប់ឥណទានបាត់បង់នីមួយៗ ដោយអនុលោមទៅតាមតម្រូវការរបស់ធនាគារកណ្តាល ។

## (ង) ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទាន ត្រូវបានសង្ខេបដូចខាងក្រោម :

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ឥណទាន និងបុរេប្រទាន ដែលមិនហួសកំណត់ និងមិនថយចុះតម្លៃ | 124,218,316 | 503,456,835 | 84,438,617 | 352,024,594 |
| ឥណទាន និងបុរេប្រទាន ដែលហួសកំណត់ ប៉ុន្តែមិនថយចុះតម្លៃ | 13,486,475 | 54,660,683 | 14,777,322 | 61,606,655 |
| ឥណទាន និងបុរេប្រទានដែលថយចុះតម្លៃ | 4,201,712 | 17,029,539 | 5,938,057 | 24,755,760 |
| ឥណទាន និងបុរេប្រទាន - ដុល | 141,906,503 | 575,147,057 | 105,153,996 | 438,387,009 |
| ការប្រាក់ត្រូវទទួល | 1,379,794 | 5,592,305 | 999,927 | 4,168,696 |
| ការប្រាក់ព្យួរ | (1,323,423) | (5,363,833) | (1,575,199) | (6,567,005) |
| | 56,371 | 228,472 | (575,272) | (2,398,309) |
| ដក : | | | | |
| សំវិធានធនឥណទានបាត់បង់ | (4,348,744) | (17,625,459) | (8,060,501) | (33,604,229) |
| កម្រៃកិច្ចសន្យាឥណទានដែលមិនបានដករំលស់ | (1,413,069) | (5,727,170) | (752,863) | (3,138,686) |
| | (5,761,813) | (23,352,629) | (8,813,364) | (36,742,915) |
| ឥណទាន និងបុរេប្រទាន - សុទ្ធ | 136,201,061 | 552,022,900 | 95,765,360 | 399,245,785 |

អនុលោមទៅតាមតម្រូវការរបស់ធនាគារកណ្តាល ក្នុងការធ្វើសំវិធានធនឥណទាន សាច់ប្រាក់ដែលរំពឹងថានឹងអាចប្រមូល បានមកវិញពីវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) មិនត្រូវបានគេគិតបញ្ចូលនោះទេ។ សំវិធានធនសរុបនៃឥណទានបាត់បង់មានចំនួន ៤.៣៤៨.៧៤៤ ដុល្លារអាមេរិក គឺជាសំវិធានធនជាក់លាក់សម្រាប់ឥណទានដែលបានថយចុះតម្លៃ។

### (i) ឥណទាន និងបុរេប្រទាន ដែលមិនហួសកំណត់ និងមិនថយចុះតម្លៃ

ឥណទាន និងបុរេប្រទាន ដែលមិនហួសកំណត់ មិនត្រូវបានចាត់ទុកថាថយចុះតម្លៃទេ លុះត្រាតែមានព័ត៌មានផ្សេងទៀត ដែលចង្អុលបង្ហាញផ្ទុយពីនេះ។

### (ii) ឥណទាន និងបុរេប្រទាន ដែលហួសកំណត់ ប៉ុន្តែមិនថយចុះតម្លៃ

ឥណទាន និងបុរេប្រទាន ដែលហួសកាលកំណត់សងតិចជាង៩០ថ្ងៃ មិនត្រូវបានចាត់ទុកថាថយចុះតម្លៃទេ លុះត្រាតែមានព័ត៌មានផ្សេងទៀត ដែលចង្អុលបង្ហាញផ្ទុយពីនេះ។ ចំនួនឥណទាន និងបុរេប្រទានអតិថិជនដុល តាមចំណាត់ថ្នាក់ ដែលបានហួសកំណត់ ប៉ុន្តែមិនថយចុះតម្លៃ មានដូចខាងក្រោម :

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ហួសកាលកំណត់រហូតដល់ ៣០ ថ្ងៃ | - | - | - | - |
| ហួសកាលកំណត់ពី ៣០-៦០ ថ្ងៃ | - | - | - | - |
| ហួសកាលកំណត់ពី ៦០-៩០ ថ្ងៃ | 13,486,475 | 54,660,683 | 14,777,322 | 61,606,655 |
| សរុប | 13,486,475 | 54,660,683 | 14,777,322 | 61,606,655 |
| តម្លៃវត្ថុបញ្ចាំ | 31,306,777 | 126,886,367 | 31,306,777 | 126,886,367 |

**( ii ) ឥណទាន និងបុរេប្រទានដែលថយចុះតម្លៃ**

អនុលោមតាមប្រកាសលេខ ធ៧-០០-៥១ប្រ.ក. ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការធ្វើចំណាត់ថ្នាក់ឥណទាន និង សវិធានឥណទានអាក្រក់ និងសង្ស័យ ឥណទាន និងបុរេប្រទាន ដែលហួសកាលកំណត់លើសពី ៩០ថ្ងៃ ត្រូវបានចាត់ទុកថាថយចុះតម្លៃ ហើយកាតព្វកិច្ចសវិធានធនដាក់លាក់អប្បបរមាលើការថយចុះតម្លៃ ត្រូវបានធ្វើឡើងអាស្រ័យលើចំណាត់ថ្នាក់ដែលពាក់ព័ន្ធ លើកលែងតែ មានព័ត៌មានផ្សេងៗ ចង្អុលបង្ហាញផ្ទុយពីនេះ ។

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល មិនបានធ្វើសវនកម្ម | 2009 ដុល្លារអាមេរិក | 2009 ពាន់រៀល មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| ហួសកាលកំណត់ពី ០ - ៩០ ថ្ងៃ | - | - | - | - |
| ហួសកាលកំណត់ពី ៩០ - ១៨០ ថ្ងៃ | - | - | 150,000 | 625,350 |
| ហួសកាលកំណត់ពី ១៨០ - ៣៦០ ថ្ងៃ | 2,592,131 | 10,505,907 | - | - |
| ហួសកាលកំណត់ពី ៣៦០ ថ្ងៃ ឬលើសពីនេះ | 1,609,581 | 6,523,632 | 5,788,057 | 24,130,410 |
| សរុប | 4,201,712 | 17,029,539 | 5,938,057 | 24,755,760 |
| តម្លៃវត្ថុបញ្ចាំ | 9,039,548 | 36,637,288 | 16,087,570 | 67,069,079 |

តម្លៃទ្រព្យបញ្ចាំត្រូវបានវាយតម្លៃ ដោយអ្នកវាយតម្លៃខាងក្រៅ ឬវាយតម្លៃដោយធនាគារផ្ទាល់ ក្នុងពេលដំណើរការអនុម័តឥណទាន ។ ដោយសារតម្លៃអចលនទ្រព្យនាពេលបច្ចុប្បន្ន មានការប្រែប្រួលខ្លាំង ដូចនេះតម្លៃនៃវត្ថុបញ្ចាំដែលបានវាយតម្លៃ ក្នុងពេលអនុម័តឥណទាន អាចខុសគ្នាពីតម្លៃនាពេលបច្ចុប្បន្ន ។ អនុលោមតាមបទប្បញ្ញត្តិរបស់ធនាគារកណ្តាល តម្លៃនៃវត្ថុបញ្ចាំ មិនត្រូវបានគិតទេ នៅពេលកំណត់ការខាតបង់ឥណទាន និងបុរេប្រទានអតិថិជន ។

**( vi ) ឥណទាន និងបុរេប្រទានដែលបានចរចាឡើងវិញ**

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ មិនមានឥណទាន និងបុរេប្រទានដែលបានចរចាឡើងវិញទេ ។

### (ច) ការរឹបអូសវត្ថុបញ្ចាំ

ក្នុងអំឡុងដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ធនាគារមិនបានរឹបអូសទ្រព្យសកម្មផ្សេងៗ ដែលបានដាក់បញ្ចាំនោះទេ (២០០៩ : គ្មាន)។

ទ្រព្យសម្បត្តិដែលបានរឹបអូស ត្រូវលក់ចេញក្នុងរយៈពេល១ឆ្នាំ តាមការកំណត់របស់ធនាគារកណ្តាល ។ ទ្រព្យសម្បត្តិដែលបានរឹបអូស ត្រូវបានចាត់ថ្នាក់ជា "ទ្រព្យសម្បត្តិរឹបអូស" នៅក្នុងតារាងតុល្យការ ។

### (ឆ) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុ ធៀបនឹងហានិភ័យឥណទាន

#### i វិភាគតាមផ្នែកភូមិសាស្ត្រ

តារាងខាងក្រោមនេះ លម្អិតអំពីហានិភ័យឥណទានចម្បងៗរបស់ធនាគារ តាមតម្លៃនៅសល់របស់វា ដោយចាត់ថ្នាក់តាម តំបន់ភូមិសាស្ត្រ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ។ ក្នុងតារាងនេះ ធនាគារបានបែងចែកហានិភ័យទៅតាមប្រទេស ដោយផ្អែកលើ ប្រទេសជាភាគីដៃគូ ។

| | ប្រទេសកម្ពុជា<br>ដុល្លារអាមេរិក | សហរដ្ឋអាមេរិក និងកាណាដា<br>ដុល្លារអាមេរិក | អឺរ៉ុប<br>ដុល្លារអាមេរិក | ប្រទេសផ្សេងៗនៅក្នុងតំបន់អាស៊ាន<br>ដុល្លារអាមេរិក | ប្រទេសផ្សេងៗ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **៣១ ធ្នូ ២០១០** | | | | | | |
| សមតុល្យនៅធនាគារកណ្តាល | 161,236,833 | - | - | - | - | 161,236,833 |
| សមតុល្យនៅធនាគារផ្សេងៗ | 6,552,978 | 9,101,468 | 355,970 | 1,500,794 | 243,501 | 17,754,711 |
| ឥណទាន និងបុរេប្រទានអតិថិជន | 141,906,503 | - | - | - | - | 141,906,503 |
| ទ្រព្យសកម្មផ្សេងៗ | 76,455 | - | - | - | - | 76,455 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | 309,772,769 | 9,101,468 | 355,970 | 1,500,794 | 243,501 | 320,974,502 |
| សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម) | 1,255,509,033 | 36,888,250 | 1,442,746 | 6,082,718 | 986,910 | 1,300,909,657 |
| **៣១ ធ្នូ ២០០៩** | | | | | | |
| សមតុល្យនៅធនាគារកណ្តាល | 145,442,216 | - | - | - | - | 145,442,216 |
| សមតុល្យនៅធនាគារផ្សេងៗ | 4,200,000 | 4,865,760 | 1,786,470 | 4,084,941 | 187,590 | 15,124,761 |
| ឥណទាន និងបុរេប្រទានអតិថិជន | 105,153,996 | - | - | - | - | 105,153,996 |
| ទ្រព្យសកម្មផ្សេងៗ | 220,068 | - | - | - | - | 220,068 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | 255,016,280 | 4,865,760 | 1,786,470 | 4,084,941 | 187,590 | 265,941,041 |
| សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម) | 1,063,162,871 | 20,285,353 | 7,447,793 | 17,030,119 | 782,063 | 1,108,708,199 |

### ii វិភាគតាមប្រភេទអាជីវកម្ម

តារាងខាងក្រោមនេះ សង្ខេបហានិភ័យឥណទានរបស់ធនាគារ តាមចំនួនទឹកប្រាក់នៅសល់ ដោយវិភាគតាមប្រភេទអាជីវកម្មរបស់ដៃគូពាណិជ្ជកម្ម ។

| | គ្រឹះស្ថានហិរញ្ញវត្ថុ ដុល្លារអាមេរិក | សេវាកម្មផ្សេងៗ ដុល្លារអាមេរិក | ពាណិជ្ជកម្ម ដុល្លារអាមេរិក | អចលនទ្រព្យ ដុល្លារអាមេរិក | វិស័យផ្សេងៗ ដុល្លារអាមេរិក | ឯកត្តជន ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | | | | |
| សមតុល្យនៅធនាគារកណ្តាល | 161,236,833 | - | - | - | - | - | 161,236,833 |
| សមតុល្យនៅធនាគារផ្សេងៗ | 17,754,711 | - | - | - | - | - | 17,754,711 |
| ឥណទាន និងបុរេប្រទានអតិថិជន | 13,135,461 | 79,990,479 | 15,559,100 | 12,415,101 | 17,920,904 | 2,885,458 | 141,906,503 |
| ទ្រព្យសកម្មផ្សេងៗ | 34,558 | - | - | - | - | 41,897 | 76,455 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | 192,161,563 | 79,990,479 | 15,559,100 | 12,415,101 | 17,920,904 | 2,927,355 | 320,974,502 |
| សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម) | 778,830,815 | 324,201,411 | 63,061,032 | 50,318,404 | 72,633,424 | 11,864,570 | 1,300,909,656 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | | | | | | | |
| សមតុល្យនៅធនាគារកណ្តាល | 145,442,216 | - | - | - | - | - | 145,442,216 |
| សមតុល្យនៅធនាគារផ្សេងៗ | 15,124,761 | - | - | - | - | - | 15,124,761 |
| ឥណទាន និងបុរេប្រទានអតិថិជន | 11,694,106 | 47,753,280 | 18,305,831 | 17,527,097 | 9,139,539 | 734,143 | 105,153,996 |
| ទ្រព្យសកម្មផ្សេងៗ | 141,093 | - | - | - | - | 78,975 | 220,068 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | 172,402,176 | 47,753,280 | 18,305,831 | 17,527,097 | 9,139,539 | 813,118 | 265,941,041 |
| សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម) | 718,744,672 | 199,083,424 | 76,317,009 | 73,070,467 | 38,102,738 | 3,389,889 | 1,108,708,199 |

## ២៨.២ ហានិភ័យទីផ្សារ

ធនាគារប្រឈមមុខនឹងហានិភ័យទីផ្សារ ជាហានិភ័យដែលធ្វើអោយមានការប្រែប្រួលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់ នាពេលអនាគត នៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការផ្លាស់ប្តូរតម្លៃទីផ្សារ ។ ហានិភ័យទីផ្សារកើតឡើង ដោយសារស្ថានភាពបើកទូលាយ នៃអត្រាការប្រាក់ រូបិយប័ណ្ណ និងផលិតផលមូលធន ដែលប្រឈមមុខនឹងបម្រែបម្រួលទីផ្សារជាក់លាក់ និងទូទៅ ព្រមទាំងការប្រែប្រួលអត្រាទីផ្សារ ឬតម្លៃទីផ្សារ ដូចជាអត្រាការប្រាក់ ការរីកសាយឥណទាន អត្រាប្តូររូបិយប័ណ្ណបរទេស និងតម្លៃមូលធនជាដើម ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ធនាគារមិនមានឧបករណ៍ហិរញ្ញវត្ថុ ដែលគិតតាមតម្លៃទីផ្សារទេ ។ ធនាគារមិនបានប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instruments) ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ និងការផ្តោះប្តូរអត្រាការប្រាក់ដើម្បីគ្រប់គ្រងហានិភ័យរបស់ខ្លួននោះទេ ។

### (ក) ហានិភ័យការប្តូររូបិយប័ណ្ណបរទេស

ធនាគារធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធ្វើប្រតិបត្តិការដោយប្រើរូបិយប័ណ្ណច្រើនប្រភេទ ហើយត្រូវប្រឈមមុខនឹងហានិភ័យរូបិយប័ណ្ណផ្សេងៗគ្នាដែរ ក្នុងនោះរូបិយប័ណ្ណសំខាន់ៗ រួមមានប្រាក់រៀល និងប្រាក់អឺរ៉ូ ។

ហានិភ័យការប្តូររូបិយប័ណ្ណបរទេស កើតពីប្រតិបត្តិការពាណិជ្ជកម្មក្នុងពេលអនាគត ទ្រព្យសកម្ម និងទ្រព្យអកម្មដែលបានទទួលស្គាល់ជារូបិយប័ណ្ណមួយ ដែលមិនមែនជារូបិយប័ណ្ណគោលរបស់ធនាគារ ។

គណៈគ្រប់គ្រងត្រួតពិនិត្យហានិភ័យការប្តូររូបិយប័ណ្ណបរទេស ដោយធៀបនឹងរូបិយប័ណ្ណគោល ប៉ុន្តែធនាគារមិនបានការពារហានិភ័យការប្តូររូបិយប័ណ្ណបរទេស ដែលកើតពីប្រតិបត្តិការពាណិជ្ជកម្មក្នុងពេលអនាគត ទ្រព្យសកម្ម និងទ្រព្យអកម្មដែលបានទទួលស្គាល់ ដោយប្រើកិច្ចសន្យានាពេលអនាគតទេ ។

តារាងខាងក្រោមនេះ សង្ខេបអំពីហានិភ័ការប្តូររូបិយប័ណ្ណបរទេសរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១០ ។ ក្នុងតារាងនេះ គឺជាឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ តាមតម្លៃនៅសល់ ដោយវិភាគតាមរូបិយប័ណ្ណ និងមានតម្លៃសមមូលជាប្រាក់ ដុល្លារអាមេរិក ។

| | ប្រាក់ដុល្លារអាមេរិក | ប្រាក់រៀល | ប្រាក់ដោន | ប្រាក់យ៉េន | ប្រាក់អឺរ៉ូ | ផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | | | | |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5,710,872 | 1,117,142 | - | - | - | - | 6,828,014 |
| សមតុល្យនៅធនាគារកណ្តាល | 158,318,426 | 2,918,407 | - | - | - | - | 161,236,833 |
| សមតុល្យ នៅធនាគារផ្សេងៗ | 16,806,744 | 20,504 | 364 | 383,078 | 300,714 | 243,307 | 17,754,711 |
| ឥណទាន និងបុរេប្រទានអតិថិជនសុទ្ធ | 127,564,722 | 14,341,781 | - | - | - | - | 141,906,503 |
| ទ្រព្យសកម្មផ្សេងៗ | 59,957 | - | - | - | 16,498 | - | 76,455 |
| **ទ្រព្យសកម្មសរុប** | 308,460,721 | 18,397,834 | 364 | 383,078 | 317,212 | 243,307 | 327,802,516 |
| **ទ្រព្យអកម្ម** | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 13,322,376 | 139,027 | - | - | - | - | 13,461,403 |
| ប្រាក់បញ្ញើរបស់អតិថិជន | 245,431,276 | 17,790,796 | 2,648 | 43,566 | 48,534 | 152,645 | 263,469,465 |
| អត្ថប្រយោជន៍ក្រោយពេលបញ្ចប់កិច្ចសន្យាការងារ | 840,971 | - | - | - | - | - | 840,971 |
| ទ្រព្យអកម្មផ្សេងៗ | 1,600,049 | 105,292 | - | - | - | - | 1,705,341 |
| **ទ្រព្យអកម្មសរុប** | 261,194,672 | 18,035,115 | 2,648 | 43,566 | 48,534 | 152,645 | 279,477,180 |
| ស្ថានភាពខ្ទង់ក្នុងតារាងតុល្យការសុទ្ធ | 47,266,049 | 362,719 | (2,284) | 339,512 | 268,678 | 90,662 | 48,325,336 |
| សមមូលនឹងពាន់រៀល ( មិនបានធ្វើសវនកម្ម ) | 191,569,297 | 1,470,100 | (9,257) | 1,376,042 | 1,088,952 | 367,453 | 195,862,587 |
| កិច្ចសន្យាឥណទាន | 30,640,287 | 3,031,356 | - | 43,566 | 34,219 | - | 33,749,428 |
| សមមូលនឹងពាន់រៀល ( មិនបានធ្វើសវនកម្ម ) | 124,185,083 | 12,286,086 | - | 176,573 | 138,690 | - | 136,786,432 |

| | ប្រាក់ដុល្លារអាមេរិក | ប្រាក់រៀល | ប្រាក់ផោន | ប្រាក់យ៉េន | ប្រាក់អឺរ៉ូ | ផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | | | | | | | |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6,556,700 | 1,645,457 | - | - | - | - | 8,202,157 |
| សមតុល្យនៅធនាគារកណ្តាល | 140,243,075 | 5,199,141 | - | - | - | - | 145,442,216 |
| សមតុល្យ នៅធនាគារផ្សេងៗ | 13,197,959 | - | 20,679 | 746 | 1,738,312 | 167,065 | 15,124,761 |
| ឥណទាន និងបុរេប្រទានអតិថិជនសុទ្ធ | 91,860,678 | 13,293,318 | - | - | - | - | 105,153,996 |
| ទ្រព្យសកម្មផ្សេងៗ | 155,806 | - | - | - | 17,780 | - | 173,586 |
| **ទ្រព្យសកម្មសរុប** | 252,014,218 | 20,137,916 | 20,679 | 746 | 1,756,092 | 167,065 | 274,096,716 |
| **ទ្រព្យអកម្ម** | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 13,566,056 | 54,253 | - | - | - | - | 13,620,309 |
| ប្រាក់បញ្ញើរបស់អតិថិជន | 183,134,108 | 29,575,336 | 2,755 | - | 305 | 135,283 | 212,847,787 |
| អត្ថប្រយោជន៍ក្រោយពេលបញ្ចប់កិច្ចសន្យាការងារ | 731,794 | - | - | - | - | - | 731,794 |
| ទ្រព្យអកម្មផ្សេងៗ | 1,395,873 | 88,791 | - | - | - | - | 1,484,664 |
| **ទ្រព្យអកម្មសរុប** | 198,827,831 | 29,718,380 | 2,755 | - | 305 | 135,283 | 228,684,554 |
| **ស្ថានភាពខ្ទង់ក្នុងតារាងតុល្យការសុទ្ធ** | 53,186,387 | (9,580,464) | 17,924 | 746 | 1,755,787 | 31,782 | 45,412,162 |
| សមមូលនឹងពាន់រៀល ( មិនបានធ្វើសវនកម្ម) | 221,734,047 | (39,940,954) | 74,725 | 3,110 | 7,319,876 | 132,499 | 189,323,303 |
| កិច្ចសន្យាឥណទាន | 23,416,877 | 3,172,323 | - | - | - | 145,002 | 26,734,202 |
| សមមូលនឹងពាន់រៀល ( មិនបានធ្វើសវនកម្ម) | 97,624,960 | 13,225,415 | - | - | - | 604,513 | 111,454,888 |

### (ខ) ហានិភ័យតម្លៃ

ធនាគារប្រឈមមុខនឹងហានិភ័យតម្លៃមូលបត្រ ដោយសារធនាគារ កាន់កាប់ការវិនិយោគ ដែលបានចាត់ថ្នាក់នៅក្នុងតារាងតុល្យការ ។ បច្ចុប្បន្ននេះ ធនាគារមិនមានគោលការណ៍ដើម្បីគ្រប់គ្រងហានិភ័យតម្លៃរបស់ខ្លួននោះទេ ។ ចំណេញ-ខាត ពីការវិនិយោគនេះ នឹងត្រូវកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល ។

### (គ) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់នៃលំហូរសាច់ប្រាក់ គឺជាហានិភ័យដែលធ្វើអោយមានការប្រែប្រួល លំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការប្រែប្រួលអត្រាការប្រាក់លើទីផ្សារ ។ ហានិភ័យអត្រាការប្រាក់នៃតម្លៃទីផ្សារ គឺជាហានិភ័យ ដែលធ្វើអោយមានការប្រែប្រួលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការប្រែប្រួលអត្រាការប្រាក់លើទីផ្សារ ។ កម្រិតនៃការប្រាក់ អាចកើនឡើងដោយសារលទ្ធផលនៃការប្រែប្រួល ប៉ុន្តែអាចកាត់បន្ថយការខាតបង់ នៅក្នុងករណីដែលបម្រែបម្រួលឥតរំពឹង ទុកកើតឡើង ។ នៅដំណាក់កាលនេះ គណៈគ្រប់គ្រងមិនមានគោលការណ៍ ដើម្បីកំណត់កម្រិតនៃភាពមិនស៊ីគ្នានៃអត្រាការប្រាក់ទេ ប៉ុន្តែគណៈគ្រប់គ្រង ធ្វើការត្រួតពិនិត្យយ៉ាងទៀងទាត់ទៅលើភាពមិនស៊ីគ្នានេះ ។

តារាងខាងក្រោមនេះ សង្ខេបពីហានិភ័យអត្រាការប្រាក់របស់ធនាគារ ។ នៅក្នុងតារាងនេះ ក៏រួមបញ្ចូលនូវឧបករណ៍ ហិរញ្ញវត្ថុរបស់ធនាគារតាមតម្លៃនៅសល់ ដោយបានចាត់ថ្នាក់តាមតម្លៃក្នុងកិច្ចសន្យាដើមគ្រា ឬកាលផុតកំណត់សង ។

| | ត្រឹម១ ខែ<br>ដុល្លារអាមេរិក | ពី១-៣ ខែ<br>ដុល្លារអាមេរិក | ពី៤-១២ ខែ<br>ដុល្លារអាមេរិក | ពី១-៣ ឆ្នាំ<br>ដុល្លារអាមេរិក | ពី៣ឆ្នាំឡើងទៅ<br>ដុល្លារអាមេរិក | មិនមានការប្រាក់<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | | | | |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | 6,828,014 | 6,828,014 |
| សមតុល្យនៅធនាគារកណ្តាល | 82,900,000 | 8,000,000 | - | - | 34,195,577 | 36,141,256 | 161,236,833 |
| សមតុល្យនៅធនាគារផ្សេងៗ | 11,201,733 | - | 4,200,000 | - | - | 2,352,978 | 17,754,711 |
| ឥណទាន និងបុរេប្រទានអតិថិជន | 4,861,750 | 7,786,599 | 54,334,276 | 68,428,510 | 2,293,657 | 4,201,711 | 141,906,503 |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | 76,455 | 76,455 |
| **ទ្រព្យសកម្មសរុប** | 98,963,483 | 15,786,599 | 58,534,276 | 68,428,510 | 36,489,234 | 49,600,414 | 327,802,516 |

| | ត្រឹម១ ខែ ដុល្លារអាមេរិក | ពី១-៣ ខែ ដុល្លារអាមេរិក | ពី៤-១២ ខែ ដុល្លារអាមេរិក | ពី១-៣ ឆ្នាំ ដុល្លារអាមេរិក | ពី៣ឆ្នាំឡើងទៅ ដុល្លារអាមេរិក | មិនមានការប្រាក់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **ទ្រព្យអកម្ម** | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 710,593 | 2,430,892 | 9,606,832 | - | - | 713,086 | 13,461,403 |
| ប្រាក់បញ្ញើរបស់អតិថិជន | 120,332,766 | 11,086,776 | 40,118,303 | 42,883,788 | - | 49,047,832 | 263,469,465 |
| អត្ថប្រយោជន៍ក្រោយពេលបញ្ចប់ កិច្ចសន្យាការងារ | - | - | - | - | - | 840,971 | 840,971 |
| ទ្រព្យអកម្មផ្សេងៗ | - | - | - | - | - | 1,705,341 | 1,705,341 |
| **ទ្រព្យអកម្មសរុប** | 121,043,359 | 13,517,668 | 49,725,135 | 42,883,788 | - | 52,307,230 | 279,477,180 |
| **គំលាតអត្រាការប្រាក់សរុប** | (22,079,876) | 2,268,931 | 8,809,141 | 25,544,722 | 36,489,234 | (2,706,816) | 48,325,336 |
| សមមូលជាពាន់រៀល | (89,489,737) | 9,195,977 | 35,703,448 | 103,532,758 | 147,890,865 | (10,970,725) | 195,862,586 |
| | | | | | | | |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | | | | | | | |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | 8,202,157 | 8,202,157 |
| សមតុល្យនៅធនាគារកណ្តាល | 97,300,000 | 13,000,000 | - | - | 27,618,254 | 7,523,962 | 145,442,216 |
| សមតុល្យនៅធនាគារផ្សេងៗ | 10,924,761 | - | 4,200,000 | - | - | - | 15,124,761 |
| ឥណទាន និងបុរេប្រទានអតិថិជន | 1,328,000 | 8,833,000 | 52,094,000 | 34,971,000 | 7,353,000 | 574,996 | 105,153,996 |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | 220,068 | 220,068 |
| **ទ្រព្យសកម្មសរុប** | 109,552,761 | 21,833,000 | 56,294,000 | 34,971,000 | 34,971,254 | 16,521,183 | 274,143,198 |

| | ត្រឹម១ ខែ<br>ដុល្លារអាមេរិក | ពី១-៣ ខែ<br>ដុល្លារអាមេរិក | ពី៤-១២ ខែ<br>ដុល្លារអាមេរិក | ពី១-៣ ឆ្នាំ<br>ដុល្លារអាមេរិក | ពី៣ឆ្នាំឡើងទៅ<br>ដុល្លារអាមេរិក | មិនមានការប្រាក់<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **ទ្រព្យអកម្ម** | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 93,193 | 2,419,744 | 5,323,068 | 4,824,126 | - | 960,178 | 13,620,309 |
| ប្រាក់បញ្ញើរបស់អតិថិជន | 91,603,560 | 12,089,652 | 26,160,025 | 27,230,783 | - | 55,763,767 | 212,847,787 |
| អត្ថប្រយោជន៍ក្រោយពេលបញ្ចប់ កិច្ចសន្យាការងារ | - | - | - | - | - | 731,794 | 731,794 |
| ទ្រព្យអកម្មផ្សេងៗ | - | - | - | - | - | 1,484,664 | 1,484,664 |
| **ទ្រព្យអកម្មសរុប** | 91,696,753 | 14,509,396 | 31,483,093 | 32,054,909 | - | 58,940,403 | 228,684,554 |
| **គំលាតអត្រាការប្រាក់សរុប** | 17,856,008 | 7,323,604 | 24,810,907 | 2,916,091 | 34,971,254 | (42,419,220) | 45,458,644 |
| សមមូលជាពាន់រៀល ( មិនបានធ្វើសវនកម្ម) | 72,370,400 | 29,682,567 | 100,558,606 | 11,818,917 | 141,738,492 | (171,925,099) | 184,243,883 |

## ២៨.៣ ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យដែលធនាគារ មិនមានលទ្ធភាពបំពេញកាតព្វកិច្ចសងប្រាក់ តាមកាលកំណត់សង ចំពោះទ្រព្យអកម្មហិរញ្ញវត្ថុរបស់ខ្លួន ក៏ដូចជាមិនមានលទ្ធភាពបំពេញមូលនិធិវិញបាន នៅពេលដែលបានដកមកប្រើប្រាស់រួចហើយ ។ ផលវិបាកនេះ អាចបណ្តាលអោយធនាគារមិនអាចបំពេញកាតព្វកិច្ចសងប្រាក់ ទៅអ្នកផ្ញើប្រាក់ និងកង្វះសាច់ប្រាក់ដើម្បីអោយអតិថិជនខ្ចី ។

### (ក) ដំណើរការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល

គណៈគ្រប់គ្រងរបស់ធនាគារ តាមដានសាច់ប្រាក់ងាយស្រួលក្នុងតារាងតុល្យការ និងគ្រប់គ្រងការប្រមូលផ្តុំទិន្នន័យបំណុលដែលមានកាលកំណត់ ។ ការតាមដាន និងការធ្វើរបាយការណ៍ ត្រូវបានធ្វើឡើងក្នុងទម្រង់ជាការត្រួតពិនិត្យលើសាច់ប្រាក់ប្រចាំថ្ងៃ និងព្យាករណ៍សម្រាប់ថ្ងៃបន្ទាប់ ប្រចាំសប្តាហ៍ និងប្រចាំខែជាលំដាប់ ដោយសារវាជារយៈពេលគន្លឹះក្នុងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ។ គណៈគ្រប់គ្រង តាមដានអំពីបម្រែបម្រួលនៃអ្នកផ្ញើប្រាក់សំខាន់ៗ និងគំរោងនៃការដកសាច់ប្រាក់របស់ពួកគេ ។

### (ខ) ដំណើរការរកប្រភពទុន

ប្រភពសាច់ប្រាក់ងាយស្រួលចម្បងរបស់ធនាគារ បានមកពីដើមទុនត្រូវបង់របស់ភាគទុនិក និងប្រាក់បញ្ញើរបស់អតិថិជន ។ គណៈគ្រប់គ្រង ត្រួតពិនិត្យប្រភពសាច់ប្រាក់ងាយស្រួលប្រចាំថ្ងៃយ៉ាងទៀងទាត់ តាមរយៈការត្រួតពិនិត្យលើកាលកំណត់នៃប្រាក់បញ្ញើមានកាលកំណត់ និងអ្នកផ្ញើប្រាក់សំខាន់ៗ ។

### (គ) លំហូរសាច់ប្រាក់មិនដេរីវេ (Non-derivative cash flow)

តារាងខាងក្រោមនេះ បង្ហាញពីលំហូរសាច់ប្រាក់ដែលធនាគារត្រូវបង់ ក្រោមទ្រព្យអកម្មហិរញ្ញវត្ថុមិនដេរីវេ (non-derivative financial liabilities) ដោយផ្អែកតាមកាលកំណត់លើកិច្ចសន្យា ដែលនៅសល់ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ ។ ចំនួនដែលបានលាតត្រដាងនៅក្នុងតារាងនេះ គឺជាលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាដែលមិនធ្វើអប្បហារ ដោយឡែកធនាគារគ្រប់គ្រង ហានិភ័យសាច់ប្រាក់ងាយស្រួលដែលភ្ជាប់ជាមួយ ដោយផ្អែកតាមលំហូរសាច់ប្រាក់រំពឹងទុក ដែលមិនធ្វើអប្បហារ ។

| | ត្រឹម១ ខែ<br>ដុល្លារអាមេរិក | ពី១-៣ ខែ<br>ដុល្លារអាមេរិក | ពី៤-១២ ខែ<br>ដុល្លារអាមេរិក | ពី១-៥ ឆ្នាំ<br>ដុល្លារអាមេរិក | ពី៥ឆ្នាំឡើងទៅ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | | | |
| **ទ្រព្យអកម្ម** | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 1,437,891 | 2,503,819 | 10,087,174 | - | - | 14,028,884 |
| ប្រាក់បញ្ញើរបស់អតិថិជន | 171,787,253 | 11,419,379 | 42,124,218 | 45,671,234 | - | 271,002,084 |
| ទ្រព្យអកម្មផ្សេងៗ | 44,269 | - | - | - | - | 44,269 |
| **ទ្រព្យអកម្មសរុប** | | | | | | |
| (តាមកាលផុតកំណត់លើកិច្ចសន្យា) | 173,269,413 | 13,923,198 | 52,211,392 | 45,671,234 | - | 285,075,237 |
| សមមូលនឹងពាន់រៀល | | | | | | |
| (មិនបានធ្វើសវនកម្ម) | 702,260,931 | 56,430,721 | 211,612,772 | 185,105,512 | - | 1,155,409,936 |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | | | | | | |
| **ទ្រព្យអកម្ម** | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 1,055,235 | 2,492,336 | 5,589,221 | 5,137,694 | - | 14,274,486 |
| ប្រាក់បញ្ញើរបស់អតិថិជន | 149,199,398 | 12,452,342 | 27,468,026 | 29,000,784 | - | 218,120,550 |
| ទ្រព្យអកម្មផ្សេងៗ | 40,267 | - | - | - | - | 40,267 |
| **ទ្រព្យអកម្មសរុប** | | | | | | |
| (តាមកាលផុតកំណត់លើកិច្ចសន្យា) | 150,294,900 | 14,944,678 | 33,057,247 | 34,138,478 | - | 232,435,303 |
| សមមូលនឹងពាន់រៀល | | | | | | |
| (មិនបានធ្វើសវនកម្ម) | 626,579,438 | 62,304,363 | 137,815,663 | 142,323,315 | - | 969,022,779 |

### (ឃ) ខ្ទង់ក្រៅតារាងតុល្យការ

**i កិច្ចសន្យាឥណទាន**

កាលបរិច្ឆេទនៃចំនួនក្នុងកិច្ចសន្យា នៃឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការរបស់ធនាគារ ដែលត្រូវពន្យារឥណទាន និងកញ្ចប់ឥណទានផ្សេងៗជូនអតិថិជន (កំណត់សម្គាល់ ២៦) ត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម ។

**ii កញ្ចប់ហិរញ្ញវត្ថុផ្សេងៗ**

កញ្ចប់ហិរញ្ញវត្ថុផ្សេងៗ (កំណត់សម្គាល់ ២៦) ក៏ត្រូវបានរួមបញ្ចូលនៅក្នុងតារាងខាងក្រោមដែរ ដោយផ្អែកតាមកាលបរិច្ឆេទក្នុងកិច្ចសន្យាដំបូងគេបង្អស់ ។

តារាងខាងក្រោមនេះ បង្ហាញពីលំហូរសាច់ប្រាក់ចេញ ដែលកើតចេញពីកិច្ចសន្យាហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ដោយផ្អែកតាមកាលផុតកំណត់ក្នុងកិច្ចសន្យា :

| | មិនលើស១ឆ្នាំ<br>ដុល្លារអាមេរិក | ១-៥ ឆ្នាំ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | |
| កញ្ចប់ឥណទានដែលមិនទាន់បានប្រើ | 23,273,960 | 911,891 | 24,185,851 |
| លិខិតឥណទាន | 7,376,548 | 2,187,029 | 9,563,577 |
| កិច្ចសន្យាទាក់ទងនឹងទ្រព្យសម្បត្តិ និងបរិក្ខារ | 29,113 | - | 29,113 |
| កិច្ចសន្យាភតិសន្យាប្រតិបត្តិ | 17,052 | 43,250 | 60,302 |
| **សរុប** | 30,696,673 | 3,142,170 | 33,838,843 |
| សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម) | 124,413,616 | 12,735,215 | 137,148,831 |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | | | |
| កញ្ចប់ឥណទានដែលមិនទាន់បានប្រើ | 15,038,879 | 177,234 | 15,216,113 |
| លិខិតឥណទាន | 10,720,913 | 797,176 | 11,518,089 |
| កិច្ចសន្យាទាក់ទងនឹងទ្រព្យសម្បត្តិ និងបរិក្ខារ | 76,646 | - | 76,646 |
| កិច្ចសន្យាភតិសន្យាប្រតិបត្តិ | 68,000 | 7,200 | 75,200 |
| **សរុប** | 25,904,438 | 981,610 | 26,886,048 |
| សមមូលនឹងពាន់រៀល (មិនបានធ្វើសវនកម្ម) | 107,995,602 | 4,092,332 | 112,087,934 |

## ២៨.៤ តម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអកម្មហិរញ្ញវត្ថុ

### (ក) ឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាមតម្លៃទីផ្សារ

ធនាគារ មិនមានឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវវាស់វែងតាមតម្លៃទីផ្សារទេ ។

## (ខ) ឧបករណ៍ហិរញ្ញវត្ថុមិនវាស់វែងតាមតម្លៃទីផ្សារ

តារាងខាងក្រោមនេះ សង្ខេបពីតម្លៃនៅសល់ និងតម្លៃទីផ្សារនៃរាល់ទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុ ដែលមិនបានបង្ហាញនៅលើតារាងតុល្យការរបស់ធនាគារ តាមតម្លៃទីផ្សាររបស់វា។

| | តម្លៃនៅសល់ | | តម្លៃទីផ្សារ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក 2010 | ដុល្លារអាមេរិក 2009 | ដុល្លារអាមេរិក 2010 | ដុល្លារអាមេរិក 2009 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| សមតុល្យនៅធនាគារកណ្តាល | 161,236,833 | 653,492,884 | 145,442,216 | 606,348,599 |
| សមតុល្យនៅធនាគារផ្សេងៗ | 17,754,711 | 15,124,761 | 17,754,711 | 15,124,761 |
| ឥណទាន និងបុរេប្រទានអតិថិជន | 136,201,061 | 95,765,360 | 136,201,061 | 95,765,360 |
| ទ្រព្យសកម្មផ្សេងៗ | 76,455 | 220,068 | 76,455 | 220,068 |
| **ទ្រព្យអកម្មហិរញ្ញវត្ថុ** | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 13,461,403 | 13,620,309 | 13,461,403 | 13,620,309 |
| ប្រាក់បញ្ញើរបស់អតិថិជន | 263,469,465 | 212,847,787 | 263,469,465 | 212,847,787 |
| អត្ថប្រយោជន៍ក្រោយពេលបញ្ចប់ កិច្ចសន្យាការងារ | 840,971 | 731,794 | 840,971 | 731,794 |
| ទ្រព្យអកម្មផ្សេងៗ | 1,705,341 | 1,484,664 | 1,705,341 | 1,484,664 |
| **ឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការ :** | | | | |
| កញ្ចប់ឥណទានបានអនុម័តរួច និងមិនទាន់បានប្រើ | | | 24,185,851 | 15,216,113 |
| លិខិតធានា ស្វីការ និងកញ្ចប់ឥណទានផ្សេងៗ | | | 9,563,577 | 11,518,090 |

### (i) សមតុល្យនៅធនាគារផ្សេងៗ

សមតុល្យនៅធនាគារផ្សេងៗ រួមមានគណនីចរន្តដែលមិនមានការប្រាក់ គណនីប្រាក់បញ្ញើសន្សំ គណនីប្រាក់បញ្ញើរយៈពេលខ្លីបំផុត និងគណនីប្រាក់បញ្ញើមានកាលកំណត់។ តម្លៃទីផ្សារនៃសមតុល្យនៅធនាគារផ្សេងៗ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃនៅ សល់របស់វា។

### (ii) ឥណទាន និងបុរេប្រទានអតិថិជន

ឥណទាន និងបុរេប្រទានគឺជាចំនួនសុទ្ធ បន្ទាប់ពីបានកាត់កងសំវិធានធនឥណទានបាត់បង់។ សំវិធានធនឥណទានបាត់បង់ត្រូវបានធ្វើឡើងតាមតម្រូវការនៃប្រកាសរបស់ធនាគារកណ្តាល។

### (iii) ប្រាក់បញ្ញើរបស់ធនាគារ និងប្រាក់បញ្ញើរបស់អតិថិជន

តម្លៃទីផ្សារនៃប្រាក់បញ្ញើរបស់ធនាគារ និងប្រាក់បញ្ញើរបស់អតិថិជន មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃនៅសល់។ តម្លៃទីផ្សារប៉ាន់ស្មាននៃប្រាក់បញ្ញើដែលមិនបញ្ជាក់កាលកំណត់ ដូចជាប្រាក់បញ្ញើមិនមានការប្រាក់ គឺជាចំនួនដែលត្រូវសងវិញតាមតម្រូវការ។

ប្រាក់បញ្ញើដែលមានអត្រាការប្រាក់ថេររបស់ធនាគារ មិនត្រូវបានដាក់លក់នៅលើទីផ្សារសកម្មទេ ហើយមានរយៈពេលខ្លី។ តម្លៃទីផ្សាររបស់វា មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃនៅសល់។

( iv ) **ទ្រព្យសកម្ម និងទ្រព្យអកម្មផ្សេងៗ**

តម្លៃនៅសល់នៃទ្រព្យសកម្ម និងទ្រព្យអកម្មផ្សេងៗ ត្រូវបានសន្មតថាមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃទីផ្សាររបស់វា ដោយសារគណនីទាំងនេះ មិនមានភាពប្រែប្រួលជាសារវន្ត ទៅតាមអត្រាការប្រាក់លើទីផ្សារទេ ។

## ២៨.៥ ការគ្រប់គ្រងដើមទុន

វត្ថុវិស័យរបស់ធនាគារ ក្នុងការគ្រប់គ្រងដើមទុន ដែលជាបញ្ញត្តិដ៏ទូលំទូលាយជាង "មូលធន" នៅលើតារាងតុល្យការ គឺ :

- អនុលោមតាមតម្រូវការដើមទុន ដែលកំណត់ដោយធនាគារកណ្តាល
- ការពារលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តភាពអាជីវកម្ម ដើម្បីអោយធនាគារអាចបន្តផ្តល់ប្រយោជន៏ដល់ភាគទុនិក និងដល់ភាគីដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម

ធនាគារកណ្តាល តម្រូវអោយធនាគារពាណិជ្ជទាំងអស់ : (i) រក្សាដើមទុនអប្បបរមា (ii) រក្សាមូលនិធិផ្ទាល់សុទ្ធរបស់ ធនាគារ យ៉ាងហោចណាស់អោយស្មើនឹងដើមទុនអប្បបរមា និង (iii) អនុលោមតាមអនុបាតសាធនភាព និងអនុបាតសាច់ប្រាក់ងាយស្រួល ។

តារាងខាងក្រោមនេះ សង្ខេបពីសមាសភាពដើមទុនតាមច្បាប់ :

| | 2010<br>ដុល្លារអាមេរិក | 2010<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល<br>មិនបានធ្វើសវនកម្ម |
|---|---|---|---|---|
| **ដើមទុនថ្នាក់ទី ១** | | | | |
| ដើមទុនតាមច្បាប់ | 35,750,000 | 144,894,750 | 13,000,000 | 54,197,000 |
| ទុនបម្រុង | 2,945,589 | 11,938,472 | 4,236,822 | 17,663,312 |
| ចំណេញរក្សាទុក | 8,965,303 | 36,336,373 | 24,031,594 | 100,187,715 |
| | 47,660,892 | 193,169,595 | 41,268,416 | 172,048,027 |
| **ដក :** | | | | |
| ទ្រព្យសកម្មអរូបី | (379,684) | (1,538,859) | (439,394) | (1,831,834) |
| ការចូលរួមមូលធន ក្នុងធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ | (5,000) | (20,265) | - | - |
| | (384,684) | (1,559,124) | (439,394) | (1,831,834) |
| មូលនិធិផ្ទាល់សុទ្ធ | 47,276,208 | 191,610,471 | 40,829,022 | 170,216,193 |

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ មានចំនួន ៤៧.២៧៦.២០៨ ដុល្លារអាមេរិក ។ ធនាគារ ត្រូវតែរក្សាមូលនិធិផ្ទាល់សុទ្ធ យ៉ាងហោចណាស់ស្មើនឹងដើមទុនអប្បបរមា ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ មូលនិធិផ្ទាល់សុទ្ធ របស់ធនាគារដែលមានចំនួន ៤៧.២៧៦.២០៨ ដុល្លារអាមេរិក គឺខ្ពស់ជាងចំនួន ១១.៥២៦.២០៨ ដុល្លារអាមេរិក បើធៀបនឹងដើមទុនអប្បបរមាចំនួន ៣៥.៧៥០.០០០ ដុល្លារអាមេរិក ( កំណត់សម្គាល់ ១៥) ។

## ២៩. ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទតារាងតុល្យការ

នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ធនាគារកណ្តាលបានអនុម័តលើសំណើសុំរបស់ធនាគារ ដើម្បីបង្កើនដើមទុនរបស់ខ្លួនពី ៣៩.៧៥០.០០០ ដុល្លារអាមេរិក ទៅ ៣៧.៥០០.០០០ ដុល្លារអាមេរិក ដោយការផ្ទេរពីគណនីទុនបម្រុង។ ការបង្កើនដើមទុនរបស់ធនាគារ គឺដើម្បីបំពេញតាមតម្រូវការដើមទុនអប្បបរមារបស់ធនាគារកណ្តាល។

## ៣០. តួលេខប្រៀបធៀប

តួលេខប្រៀបធៀបមួយចំនួន ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ ដើម្បីអោយស្របតាមការបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ក្នុងឆ្នាំនេះ និងដើម្បីអនុលោមតាមតម្រូវការនៃប្រកាសលេខ ធ៧-០៤-២០៤ប្រ.ក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ។

| | តួលេខក្នុងរបាយការណ៍<br>ដុល្លារអាមេរិក | ការធ្វើចំណាត់ថ្នាក់ឡើងវិញ<br>ដុល្លារអាមេរិក | សមតុល្យដែលបានធ្វើចំណាត់ថ្នាក់ឡើងវិញ<br>ដុល្លារអាមេរិក |
|---|---|---|---|
| **តារាងតុល្យការ** | | | |
| **ទ្រព្យសកម្ម** | | | |
| សមតុល្យនៅធនាគារកណ្តាល | - | 145,442,216 | 145,442,216 |
| សមតុល្យនៅធនាគារផ្សេងៗ | 132,948,727 | (117,823,966) | 15,124,761 |
| ប្រាក់តម្កល់តាមច្បាប់ | 27,618,254 | (27,618,254) | - |
| ទ្រព្យសកម្មផ្សេងៗ | 531,911 | (47,972) | 483,939 |
| | 161,098,892 | (47,976) | 161,050,916 |
| **ទ្រព្យអកម្ម** | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | - | 13,620,309 | 13,620,309 |
| ប្រាក់បញ្ញើរបស់អតិថិជន | - | 212,847,787 | 212,847,787 |
| ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារផ្សេងៗ | 226,229,038 | (226,229,038) | - |
| ទ្រព្យអកម្មផ្សេងៗ | 2,463,667 | (287,034) | 2,176,633 |
| | 228,692,705 | (47,976) | 228,644,729 |
| **របាយការណ៍លទ្ធផល** | | | |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | 4,400,284 | (4,400,284) | - |
| ចំណាយផ្នែកបុគ្គលិក | - | 1,915,902 | 1,915,902 |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | - | 366,179 | 366,179 |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | - | 2,118,203 | 2,118,203 |
| ចំណូលប្រតិបត្តិការផ្សេងៗ | 5,437,812 | (4,911,818) | 525,994 |
| សំវិធានធនឥណទាន និងបុរេប្រទានបាត់បង់ និងសង្ស័យ | (4,443,089) | 4,443,089 | - |
| ការប្រមូលបានមកវិញ នៃឥណទានបាត់បង់ និងការប្រាក់សុទ្ធ | - | 468,729 | 468,729 |
| | 5,395,007 | - | 5,395,007 |